ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# របាយការណ៍ស្រាវជ្រាវស្តីពី

# ស្ថានភាពកុមារដែលរងផលប៉ះពាល់ដោយចំណាកស្រុកឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ

ខែមករា ឆ្នាំ ២០២៥

*ការបោះពុម្ពនេះផ្តល់មូលនិធិដោយសហភាពអឺរ៉ុបតាមរយៈអង្គការ UNICEF។ ខ្លឹមសារនៃរបាយការណ៍នេះគឺជាការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*

PROTECT

Protection of the Rights of Women and Children in Labour Migration Project (PROTECT) is a joint project implemented by ILO, UN Women, UNICEF and UNODC, funded by the EU.

*គាំទ្រដោយ European Union តាមរយៈ UNICEF*

# សេចក្តីថ្លែងអំណរគុណ

ការធ្វើចំណាកស្រុកបានក្លាយជាបាតុភូតសកលដែលមានឥទ្ធិពលលើកុមាររាប់លាននាក់។ ខណៈពេលដែលការធ្វើចំណាកស្រុកអាចផ្តល់អត្ថប្រយោជន៍ដល់កុមារ និងគ្រួសាររបស់ពួកគេ ចំណាកស្រុកក៏អាចធ្វើឱ្យកុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ផងដែរ ជាពិសេសនៅពេលដែលកុមារផ្លាស់ទីទៅក្រៅសំណាញ់សុវត្ថិភាព និងផ្លូវច្បាប់ ឬត្រូវបានទុកដាក់នៅក្នុងសហគមន៍ដែលឪពុកម្តាយ ឬអ្នកថែទាំបានធ្វើចំណាកស្រុក កុមារអាចប្រឈមនឹងការកេងប្រវ័ញ្ច ឬការរំលោភបំពាននានា។

ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាប្តេជ្ញាការពារសិទ្ធិជនទេសន្តរប្រវេសន៍ ជាពិសេសកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ ការសិក្សាស្តីពីស្ថានភាពកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ រវាងកម្ពុជា និងថៃ ធ្វើឡើងដើម្បីជាមូលដ្ឋានសម្រាប់រៀបចំគម្រោងអន្តរាគមន៍នានា ក្នុងគោលបំណងការពារសិទ្ធិកុមារ និងដើម្បីគាំទ្រដល់ការបង្កើតអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនរវាងកម្ពុជា និងថៃ ដើម្បីការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារបច្ចេកទេសអន្តរក្រសួង និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានចំណាយពេលវេលា និងចែករំលែកចំណេះដឹង ដើម្បីពិនិត្យ និងផ្តល់ធាតុចូលលើរបាយការណ៍ស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកស្រី Robin Mauney ទីប្រឹក្សាបច្ចេកទេស និងក្រុមការងារ ព្រមទាំងអង្គការ UNICEF សម្រាប់ការគាំទ្រផ្នែកបច្ចេកទេសដល់ការសិក្សាស្រាវជ្រាវនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់សហភាពអឺរ៉ុប សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុតាមរយៈគម្រោង PROTECT-ការការពារសិទ្ធិស្ត្រី និងកុមារក្នុងការធ្វើចំណាកស្រុកការងារ។

ខ្ញុំជឿជាក់ថា របកគំហើញ និងអនុសាសន៍ពីរបាយការណ៍ស្រាវជ្រាវនេះ គឺមានសារៈសំខាន់សម្រាប់ក្រសួងពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីចូលរួមកិច្ចខិតខំប្រឹងប្រែងជាមួយរាជរដ្ឋាភិបាល ដើម្បីការពារសិទ្ធិកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។

ថ្ងៃ ចន្ទ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០២៥

រដ្ឋមន្ត្រី

ជា សុមេធី

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** .......... 2
**ពាក្យកាត់ និង អក្សរកាត់** .......... 5
**សង្ខេបខ្លឹមសារ** .......... 6
អនុសាសន៍ .......... 9
ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ .......... 9
ការបន្តសេវាដល់កុមារ និងគ្រួសារ .......... 11
ការគ្រប់គ្រងករណី .......... 12
ទិន្នន័យ និងការស្រាវជ្រាវ .......... 13
**សេចក្តីផ្តើម** .......... 14
គោលបំណង .......... 15
វិធីសាស្ត្រស្រាវជ្រាវ .......... 17
ការពិនិត្យឯកសារស្រាវជ្រាវ .......... 17
ការប្រមូលទិន្នន័យបឋមនៅមូលដ្ឋាន .......... 17
និយមន័យ និងវាក្យស័ព្ទ .......... 19
**លទ្ធផលរកឃើញ** .......... 22
**បរិបទប្រទេសកម្ពុជា** .......... 22
**ពលករកម្ពុជាធ្វើទេសន្តរប្រវេសន៍ទៅកាន់ប្រទេសថៃ** .......... 25
**ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ** .......... 26
*ការប្តេជ្ញាចិត្ត និងសកម្មភាពអន្តរជាតិ ពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍* .......... 26
**ក្របខ័ណ្ឌអាស៊ាន និងការប្តេជ្ញាចិត្ត** .......... 31
*កិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋសមាជិកអាស៊ាន* .......... 33
*ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយពាក់ព័ន្ធនៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជា លើកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍* .......... 34
**ក្តីបារម្ភ និងបញ្ហារបស់កុមារដែលចេញទៅប្រទេសថៃ** .......... 38
*ទេសន្តរប្រវេសន៍មិនប្រក្រតី* .......... 39
*ការមើលថែកុមារ* .......... 40
*ការចុះបញ្ជីកំណើត និងឯកសារច្បាប់* .......... 41
*ការសិក្សាអប់រំ* .......... 42
*ការទទួលបានសេវាសុខភាព* .......... 43
*ពលកម្មកុមារ* .......... 44
*ការជួញដូរកុមារ* .......... 45
*ការឃុំខ្លួន* .......... 46

**ប្រព័ន្ធកិច្ចការពារកុមារ** ........ 47
*ប្រព័ន្ធកិច្ចការពារកុមារនៅប្រទេសកម្ពុជា* ........ 47
*ប្រព័ន្ធកិច្ចការពារកុមារនៅប្រទេសថៃ* ........ 50
*ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញនៅក្នុងប្រទេសកម្ពុជា* ........ 50
*ភាគីពាក់ព័ន្ធសំខាន់ៗក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញ* ........ 53
**ការអនុវត្ត និងគំរូល្អៗក្នុងកិច្ចការពារ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញចំពោះកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍** ........ 54
ចន្លោះប្រហោងក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ និងការអនុវត្ត ........ 56
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 59
**សេចក្តីសន្និដ្ឋាន** ........ 59
**អនុសាសន៍** ........ 61
*ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ* ........ 61
*ការបន្តសេវាដល់កុមារ និងគ្រួសារ* ........ 63
*ការគ្រប់គ្រងករណី* ........ 64
*ទិន្នន័យ និងការស្រាវជ្រាវ* ........ 64
**ឧបសម្ព័ន្ធទី ១៖ ការធ្វើផែនទីអង្គការរួកពាក់ព័ន្ធ និងអង្គការអន្តរជាតិ** ........ 66
ប្រទេសកម្ពុជា ........ 66
ប្រទេសថៃ ........ 69
**ឧបសម្ព័ន្ធ២៖ ស្ថានភាពកុមារដែលទុកនៅស្រុកកំណើត** ........ 70
ហេតុផលទេសន្តរប្រវេសន៍របស់ឪពុកម្តាយ និងការទុកកូនៗនៅស្រុកកំណើត ........ 70
កត្តាសេដ្ឋកិច្ច ........ 72
ទេសន្តរប្រវេសន៍មិនប្រក្រតី និងក្តីបារម្ភពីសុត្ថិភាព ........ 72
ការសិក្សាអប់រំរបស់កុមារ ........ 73
ការរៀបចំកិច្ចការថែទាំកុមារ ........ 73
ប្រេវ៉ាឡង់ លក្ខណៈ និងកាលៈទេសៈរបស់កុមារដែលទុកនៅស្រុកកំណើត ........ 73
អ្នកមើលថៃកុមារដែលទុកនៅស្រុកកំណើត ........ 74
ការផ្ញើរប្រាក់របស់ឪពុកម្តាយទេសន្តរប្រវេសន៍ ........ 75
ទំនាក់ទំនងជាមួយឪពុកម្តាយទេសន្តរប្រវេសន៍ ........ 75
ស្ថានភាពឪពុកម្តាយទេសន្តរប្រវេសន៍ ជំពោះកូនៗទុកនៅស្រុកកំណើត ........ 76
ហានិភ័យនៃកិច្ចការពារ ........ 76
ការទទួលបានតម្រូវការមូលដ្ឋាន និងការសិក្សា ........ 76
ការមិនយកចិត្តទុកដាក់ និងកុមារមានតួនាទីជាអ្នកមើលថៃ ........ 77
ការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ........ 78
ពលកម្មកុមារ ពលកម្មដោយបង្ខំ និងការជួញដូរ ........ 78

# ពាក្យកាត់ និង អក្សរកាត់

| | | |
|---|---|---|
| APLE | Action Pour Les Enfants | អង្គការសកម្មភាពដើម្បីកុមារកម្ពុជា |
| ASEAN | Association of Southeast Asia Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CARAM | Coordination of Action Research on AIDS and Mobility Cambodia | អង្គការសម្របសម្រួលការស្រាវជ្រាវសកម្មភាពលើជំងឺអេដស៍ និងការចល័តនៅកម្ពុជា |
| CEDAW | Convention on the Elimination of Discrimination against Women | អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី |
| CENTRAL | Center for Alliance of Labor and Human Rights | មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស |
| CCWC | Commune Committee for Women and Children | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់ |
| CPCR | Center for the Protection of Children's Rights Foundation | មជ្ឈមណ្ឌលការពារសិទ្ធិកុមារ |
| CLEC | Community Legal Education Center | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| CRC | Convention on the Rights of the Child | អនុសញ្ញាស្តីពីសិទ្ធកុមារ |
| CWCC | Cambodia Women's Crisis Center | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| CRPD | Convention on the Rights of Persons with Disabilities | អនុសញ្ញាស្តីពីសិទ្ធិជនដែលមានពិការភាព |
| FGD | Focus Group Discussion | ក្រុមពិភាក្សា |
| GCM | Global Compact for Migration | កាតិកាសញ្ញាសកលសម្រាប់ទេសន្តរប្រវេសន៍ |
| GDG | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| ID Poor Card | Identification of Poor Household Program (ID Poor Card) | កម្មវិធីកំណត់រកគ្រួសារក្រីក្រ ប័ណ្ណក្រីក្រ)) |
| IOM | International Organization of Migration | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| KIIs | Key Informant Interview | ការ**សម្ភាសន៍**អ្នកផ្តល់ព័ត៌មានសំខាន់ៗ |
| KMR | Komar Rikreay | អង្គការកុមាររីករាយ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MOU | Memorandum of Understanding | អនុស្សរណៈនៃការយោគយល់គ្នា |
| PDoSVY | Provincial Department of Social Affairs, Veterans and Youth Rehabilitation | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| SDG | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SOP | Standard Operating Procedure | ស្តង់ដារនីតិវិធីប្រតិបត្តិ |

# សង្ខេបខ្លឹមសារ

នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មានជនទេសន្តរប្រវេសន៍អន្តរជាតិចំនួនជាង ១០ លាននាក់ ហើយប្រទេសថៃនៅតែជាប្រទេសគោលដៅចម្បងសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជា។ ពលករទេសន្តរប្រវេសន៍កម្ពុជាមានចំនួនប្រមាណ ១,៣លាននាក់ កំពុងរស់នៅក្រៅប្រទេស ភាគច្រើនរស់នៅប្រទេសថៃ និងប្រទេសកូរ៉េខាងត្បូង[1]។ មិនមានទិន្នន័យអំពីកុមារទេសន្តរប្រវេសន៍ដែលរួមដំណើរជាមួយឪពុកម្តាយនោះទេ ទោះបីកុមារដែលទុកនៅស្រុកកំណើតមានចំនួនច្រើនជាងនេះក្តី ក៏នៅមានកុមារទេសន្តរប្រវេសន៍មួយចំនួនធំ បានរួមដំណើរចាកចេញទៅជាមួយគ្រួសាររបស់ពួកគេ និងសូម្បីធ្វើដំណើរតែម្នាក់ឯងក៏មាន។

"កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍" គឺជាកន្សោមពាក្យទូលំទូលាយ រួមមានកុមារ (អាយុក្រោម ១៨ ឆ្នាំ) ដែលកំពុងផ្លាស់ទី ឬបានផ្លាស់ទីលំនៅ ចាកចេញពីប្រទេសដើមរបស់ខ្លួន ឬឆ្លងកាត់ច្រកព្រំដែន ចូលទៅកាន់ប្រទេសមួយទៀត ទាំងបណ្តោះអាសន្នក្តី ឬអចិន្ត្រៃយ៍ក្តី។ នៅប្រទេសកម្ពុជា ក៏ដូចជាប្រទេសជិតខាង កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍កើតឡើង នៅពេលឪពុកម្តាយទេសន្តរប្រវេសន៍ម្នាក់ ឬទាំងពីរនាក់ ទុកកុមារនៅស្រុកកំណើត កុមាររួមដំណើរជាមួយឪពុកម្តាយ (ឬកុមារកើតនៅបរទេស) ឬកុមារធ្វើដំណើរតែម្នាក់ឯង។

សម្ពាធសេដ្ឋកិច្ច ជំរុញឱ្យមានទេសន្តរប្រវេសន៍អន្តរជាតិកើតឡើង។ ការជាប់បំណុលច្រើន បម្រែបម្រួលអាកាសធាតុ និងកត្តាផ្សេងៗទៀត ជំរុញឱ្យប្រជាជនកម្ពុជាស្វែងរកការងារធ្វើនៅក្រៅប្រទេស។ ទោះបីទេសន្តរប្រវេសន៍អាចផ្តល់ផលប្រយោជន៍ដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេក្តី ក៏ពួកអ្នកដែលងាយរងគ្រោះរួចទៅហើយ ដោយសារភាពក្រីក្រ ការប្រែប្រួលអាកាសធាតុ និងកត្តាផ្សេងៗទៀតនោះ នៅតែបន្តប្រឈមបញ្ហាធំៗ។ កុមារដែលមានពិការភាពអាចស្ថិតក្នុងចំណោមជនងាយរងគ្រោះជាងគេបំផុត។ ពួកគេប្រឈមខ្វះខាតជីវភាពប្រចាំថ្ងៃ ហើយទេសន្តរប្រវេសន៍អាចធ្វើឱ្យពិការភាពរបស់ពួកគេកាន់តែមានសភាពធ្ងន់ធ្ងរ និងកាន់តែងាយរងគ្រោះ។ ជាញឹកញាប់ តម្រូវការរបស់ពួកគេ មិនត្រូវបានរាប់បញ្ចូលក្នុងដំណើរការរៀបចំផែនការនោះទេ។

ការស្រាវជ្រាវនេះ មានគោលបំណងផ្តល់ជាឯកសារចំណេះដឹង ស្តីអំពីបទពិសោធន៍របស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ក្នុងស្ថានភាពឆ្លងច្រកព្រំដែនជាមួយប្រទេសថៃ រួមមាន ការទទួលបានសេវា ក្រប ខ័ណ្ឌគោលនយោបាយ ដំណើរការ និងយន្តការនានា ទាំងនៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជា និងថាតើរបៀបដែលដំណើរការ និងប្រព័ន្ធការពារកុមារ រៀបចំកិច្ចការធ្វើមាតុភូមិនិវត្តន៍ និងនិរទេស ប្រព្រឹត្តទៅយ៉ាងដូចម្តេច ហើយថាតើដំណើរការទាំងនេះគិតដល់ឧត្តមប្រយោជន៍កុមារដែរ ឬទេ។

[1] https://www.khmertimeskh.com/501521096/govt-provides-robust-assistance-to-1-3-million-migrant-workers/

ការស្រាវជ្រាវដែលមានស្រាប់នាពេលបច្ចុប្បន្ន និងបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ មានដូចជា បុគ្គលិករដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងក្រុមគ្រួសាររបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ត្រូវបានធ្វើឡើង ដើម្បីយល់ឱ្យកាន់តែច្បាស់អំពីស្ថានភាពរបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។

**លទ្ធផលរកឃើញសំខាន់ៗ៖**

- កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ រួមមាន កុមារដែលទុកនៅស្រុកកំណើត កុមាររួមដំណើរជាមួយឪពុកម្តាយទៅធ្វើការ ឬកុមារធ្វើដំណើរតែឯង (គ្មានអ្នករួមដំណើរជាមួយ) ឬកុមារដែលត្រូវបានបំបែកចេញពីឪពុកម្តាយ។
- ទេសន្តរប្រវេសន៍ កើតឡើងដោយកត្តាជាច្រើន រួមមាន លទ្ធភាពទទួលបានឱកាសជីវភាពប្រសើរ។ កត្តាដូចជាផលប៉ះពាល់អាកាសធាតុកំពុងជំរុញឱ្យមនុស្សកាន់តែច្រើនឡើងធ្វើទេសន្តរប្រវេសន៍។
- គ្រួសារជាច្រើនធ្វើទេសន្តរប្រវេសន៍តាមមធ្យោបាយមិនប្រក្រតី ដោយសារការចំណាយច្រើន និងកត្តាផ្សេងៗទៀត។ ចំណុចនេះបណ្តាលឱ្យមានចន្លោះប្រហោងក្នុងការទទួលទិន្នន័យស្តីពីកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ដោយសារពួកគេមិនត្រូវប្រមូលដាក់បញ្ចូលក្នុងដំណើរការទិន្នន័យ។ ដូច្នេះ គេមិនដឹងថាមានកុមារប៉ុន្មាននាក់ដែលធ្វើទេសន្តរប្រវេសន៍ជាមួយគ្រួសារ ធ្វើដំណើរដោយខ្លួនឯង ឬត្រូវបានបំបែកពីគ្រួសារនៅប្រទេសថៃ នោះទេ។
- គ្រួសារ ហើយជួនកាលទាំងកុមារផង (ដែលកំពុងធ្វើការ) ចេញទៅធ្វើការនៅប្រទេសថៃទំនងជាធ្វើការក្នុងវិស័យក្រៅប្រព័ន្ធដែលមិនសូវមានការគ្រប់គ្រងច្បាស់លាស់។
- ការស្រាវជ្រាវនេះបានធ្វើការបញ្ជាក់លើការស្រាវជ្រាវដែលមានស្រាប់ដែលបង្ហាញថាទេសន្តរប្រវេសន៍មានផលប្រយោជន៍ចំពោះកុមារ និងក្រុមគ្រួសាររបស់ពួកគេមែន ប៉ុន្តែក៏មានបញ្ហាជាច្រើនដែលកុមារប្រឈមក្នុងការទទួលបានសិទ្ធិជាមូលដ្ឋានរបស់ខ្លួន មិនថាកុមារទុកនៅស្រុក កុមារទៅជាមួយឪពុកម្តាយ ឬធ្វើដំណើរតែឯងនោះទេ។ ក្តីបារម្ភមួយចំនួនមានដូចជា ការមើលថែមិនគ្រប់គ្រាន់ អស្ថិរភាពសេដ្ឋកិច្ច មិនទទួលបានតម្រូវការមូលដ្ឋាន កង្វះអាហារូបត្ថម្ភ ភាពតានតឹងផ្លូវចិត្ត ការអភិវឌ្ឍន៍សង្គម ការកើនឡើងហានិភ័យនៃការប្រើប្រាស់គ្រឿងញៀន ការកើនឡើងហានិភ័យនៃការមិនយកចិត្តទុកដាក់ ការរំលោភបំពានរាងកាយ បៀតបៀនផ្លូវភេទ ការរើសអើង និងពលកម្មកុមារ។
- ហានិភ័យបន្ថែមចំពោះកុមារនៅក្នុងប្រទេសថៃ រួមមាន ហានិភ័យក្នុងអំឡុងពេលធ្វើដំណើរ ចំពោះការកេងប្រវ័ញ្ចដោយបំពាន និងការជួញដូរ ការបំបែកចេញពីគ្រួសារ ពលកម្មកុមារ ការឃុំខ្លួន ការកេងប្រវ័ញ្ចផ្លូវភេទ និងការបៀតបៀន ការរើសអើង និងការមើលថែមិនគ្រប់គ្រាន់។ ឧបសគ្គភាសា និងកង្វះឯកសារផ្លូវច្បាប់ អាចបណ្តាលឱ្យមានភាពស្មុគស្មាញដល់បញ្ហាទាំងនេះ ព្រមគ្នានឹងស្ថានភាពទេសន្តរប្រវេសន៍មិន
  ប្រក្រតី។ ហានិភ័យអាចមានភាពខុសគ្នាចំពោះក្មេងប្រុស និងក្មេងស្រី និងកុមារដែលមានពិការភាព។ ខណៈពេលដែលកុមារទាំងអស់ប្រឈមនឹងហានិភ័យ ក្មេងប្រុសទំនងជាជួបប្រទះនឹងការធ្វើការងារដោយបង្ខំ ហើយក្មេងស្រីទំនងជាជួបប្រទះការកេងប្រវ័ញ្ចផ្លូវភេទ ការរៀបការដោយបង្ខំ។ កុមារដែលមានពិការអាចប្រឈមមុខនឹងការមាក់ងាយ ការរើសអើង និងការធ្វើការងារដោយបង្ខំ។

- កុមារប្រឈមបញ្ហាក្នុងការទទួលបានការអប់រំ ការថែទាំសុខភាព និងសេវាផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា និងក្នុងប្រទេសថៃ។ នៅប្រទេសកម្ពុជា បញ្ហាប្រឈមគឺ ស្ថានភាពចម្ងាយផ្លូវដើម្បីទទួលសេវានានា (ការរកទទួលសេវា) ភាពក្រីក្រ កង្វះការកំណត់ជនគោលដៅនៃសេវាផ្សេងៗជាពិសេសកុមារដែលរងប៉ះពាល់ដោយទេសន្តរប្រវេសន៍។ នៅប្រទេសថៃវិញ ទោះបីការអប់រំ និងសុខភាពមានភាពស្របច្បាប់ក្តី ក៏ក្រុមគ្រួសារមានការភ័យខ្លាចក្នុងការចូលប្រើសេវា ដោយសារខ្វះឯកសារ ឬខ្វះព័ត៌មានអំពីរបៀបចូលប្រើ ឬមានឧបសគ្គភាសា។ កុមារដែលមានពិការភាពស្ថិតក្នុងចំណោមជនងាយរងគ្រោះខ្លាំងជាងគេបំផុត។
- កុមារទាំងឡាយដែលមានស្ថានភាពទេសន្តរប្រវេសន៍មិនប្រក្រតី [2] រងហានិភ័យកាន់តែខ្លាំង និងលទ្ធភាពតិចក្នុងទទួលបានសេវា។
- ក្របខ័ណ្ឌច្បាប់អន្តរជាតិ ក៏ដូចជាថ្នាក់ជាតិ បានចែងច្បាស់ថា កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ មានសិទ្ធិដូចៗគ្នា គឺពួកគេមានសិទ្ធិទទួលបានការការពារដូចគ្នាទៅនឹងកុមារទាំងអស់។ គោលការណ៍ឧត្តមប្រយោជន៍កុមារត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងការប្តេជ្ញាចិត្តជាច្រើន។ ប៉ុន្តែទោះបីក្របខ័ណ្ឌច្បាប់នៅថ្នាក់តំបន់ និងថ្នាក់ជាតិ រួមបញ្ចូលបទដ្ឋាន "ឧត្តមប្រយោជន៍កុមារ"ក្តី ក៏គេនៅមិនមាននីតិវិធីគ្រប់គ្រាន់សម្រាប់អនុវត្តឧត្តមប្រយោជន៍នេះទេ។
- កុមារត្រូវបានបញ្ចូលក្នុងច្បាប់ការពារកុមារនៅក្នុងប្រទេសថៃ ហើយមានសិទ្ធិទទួលបានការអប់រំ ការថែទាំសុខភាព ឯកសារផ្លូវច្បាប់ ប៉ុន្តែឧបសគ្គនៅតែមានក្នុងពេលអនុវត្ត។ បញ្ហាភាសា កង្វះចំណេះដឹង និងភាពភ័យខ្លាចនៃការនិរទេស ក៏ស្ថិតក្នុងចំណោមឧបសគ្គនានាដែរ។
- ខណៈដែលការឃុំខ្លួនកុមារមិនត្រូវបានហាមឃាត់ដោយច្បាប់ថៃ ប្រទេសថៃបានប្តេជ្ញាកាត់បន្ថយការឃុំខ្លួនកុមារ។ ក៏ប៉ុន្តែកុមារកម្ពុជាដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃជារឿយៗនៅតែត្រូវបានឃុំខ្លួន ឬជាប់នៅមណ្ឌលថែទាំជំនួសរយៈពេលយូរ។
- កង្វះនីតិវិធីជាប់លាប់ និងច្បាស់លាស់ សម្រាប់ជាដំណោះស្រាយឆ្លើយតបបញ្ហាកុមារ ឬខ្វះកិច្ចសហប្រតិបត្តិការចំពោះកុមារ ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ ក៏រួមចំណែកនាំឱ្យមានបញ្ហានេះផងដែរ។ គេយកស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ទាក់ទងនឹងការគ្រប់គ្រងករណីនៃការជួញដូរមនុស្សមកប្រើ ប៉ុន្តែ SOPs ទាំងនេះមិនឆ្លើយតបបានគ្រប់គ្រាន់ចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នោះទេ។
- តួអង្គសំខាន់ៗសម្រាប់ការងារវិលត្រឡប់ និងការធ្វើមាតុភូមិនិវត្តន៍ ដល់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ មានដូចជា ប៉ូលីស ស្ថាប័នអន្តោប្រវេសន៍ ផ្នែកសុខុមាលភាពសង្គម បុគ្គលិកផ្តល់សេវាគាំពារកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ទាំងក្នុងប្រទេសថៃ និងប្រទេសកម្ពុជា។ បន្ថែមពីនេះទៀត នៅមានមជ្ឈមណ្ឌលសំចតក្រុងប៉ោយប៉ែត មជ្ឈមណ្ឌលទទួលពលករទេសន្តរប្រវេសន៍ដែលដើរតួសំខាន់ៗ។ ប៉ុន្តែ មិនមាននីតិវិធីច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវសម្រាប់តួអង្គសំខាន់ៗនីមួយៗនេះទេ។

---

[2] Irregular migration/irregular status: Movement of persons that takes place outside the laws, regulations, or international agreements governing the entry into or exit from the State of origin, transit or destination. Definition accessed at[Key Migration Terms, Migration Glossary | IOM, UN Migration].

- ប្រព័ន្ធគ្រប់គ្រងករណីការពារកុមាររបស់ប្រទេសកម្ពុជា ផ្តោតតែលើកុមារដែលទុកនៅសហគមន៍ ឬកុមារដែលវិលត្រឡប់មកវិញប៉ុណ្ណោះ។ ប្រព័ន្ធបច្ចុប្បន្នមិនមានដំណើរការ ឬប្រមូលទិន្នន័យបានគ្រប់គ្រាន់ ដែលអាចបំបែកទិន្នន័យទាំងនេះ ដើម្បីយល់ឱ្យច្បាស់ និងឆ្លើយតបដោយប្រសិទ្ធភាព ចំពោះស្ថានភាពរបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។
- ពេលកុមារវិលត្រឡប់មកវិញដោយខ្លួនឯង ពួកគេត្រូវការសេវាការពារ ដែលជាញឹកញាប់ កុមារត្រូវបានខកខានបញ្ចូលក្នុងប្រព័ន្ធ ប្រសិនបើពួកគេមិនត្រូវបានកំណត់អត្តសញ្ញាណនៅតាមសហគមន៍ ដោយអជ្ញាធរមូលដ្ឋានដែលបញ្ជូនកុមារទៅរកសេវាការពារ។

# អនុសាសន៍

## ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

### រដ្ឋាភិបាលប្រទេសថៃ និងប្រទេសកម្ពុជា

បង្កើត**អនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយប្រទេសថៃ ស្តីពីការឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍** ដែលបំពេញ ជំរុញនិងការពារសិទ្ធិ រួមមានការធានាក្នុងការទទួលបានសេវាសម្រាប់កុមារកម្ពុជានៅក្នុងប្រទេសថៃដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។

- អនុស្សរណៈនៃការយោគយល់គ្នា (MOU)ត្រូវដោះស្រាយផ្នែកសំខាន់ៗក្នុងការធានាឱ្យទទួលបានសេវាផ្សេងៗក្នុងប្រទេសថៃ ដោយបញ្ជាក់ឡើងវិញពីសិទ្ធិកុមារនៅប្រទេសថៃ ស្តីពីឯកសារស្របច្បាប់ សេវាអប់រំ សេវាថែទាំសុខភាព សេវាច្បាប់ សេវាផ្លូវចិត្តសង្គមនិងកិច្ចការពារទាក់ទងនិងហិង្សា ការកេងប្រវ័ញ្ច និងការទុកកុមារចោល ដោយផ្តល់អាទិភាពការចែករំលែកពត៌មាន និងដកចេញឧបសគ្គនានាក្នុងប្រទេសថៃ។
- អនុស្សរណៈនៃការយោគយល់គ្នា (MOU)ត្រូវកំណត់ដំណើរការធ្វើមាតុភូមិនិវត្តន៍ ដូចជា ស្វែងរកអត្តសញ្ញាណ តាមដានប្រវត្តិគ្រួសារ ការវាយតម្លៃ ការផ្ទៀងផ្ទាត់សញ្ជាតិ ការកំណត់ឧត្តមប្រយោជន៍ និងការផ្តល់សេវា រួមជាមួយនីតិវិធីធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញ។
- ត្រូវផ្តល់ឱកាសដល់កុមារ (ស្របតាមអាយុ) ដើម្បីទទួលបានទស្សនៈរបស់ពួកគេ សម្រាប់ការសម្រេចចិត្តណាមួយ។
- កិច្ចព្រមព្រៀងនេះក៏ត្រូវបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តចំពោះជម្រើសផ្សេងទៀតក្នុងការឃុំខ្លួនកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ។ គេគួរដាក់បញ្ចូលក្របខ័ណ្ឌពេលវេលាផងដែរ។

បង្កើតគំរូឆ្លងព្រំដែនទូលំទូលាយសម្រាប់ការវិលត្រឡប់មកវិញ និងការធ្វើសមាហរណកម្មកុមារ រួមជាមួយ**ស្តង់ដារនីតិវិធីប្រតិបត្តិការ រវាងប្រទេសកម្ពុជា និងប្រទេសថៃ សម្រាប់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍** ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ជាពិសេស ស្របគោលការណ៍ឧត្តមប្រយោជន៍កុមារ។ ទោះបីអនុស្សរណៈនៃការយោគយល់គ្នា (MOU) និងស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) មានភាពពាក់ព័ន្ធ ទៅនឹងការប្រឆាំងការជួញដូរក្តី ក៏ឧបករណ៍ទាំងពីរនេះមិនឆ្លើយតបឱ្យបានគ្រប់គ្រាន់ចំពោះបញ្ហាកុមារដែលរងផលប៉ះ

ពាល់ដោយទេសន្តរប្រវេសន៍នោះទេ។ គេចាំបាច់ត្រូវញែកដំណើរការ តែត្រូវភ្ជាប់នឹងដំណើរការថ្មី។ ផ្នែកសំខាន់ៗមួយចំនួនសម្រាប់ដាក់បញ្ចូលរួមមាន៖

- បញ្ជាក់តួនាទី និងកំណត់ទំនួលខុសត្រូវរបស់តួអង្គសំខាន់ៗ (ផ្នែកអន្តោប្រវេសន៍ កិច្ចការពារកុមារ សុខុមាលភាពសង្គម ស្ថានទូត អង្គការក្រៅរដ្ឋាភិបាល) ក្នុងប្រទេសថៃ និងប្រទេសកម្ពុជា ក្នុងវិស័យសំខាន់ៗដូចបានរៀបរាប់ខាងលើ។ គំរូនេះគួររួមបញ្ចូលយន្តការទំនាក់ទំនងឆ្លងព្រំដែន កិច្ចសហប្រតិបត្តិការ និងការបញ្ជូនបន្ត ដើម្បីសម្រួលដល់កិច្ចការពារ ការផ្តល់សេវា ការបញ្ជូនត្រឡប់មកវិញ និងករណីធ្វើសមាហរណកម្មឡើងវិញ។
- ស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ត្រូវដោះស្រាយបញ្ហា ដូចជាការវាយតម្លៃកភាពងាយរងគ្រោះដោយកត្តាយេនឌ័រ ស្ថានភាពពិការ និងហានិភ័យ និងភាពងាយរងគ្រោះផ្សេងៗ។ កុមារដែលត្រូវបានបញ្ជូនមកវិញ ត្រូវទទួលបានការគាំទ្រ និងត្រូវផ្ទេរតាមរយៈបុគ្គលិកសុខុមាលភាពសង្គម ជំនួសឱ្យការ "ប្រគល់" ទៅកាន់មន្ត្រីប្រចាំការព្រំដែន។

**ផ្តល់ឱកាសដល់កុមារចូលរួមក្នុងដំណើរការបង្កើតគោលនយោបាយ** ដើម្បីធានាបាននូវទស្សនៈ និងផលប្រយោជន៍របស់កុមារ ដោយទស្សនៈនេះត្រូវបានស្តាប់ ហើយពិចារណា។

បង្កើត**គោលការណ៍ណែនាំជាក់ស្តែងមួយ ដើម្បីអនុវត្តវាយតម្លៃ និងកំណត់ឧត្តមប្រយោជន៍កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍** (សម្រាប់កុមារក្នុងអំឡុងពេលធ្វើដំណើរ និងត្រឡប់មកវិញ និងកុមារដែលទុកនៅសហគមន៍) សម្រាប់បុគ្គលិក និងអ្នកឯកទេសផ្តល់សេវាផ្សេងៗនៅក្នុងប្រទេសទាំងពីរ ដែលទទួលបន្ទុកដោះស្រាយបញ្ហាកុមារទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ។ ដំណើរការនេះត្រូវធានាជាតុចូលពីកុមារ និងគោរពចំពោះភ្នាក់ងារតំណាងកុមារដែលមានអាយុច្រើនជាងក្នុងការទទួលស្គាល់នៃវឌ្ឍភាពសមត្ថភាព។

បង្កើត**កិច្ចព្រមព្រៀងលើដំណើរការបញ្ជាក់អត្តសញ្ញាណកុមារ** រួមមានការតាមស្វែងរកគ្រួសារ និងដំណើរការផ្សេងៗទៀត ដើម្បីធានាថា កុមារមានសិទ្ធិទទួលបានអត្តសញ្ញាណជាតិ និងសិទ្ធិនានាដែលភ្ជាប់មកជាមួយអត្តសញ្ញាណនេះ។

**ផ្តល់សេវាផ្នែកច្បាប់ដល់កុមារដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ**។ កុមារដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ដោយ**មិនស្ម័គ្រចិត្ត ឬមានជម្លោះផ្នែកច្បាប់ ពួកគេមានសិទ្ធិទទួលបានសេវាច្បាប់ដែលរួមមានការទទួលបានសេវាផ្លូវច្បាប់ផ្សេងៗ សេវាសុខមាលភាពសង្គម និងមានសិទ្ធិប្តឹងឧទ្ធរណ៍**។ ការបំបែកកុមារពីឪពុកម្តាយ ឬសមាជិកគ្រួសារផ្សេងទៀត ត្រូវជៀសវាង លុះត្រាតែការរួមដំណើរជាមួយគ្នានេះ ធ្វើឱ្យកុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។ កុមារមិនគួរត្រូវបានដកហូតសេរីភាព ហើយត្រូវឃុំខ្លួនឡើយ។

ផ្តល់សិទ្ធិទទួលបាន**ការបកប្រែភាសា**តាមតម្រូវការសម្រាប់កុមារ ស្ថិតក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍ និងត្រឡប់ទៅប្រទេសកម្ពុជាវិញ។

### ប្រទេសកម្ពុជា

**ពិនិត្យឡើងវិញគោលនយោបាយដែលមានស្រាប់ទាក់ទងនឹងពលករទេសន្តរប្រវេសន៍** ដូចជាគោលនយោបាយទេសន្តរប្រវេសន៍ការងារដើម្បីធានាថា គោលនយោបាយទាំងនេះឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ បញ្ចូលសំឡេងរបស់កុមារ ក្នុងការបង្កើតគោលនយោបាយ ដើម្បីធានាថា តម្រូវការ និងសិទ្ធិជាក់លាក់របស់ពួកគេ ត្រូវបានចាត់ទុក ជាអាទិភាព។ ចំណុចនេះអាចកើតឡើងតាមរយៈការពិគ្រោះយោបល់ ឬការស្រាវជ្រាវ។

ជានាថា **ផែនការអភិវឌ្ឍន៍ភូមិឃុំត្រូវបញ្ចូលសកម្មភាពចំណេះដឹងអំពីទេសន្តរប្រវេសន៍** នៅថ្នាក់មូលដ្ឋានដែលអាចនាំទៅដល់ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព។

## ការបន្តសេវាដល់កុមារ និងគ្រួសារ

**ផ្តល់ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងមុនពេលចេញដំណើរដល់ឪពុកម្តាយ អាណាព្យាបាល និងកុមារ** មកពីក្រុមគ្រួសារជនទេសន្តរប្រវេសន៍អំពីរបៀបគាំទ្រ និងកិច្ចការពារកុមារដែលទុកនៅសហគមន៍ និងដើម្បីធានាថាកុមារដែលធ្វើដំណើរជាមួយឪពុកម្តាយរបស់ពួកគេ ត្រូវទទួលបានកិច្ចការពារ។ ត្រូវធានាថា ព័ត៌មានសេវាទាំងឡាយដែល អាចរកបានត្រូវមានសម្រាប់កុមារដែលមានពិការ ដើម្បីដោះស្រាយភាពខុសគ្នានៃយេនឌ័រ និងហានិភ័យ។

**ត្រូវធានាថាកម្មវិធីចិញ្ចឹមកូនៗដោយវិជ្ជមាន** ត្រូវបង្កើតឡើងសម្រាប់អ្នកមើលថែកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ដើម្បីជានាលើកកម្ពស់ការចិញ្ចឹមបីបាច់ពួកគេដោយវិជ្ជមាន និងការអនុវត្តការថែទាំ ក្នុងគោលបំណងជួយកែលម្អសុខុមាលភាពរបស់កុមារ និងទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ។

**លើកកម្ពស់បណ្តាញមិត្តអប់រំមិត្ត និងយន្តការផ្សេងទៀតសម្រាប់គាំទ្រគ្នាទៅវិញទៅមក ដល់កុមារ**ដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ទាំងនៅក្នុងប្រទេសថៃ និងនៅក្នុងប្រទេសកម្ពុជា។

ត្រូវជានាថា **ព័ត៌មានសមស្របតាមអាយុកុមារ** ត្រូវបានផ្សព្វផ្សាយដល់កុមារក្នុងទម្រង់ងាយយល់ ព្រមទាំងសិទ្ធិស្របច្បាប់របស់ពួកគេផងដែរ។

បង្កើន**កិច្ចខិតខំប្រឹងប្រែង ដើម្បីឱ្យដល់កុមារនៅប្រទេសថៃ ដើម្បីដោះស្រាយហានិភ័យ ដូចជាកត្តាយេនឌ័រ ពលកម្មកុមារ និងការជួញដូរកុមារជាដើម។** ឧទាហរណ៍ ការកំណត់គោលដៅលើកិច្ចខិតខំប្រឹងប្រែងនៅក្នុងសហគមន៍ដែលមានពលករទេសន្តរប្រវេសន៍រស់នៅ ឬចំណោមមនុស្សជាច្រើនបានចេញពីស្រុក ឬត្រឡប់មក វិញ។ បញ្ចូលប្រធានបទដូចជាវិធីទទួលបានការអប់រំ ការថែទាំសុខភាព និងការទទួលបានឯកសារផ្លូវច្បាប់។

ប្រើប្រាស់**បច្ចេកវិទ្យាដើម្បីជួយឪពុកម្តាយទេសន្តរប្រវេសន៍ទាក់ទងជាមួយកូនៗ និងក្រុមគ្រួសាររបស់ពួកគេ។** ការបញ្ចុះតម្លៃទូរគមនាគមន៍ ដោយសម្របសម្រួលការរកចូលប្រើសេវាអ៊ិនធើណែត និងដកចេញឧបសគ្គប

ច្ចេកវិទ្យាដែលពាក់ព័ន្ធ អាចជួយឱ្យជនទេសន្តរប្រវេសន៍ភ្ជាប់ទំនាក់ទំនងកាន់តែញឹកញាប់ជាមួយកូនៗរបស់ពួកគេ (ផ្សារភ្ជាប់ជាមួយវិស័យឯកជន)។

ត្រូវធានាថា មាន**កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ** ដែលពលករទេសន្តរប្រវេសន៍ និងកូនរបស់ពួកគេអាចចូលទៅប្រើបានដោយងាយស្រួល។

## ការគ្រប់គ្រងករណី

ដោយទទួលស្គាល់ពីសារៈសំខាន់ប្រព័ន្ធការពារកុមារនៅតាមច្រកព្រំដែន ដើម្បីឆ្លើយតបដោះស្រាយបញ្ហាកុមារដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍ទៅប្រទេសថៃ ទើបគេចាំបាច់ត្រូវ**ធ្វើបច្ចុប្បន្នភាពស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ប្រព័ន្ធការពារកុមារ និងប្រព័ន្ធគ្រប់គ្រងករណី ដើម្បីធានាថា ប្រព័ន្ធទាំងនេះ រួមបញ្ចូលតួនាទីកិច្ចការពារកុមារកម្ពុជា។** បច្ចុប្បន្ន ស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs)[3] ផ្តល់ដំណោះស្រាយតែកុមារដែលបានត្រឡប់មកវិញ ឬកុមារដែលទុកនៅសហគមន៍ប៉ុណ្ណោះ។ គេត្រូវកំណត់ឱ្យបានច្បាស់នូវតួនាទី និងទំនួលខុសត្រូវរបស់ផ្នែកទទួលបន្ទុកកិច្ចការពារកុមារកម្ពុជា ដោយផ្សារភ្ជាប់ទៅនឹងគំរូថ្មីនៃការឆ្លើបតបបញ្ហាឆ្លងកាត់ច្រកព្រំដែន ហើយថាតើរបៀបគ្រប់គ្រងប្រព័ន្ធទាំងនេះ ជាពិសេស របៀបវាយតម្លៃកុមាររកមើលភាពងាយរងគ្រោះ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍ ប្រព្រឹត្តទៅយ៉ាងដូចម្តេច។

**ពង្រីកប្រភេទក្រុមកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ក្នុងប្រព័ន្ធ** *Primero CPIMS+* ៖ គ្មានព័ត៌មានលម្អិតគ្រប់គ្រាន់ពីប្រភេទ (categories) ក្រុមដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ ប្រភេទនេះអាចត្រូវបានពង្រីក ដើម្បីបញ្ចូលប្រភេទកុមារ ដូចជា ១)កុមារដែលទុកនៅស្រុកកំណើត (តែឪពុក ឬតែម្តាយ ឬ ទាំងពីរកំពុងធ្វើទេសន្តរប្រវេសន៍) ២)កុមារដែលវិលត្រឡប់ (វិលត្រឡប់មកពីទេសន្តរប្រវេសន៍ដោយស្ម័គ្រចិត្ត កុមារដែលបានត្រឡប់មកវិញដោយមិនស្ម័គ្រចិត្ត កុមារបំបែកពីគ្រួសារ កុមារគ្មានអ្នកអមដំណើរជាមួយ ៣) កុមារជាកូនជនចំណាកស្រុកក្រៅប្រទេស (ឆ្លងដែន) និង ៤)កុមារជាកូនរបស់ជនចំណាកស្រុកក្នុងប្រទេស។ ចំណុចនេះត្រូវបញ្ជាក់ឱ្យបានច្បាស់ក្នុងស្តង់ដារនីតិវិធីប្រតិបត្តិ (SOPS)។ និយមន័យបែបអន្តរជាតិគឺមាននៅដើមដំបូងនៃរបាយការណ៍នេះដែលក្នុងផ្នែក
និយមន័យ។

ការប្រមូលផ្តុំព័ត៌មានអំពីអ្នកមើលថៃ ជាមួយនឹងស្ថានភាពរស់នៅបច្ចុប្បន្ន គេនឹងទទួលបានព័ត៌មានលម្អិតបន្ថែមអំពីស្ថានភាពរបស់កុមារ។ លើសពីនេះ ការបំបែកទិន្នន័យ (តាមរយៈការរាយការណ៍) ពីប្រព័ន្ធ *Primero* អាចត្រូវបានស្រាវជ្រាវដើម្បីធានាថា ទិន្នន័យដែលប្រមូលបាន ត្រូវបានយកទៅវិភាគ ដោយប្រើទិន្នន័យដែលបានមកពី ដូចជា អ្នកមើលថៃកុមារ ស្ថានភាពពិការ និងពីអ្នកផ្សេងៗទៀត។

[3] MoSVY (2023) *Guidebook on Child Protection Operation Procedures for Municipal, district and Khan Administration.*

**កម្លាំងការងារសេវាសង្គម៖** ការមានកម្លាំងការងារសេវាសង្គម ដែលទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ ផ្តល់សារៈសំខាន់យ៉ាងខ្លាំងក្នុងការធានានូវគុណភាពដល់ការគ្រប់គ្រងករណី។ បន្ថែមលើការបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារ និងការគ្រប់គ្រងករណី បុគ្គលិកសង្គមកិច្ច តម្រូវឱ្យមានការបណ្តុះបណ្តាលស្តីពីស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs)កត្តាជំរុញផ្សេងៗ និងផលប៉ះពាល់ពីទេសន្តប្រវេសន៍មកលើកុមារ ហើយធានាថា ការចូលរួមរបស់កុមារគឺជាការចូលរួមចំណែកក្នុងការសម្រេចចិត្តណាមួយសម្រាប់ពួកគេ។

## ទិន្នន័យ និងការស្រាវជ្រាវ

ទោះបីទិន្នន័យនៅមានកម្រិតក្តី ក៏ក្រសួងផ្សេងៗ មានទិន្នន័យដែលជួយដល់ការយល់ដឹងបានខ្លះៗ។ គេគួរបង្កើតផែនទី និងកំណត់ទិន្នន័យរបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ហើយប្រើវាដើម្បីស្វែងយល់អំពីទិន្នន័យដែលមានស្រាប់ និងរកមើលចន្លោះប្រហោង។ គេអាចធ្វើវាបានឥឡូវ ដើម្បីផ្តល់ការយល់ដឹងឱ្យកាន់តែច្បាស់អំពីប្រព័ន្ធនេះ។

ផ្តល់ការគាំទ្របន្ថែមដល់ការសិក្សា ដើម្បីយល់កាន់តែច្បាស់អំពីស្ថានភាពរបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍ – កុមារដែលទុកនៅស្រុកកំណើត ទីកន្លែងសំចត និងស្ថិតក្នុងប្រទេសថៃ។ ចំណុចនេះរួមបញ្ចូលទាំងការគាំទ្រការស្រាវជ្រាវ និងប្រព័ន្ធកែលម្អលើកិច្ចការប្រមូលទិន្នន័យនិងការចែករំលែកព័ត៌មាន។

# សេចក្តីផ្តើម

"កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍" គឺជាកន្សោមពាក្យទូលំទូលាយ រួមមានកុមារ (អាយុក្រោម ១៨ ឆ្នាំ) ដែលកំពុងផ្លាស់ទី ឬបានផ្លាស់ទីលំនៅ ចាកចេញពីប្រទេសដើមរបស់ខ្លួន ឬឆ្លងកាត់ច្រកព្រំដែន ចូលទៅកាន់ប្រទេសមួយផ្សេងទៀត ទាំងបណ្តោះអាសន្នក្តី ឬអចិន្ត្រៃយ៍ក្តី។ ចំណុចនេះរាប់បញ្ចូលទាំងកុមារដែលធ្វើទេសន្តរប្រវេសន៍ដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត (ការផ្លាស់ទីលំនៅដោយបង្ខំកើតឡើង ដោយគ្រោះមហន្តរាយធម្មជាតិ ឬសង្គ្រាម) ឬដោយហេតុផលសេដ្ឋកិច្ច សង្គម ការអប់រំ ឬវប្បធម៌។ នេះរាប់បញ្ចូលទាំងកុមារធ្វើដំណើរតែឯង ឬធ្វើដំណើរជាមួយឪពុកម្តាយ ហើយក៏រាប់បញ្ចូលកុមារដែលឪពុកម្តាយម្នាក់ ឬទាំងពីរនាក់ ទុកពួកគេនៅឯស្រុកកំណើត ដោយការធ្វើចំណាកស្រុក (កុមារទុកនៅស្រុកកំណើត)[4]។

នៅប្រទេសកម្ពុជា ក៏ដូចជាប្រទេសជិតខាង កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍កើតឡើងនៅពេលឪពុកម្តាយទេសន្តរប្រវេសន៍ម្នាក់ ឬទាំងពីរនាក់ ទុកកុមារនៅស្រុកកំណើត កុមាររួមដំណើរជាមួយឪពុកម្តាយ (ឬកុមារកើតនៅបរទេស) ឬកុមារធ្វើដំណើរតែម្នាក់ឯង។ ប្រទេសកម្ពុជាគឺជាជម្រកដល់ក្រុមកុមារជាច្រើនដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍- ទាំងក្នុងប្រទេស និងឆ្លងច្រកព្រំដែន - អំឡុងពេលក្រុមគ្រួសារ និងកុមារស្វែងរកឱកាសសេដ្ឋកិច្ចកាន់តែប្រសើរ។

ទោះបីការស្រាវជ្រាវនៅប្រទេសកម្ពុជា បានពិនិត្យលើជនទេសន្តរប្រវេសន៍ពេញវ័យ និងផលប៉ះពាល់ក៏ដោយ ក៏ចំណាប់អារម្មណ៍ និងបទពិសោធន៍ជាក់លាក់របស់ជនទេសន្តរប្រវេសន៍ជាកុមារ ទទួលបានការចាប់អារម្មណ៍តិចតួច។ ទិន្នន័យ និងការយល់ដឹងនៅមានកម្រិត ទាក់ទងនឹងកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើលំនាំទេសន្តរប្រវេសន៍របស់កុមារ ឬរបៀបដែលគោលនយោបាយទេសន្តរប្រវេសន៍ជាក់លាក់ប៉ះពាល់ដល់អនីតិជន។ ការសិក្សាដែលមានស្រាប់ បានផ្តោតជាចម្បងលើបទពិសោធន៍ និងផលប៉ះពាល់ជនទេសន្តរប្រវេសន៍ពេញវ័យ តែនៅខ្វះទស្សនៈទានចំពោះជនទេសន្តរប្រវេសន៍ជាកុមារ។

គេត្រូវការស្រាវជ្រាវ និងការវាយតម្លៃបន្ថែមទៀត ដើម្បីស្វែងយល់ពីបទពិសោធន៍នៃការយល់ឃើញអំពីស្ថានភាពឆ្លងព្រំដែនរបស់កុមារកម្ពុជាដែលរស់ក្នុងប្រទេសថៃ រួមទាំងការឆ្លងកាត់ច្រកទ្វារ និងការទទួលបានសេវាទាំងសងខាង (កម្ពុជានិងថៃ)។

ការសិក្សាស្រាវជ្រាវរបស់អង្គការយូនីសេហ្វ អំពីកុមារក្នុងបរិបទទេសន្តរប្រវេសន៍ តាមរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)-[5] ករណីសិក្សានៅកម្ពុជា[6] រកឃើញថា ការធ្វើទេសន្តរប្រវេសន៍របស់ឪពុកម្តាយនៅក្នុងប្រទេសកម្ពុជា ជាញឹកញាប់ ធ្វើឱ្យកុមារប្រឈមបញ្ហាជាច្រើន ដោយទុកពួកគេចោលនៅស្រុកកំណើត ហើយកុមារទាំងនេះងាយរងហានិភ័យនៃកិច្ចគាំពារផ្សេងៗ។ ការសិក្សាបានផ្តល់អនុសាសន៍ដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) ក្នុងកិច្ចការពារកុមារទេសន្តរប្រវេសន៍ឱ្យ

[4] UNICEF Migration Country brief Thailand.pdf
[5] https://www.unicef.org/eap/reports/regional-situation-analysis-children-affected-migration-asean-member-states
[6] https://www.unicef.org/eap/media/13426/file/ASEAN%20CABM%20Cambodia.pdf

មានភាពកាន់តែប្រសើរឡើង រួមទាំងពង្រឹងដំណើរការគ្រប់គ្រងករណី និងធានាឱ្យមានសេវាទូលំទូលាយ អាចរកបាននៅតាមមូលដ្ឋាន ដើម្បីបំពេញតម្រូវការដល់កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ អនុសាសន៍បន្ថែម រួមមានការដាក់ជាក្រុមកុមារដែលត្រូវបានទុកចោលនៅស្រុកកំណើត ទុកជាក្រុមដាច់ដោយឡែក នៅក្នុងប្រព័ន្ធគ្រប់គ្រងករណីការពារកុមារ ក្នុងប្រព័ន្ធព្រីម៉េរ៉ូ *(Primero)* របស់ ស.អ.យ និងពង្រឹងសេវា ដោយផ្តោតចំពោះកុមារទាំងនេះ រួមទាំងគ្រួសាររបស់ពួកគេ។

ដោយមើលឃើញភាពស្មុគស្មាញនៃក្តីបារម្ភមានកាន់តែខ្លាំងឡើង ចំពោះកិច្ចការពារកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ជាពិសេស ក្នុងករណីឆ្លងកាត់ច្រកទ្វារ រាជរដ្ឋាភិបាលកម្ពុជាត្រូវពង្រឹងដំណើរការគ្រប់គ្រងករណី និងពង្រីកកិច្ចសហប្រតិបត្តិការ នៅតាមច្រកទ្វារជាមួយរាជរដ្ឋាភិបាលប្រទេសថៃ។ កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ នឹងជួយប្រយុទ្ធប្រឆាំងការជួញដូរស្ត្រី និងកុមារឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការដោះស្រាយប្រភេទកុមារ រងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ មានដូចជា កុមារដែលត្រឡប់មក ប្រទេសដើមវិញ បន្ទាប់ពីទេសន្តរប្រវេសន៍របស់ខ្លួន និងកុមារដែលឪពុកម្តាយទុកនៅឯសហគមន៍។

គេចាំបាច់ត្រូវស្វែងយល់ផងដែរ អំពីដំណើរការបញ្ជូនកុមារកម្ពុជា ដោយភាគីថៃ ដើម្បីកំណត់ថាតើដំណើរការ ទាំងនេះស្របតាមស្តង់ដារទទួលជនទេសន្តរប្រវេសន៍នៅកម្ពុជា និងគោលការណ៍របស់អនុសញ្ញាស្តីពីសិទ្ធិកុមារ *(CRC)* ដែរឬទេ។ គេគួរវាយតម្លៃទៅលើកុមារដែលធ្លាប់ត្រូវបានបញ្ជូនមកប្រទេសដើមវិញ ដើម្បីរកមើលថាតើពិធីសាររវាងប្រទេស និងប្រទេស បានផ្តល់កិច្ចការពារគ្រប់គ្រាន់ដល់ក្រុមកុមារដែលងាយរងគ្រោះទាំងនេះដែរឬទេ។

## គោលបំណង

ការស្រាវជ្រាវនេះមាន**គោលបំណងរួមគឺ** បង្កើតឯកសារចំណេះដឹងស្តីពីបទពិសោធន៍របស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នៅក្នុងប្រទេសកម្ពុជា ដោយផ្តោតលើសកម្មភាពបន្លាស់ទីឆ្លងចព្រំដែនជាប់ប្រទេសថៃ។

**គោលបំណងជាក់លាក់មាន៖**

- ស្វែងយល់ពីបទពិសោធន៍របស់កុមារកម្ពុជានៅក្នុងប្រទេសថៃ ក្នុងស្ថានភាពឆ្លងព្រំដែន រួមមានបទពិសោធន៍ឆ្លងច្រកទ្វារ និងការទទួលបានសេវាទាំងសងខាង និងវិធីដែលបទពិសោធន៍ទាំងនេះត្រូវបានអនុវត្តដោយក្របខ័ណ្ឌគោលនយោបាយ ដំណើរការ និងយន្តការជាធរមាន ទាំងនៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជា។
- **ផ្តល់ទិដ្ឋភាពទូទៅអំពីវិធីដែលប្រព័ន្ធការពារកុមារ ដំណើរការគ្រប់គ្រងករណី** *Primero* បច្ចុប្បន្ន កំណត់ដំណើរការមាតុភូមិនិវត្តន៍ ឬការនិរទេស ហើយថាដំណើរការទាំងនេះ ផ្តល់ដំណោះស្រាយដល់ផលប្រយោជន៍ និងតម្រូវការគាំប្រសើរដល់កុមារដែលធ្លាប់ឆ្លងកាត់ស្ថានភាពឆ្លងច្រកទ្វារទាំងនេះដែរឬទេ។
- **ផ្តល់អនុសាសន៍ដល់វិធានកិច្ចការពារកុមារ** (ភាពអាចការពារបាន/ កិច្ចការពារ / ការធ្វើមាតុភូមិនិវត្តន៍ & សមាហរណកម្មឡើងវិញ) ដែលគួរត្រូវបានអនុម័តនៅក្នុងកិច្ចសហប្រតិបត្តិការឆ្លងព្រំដែន

- **ផ្តល់អនុសាសន៍ចំពោះសកម្មភាពសំខាន់ៗ ដើម្បីពង្រឹងការគ្រប់គ្រងករណី** *Primero* ជាធរមាន, ដើម្បីរួមបញ្ចូលប្រភេទក្រុមកុមារផ្សេងៗគ្នា ដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ និងកែលម្អស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) និងការអនុវត្តស្តង់ដារនេះ, ដើម្បីជួយកុមារដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ និងកុមារដែលទុកនៅស្រុកកំណើត ឬទុកនៅក្នុងសហគមន៍ ឱ្យមានភាពកាន់តែប្រសើរឡើង។

## សំណួរស្រាវជ្រាវ

- តើអ្វីជា**ក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្ន** (កិច្ចការពារ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញ) ដែលត្រូវអនុវត្តចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍រវាងប្រទេសកម្ពុជា និងប្រទេសថៃ? តើអ្វីទៅជាការប្តេជ្ញាចិត្តជាសកល តំបន់ និងទ្វេភាគីដែលត្រូវអនុវត្ត?
- តើ**ក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្នត្រូវបានអនុវត្ត**យ៉ាងដូចម្តេច? តើអ្វីជាការអនុវត្តជាក់ស្តែងនៃដំណើរការ និងយន្តការដែលត្រូវបានអនុវត្តចំពោះកុមារឆ្លងដែនទៅប្រទេសថៃក្នុងលក្ខខណ្ឌនៃការទទួលបានសេវា និងកិច្ចការពារ រួមទាំងដំណើរការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញ?

- **តើកុមារកម្ពុជានៅប្រទេសថៃយល់ឃើញអ្វីខ្លះអំពីបទពិសោធន៍?** (ក្នុងស្ថានភាពឆ្លងព្រំដែន រួមទាំងការឆ្លងកាត់ច្រកទ្វារ និងការទទួលបានសេវាទាំងសងខាង)។ តើអ្វីជាបញ្ហាប្រឈមដែលបានកើតឡើងក្នុងស្ថានភាពឆ្លងព្រំដែន រួមទាំងការឆ្លងកាត់ច្រកទ្វារ និងការទទួលសេវាទាំងពីរភាគី?

- **តើការអនុវត្តល្អអ្វីខ្លះ** (ជាសកល និងថ្នាក់តំបន់) ក្នុង**ការផ្តល់កិច្ចការពារ (កិច្ចការពារ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញ)** សម្រាប់កុមារដែលរងផលប៉ះពាល់ទេសន្តរប្រវេសន៍? តើអ្វីជាគោលការណ៍ និងសកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តតាម ដើម្បីការពារសិទ្ធិកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។

- **តើប្រព័ន្ធគ្រប់គ្រងករណីបច្ចុប្បន្ន** ត្រូវបានណែនាំដោយស្តង់ដារនីតិវិធីប្រតិបត្តិ( SOPs) ការពារកុមារ និង*CPS+ ម៉ូឌុល Primero* ដែលណែនាំដល់ដំណើរការគ្រប់គ្រងករណីពាក់ព័ន្ធនឹងកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ មានដំណើរការបានយ៉ាងដូចម្តេច?

- **តើអ្នកណាជាភាគីពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ** រួមទាំងអ្នកបង្កើតគោលនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ?

- **តើអនុសាសន៍សំខាន់ៗអ្វីខ្លះ ត្រូវដាក់បញ្ចូលទៅក្នុងអនុស្សរណៈនៃការយោគយល់គ្នា (MoU)ស្តីពីការឆ្លងព្រំដែន** ដើម្បីការពារកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍រវាងប្រទេសកម្ពុជា និងប្រទេសថៃ។

- **តើអនុសាសន៍អ្វីខ្លះប្រើសម្រាប់ការកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ** និងការអនុវត្តស្របតាមការអនុវត្តល្អជាសាកល និងការប្តេជ្ញាចិត្តដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ទាក់ទងនឹងកិច្ចការពារ ការធ្វើ

មាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញដល់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍រវាងប្រទេសថៃ និងប្រទេសកម្ពុជា ?

- **តើអនុសាសន៍អ្វីខ្លះសម្រាប់ការកែលម្អ ប្រព័ន្ធ** Primero ដែលជាឧបករណ៍គាំទ្រការគ្រប់គ្រងករណីមានករណីការពារកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ?

## វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្របង្កើតឯកសារចំណេះដឹងនេះ គឺជាការស្រាវជ្រាវបែបគុណភាព រួមបញ្ចូលការពិនិត្យឡើងវិញនូវឯកសារនានា ដូចជា ក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្ន ការស្រាវជ្រាវដែលមានស្រាប់ របាយការណ៍ពាក់ព័ន្ធនឹងកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ និងការប្រមូលទិន្នន័យសំខាន់ៗតាមរយៈការសម្ភាសន៍បុគ្គលសំខាន់ៗនិងការពិភាក្សាជាក្រុម ដើម្បីយល់កាន់តែច្បាស់អំពីស្ថានភាពបច្ចុប្បន្ន ហើយនិងការកំណត់អត្តសញ្ញាណតួអង្គសំខាន់ៗក្នុងការសិក្សានេះផងដែរ។

## ការពិនិត្យឯកសារស្រាវជ្រាវ

ការពិនិត្យឯកសារឡើងវិញ ធ្វើឡើងដើម្បីបង្កើតការយល់ដឹងអំពីក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្ន និងការអនុវត្តល្អប្រសើរនៃក្របខ័ណ្ឌនេះ និងដើម្បីចង្អុលបង្ហាញអ្នកពាក់ព័ន្ធសំខាន់ៗ។ លើសពីនេះ ការពិនិត្យឡើងវិញនេះ បានផ្តោតជាសំខាន់លើកការស្វែងរក និងកំណត់ឯកសារស្រាវជ្រាវដែលមានស្រាប់ ឬឯកសារផ្សេងៗទៀតស្តីពីស្ថានភាពកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍រវាងប្រទេសកម្ពុជា និងប្រទេសថៃ ការអនុវត្តគោលនយោបាយ នីតិវិធី និងការអនុវត្តផ្សេងៗ ដែលអនុវត្តចំពោះកុមារបរទេសដែលរស់នៅ ឬត្រឡប់មកពីប្រទេសថៃ។

នាយកដ្ឋានការពារកុមាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា *(MoSVY)* ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ បានអនុវត្តប្រព័ន្ធគ្រប់គ្រងករណី *Primero* នៅក្នុងប្រទេសកម្ពុជា។ ដើម្បីយល់កាន់តែច្បាស់អំពីរបៀបដែលកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ត្រូវបានចងក្រងជាឯកសារ និងឆ្លើយតបនៅក្នុងប្រទេសកម្ពុជា គេត្រូវពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រងករណី *Primero* និងស្តង់ដារគ្រប់គ្រងករណី ដើម្បីណែនាំផ្តល់អនុសាសន៍សម្រាប់ការកែលម្អដល់ការគាំទ្រប្រកបដោយសុវត្ថិភាព និងរលូន ដើម្បីឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ រួមទាំងការធ្វើមាតុភូមិនិវត្តន៍របស់កុមារពីប្រទេសថៃ និងកុមារ ដែលទុកនៅក្នុងសហគមន៍របស់ពួកគេ។

## ការប្រមូលទិន្នន័យបឋមនៅមូលដ្ឋាន

ការប្រមូលទិន្នន័យបឋមត្រូវបានធ្វើឡើងដើម្បីយល់កាន់តែច្បាស់អំពីរបៀបអនុវត្តកិច្ចការពារកុមារដែលមានស្រាប់ រួមទាំងក្របខ័ណ្ឌបទប្បញ្ញត្តិ និងដំណើរការគ្រប់គ្រងករណីដែលកំពុងត្រូវបានអនុវត្ត និងដើម្បីកំណត់ភាគីពាក់ព័ន្ធ និងសកម្មភាពសំខាន់ៗ។

**វិធីសាស្ត្រជ្រើសរើសសំណាកៈ** វិធីសាស្ត្រជ្រើសរើសសំណាកសម្រាប់ការប្រមូលទិន្នន័យបឋមមានគោលបំណងច្បាស់លាស់។ ទិន្នន័យត្រូវបានប្រមូលនៅថ្នាក់ជាតិ និងនៅខេត្តគោលដៅចំនួនពីរ គឺខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។ ខេត្តទាំងពីរនេះត្រូវបានជ្រើសរើស ព្រោះជាខេត្តជាប់ព្រំដែន ដែលកុមារអាចនឹងត្រូវធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃមកវិញ។ អ្នកផ្តល់ព័ត៌មានសំខាន់ៗត្រូវបានរាយបញ្ជីនៅក្នុងតារាងទី១។

**ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗៈ** វិធីសាស្ត្រចម្បងគឺត្រូវសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) ។ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) គឺជាការសម្ភាសន៍ដែលបានរៀបចំឡើង ដើម្បីសម្ភាសន៍ជាមួយបុគ្គលណាម្នាក់ដែលមានជំនាញ ឬបទពិសោធន៍ជាក់លាក់ទៅតាមវិស័យនីមួយៗ។ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ និងខេត្តគោលដៅចំនួនពីរ គឺបន្ទាយមានជ័យ និងបាត់ដំបង។

**ការពិភាក្សាក្រុមៈ** ការពិភាក្សាក្រុមផ្តោតបញ្ហា (FGD) ពិភាក្សាជាមួយឪពុកម្តាយរបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ វិធីសាស្ត្រនេះមានគោលបំណងដើម្បីស្វែងយល់ពីបទពិសោធន៍ជាក់ស្តែងរបស់គ្រួសារកុមារ។

តារាង១៖ អ្នកផ្តល់ព័ត៌មានសំខាន់ៗ

| **ខេត្តបន្ទាយមានជ័យ** | | **ថ្នាក់ជាតិ** | |
|---|---|---|---|
| គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (PCCT) | ២ | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ | ១ |
| មន្ទីរសង្គមកិច្ចខេត្ត (PDoSVY) | ២ | អង្គការសង់ត្រាល | ១ |
| មជ្ឈមណ្ឌលសំចតប៉ោយប៉ែត | ១ | អង្គការមិត្ត (មិត្តសំឡាញ់អន្តរជាតិ) | ៣ |
| អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ | ១ | អង្គការមិត្តសំឡាញ់ | ១ |
| អង្គការដំណក់ទឹក | ២ | អង្គការជំនួយផ្លូវច្បាប់ដល់កុមារី និងស្ត្រី | ១ |
| នគរបាលអន្តោប្រវេសន៍ | ២ | អង្គការកល្យាណមិត្ត (អង្គការមិត្តអន្តរជាតិ) ខេត្តបន្ទាយមានជ័យ | ១ |
| ការិយាល័យសុខុមាលភាពសង្គមស្រុក | ១ | អង្គការយូនីសេហ្វ | ១ |
| ជនទេសន្តរប្រវេស៍ដែលត្រឡប់មកវិញជាមួយកូនៗ | ៥ (ស្ត្រី៤នាក់) | ស.អ.យ – (ទទួលបន្ទុកការងារជួញដូរមនុស្ស) | ១ |

| | | | |
|---|---|---|---|
| **ខេត្តបាត់ដំបង** | | ស.អ.យ (ការវាយតម្លៃ និង ផែនការសកម្មភាពស្តុំកូនអន្តរប្រទេសនៅកម្ពុជា) MoSVY ICAA | ១ |
| គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (PCCT) | ១ | អង្គការរតនៈ | ៤ |
| មន្ទីរសង្គមកិច្ចខេត្ត (PDoSVY) | ១ | គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស | ៤ |
| មណ្ឌលទទួលពលករកំរៀង (Kamrieng MRC) | ២ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤ |
| គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (PCCT) | ១ | **អន្តរជាតិ** | |
| អង្គការកុមាររីករាយ (KMR) | ១ | អង្គការ ASEAN Act | ១ |
| អង្គការ Holt | ១ | អង្គការយូនីសេហ្វ | ៣ |
| អង្គការ CCT | ១ | អង្គការ អន្តរជាតិទេសន្តរប្រវេសន៍ (IOM) | ១ |
| អង្គការ Hagar | ១ | អង្គការពលកម្មអន្តរជាតិ (ILO) | ១ |
| | | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) | ១ |

## និយមន័យ និងពាក្យស័ព្ទ

**ជនទេសន្តរប្រវេសន៍ –** សំណុំពាក្យស័ព្ទ ដែលមិនត្រូវបានកំណត់នៅក្រោមច្បាប់អន្តរជាតិ ឆ្លុះបញ្ចាំងពីការយល់ដឹងទូទៅរបស់បុគ្គលដែលផ្លាស់ទី ចេញពីកន្លែងខ្លួនធ្លាប់រស់នៅជាធម្មតា ដោយមិនគិតការផ្លាស់ទីក្នុងប្រទេស ឬឆ្លងកាត់ច្រកទ្វារអន្តរជាតិ បណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ និងដោយហេតុផលផ្សេងៗ។ ពាក្យស័ព្ទនេះរួមបញ្ចូលការងារ ការសិក្សា ឬហេតុផលផ្សេងទៀត។[7]

**ទេសន្តរប្រវេសន៍ការងារ –**ការផ្លាស់ទីលំនៅរបស់បុគ្គលពីរដ្ឋមួយទៅរដ្ឋមួយទៀត ឬក្នុងប្រទេសដែលខ្លួនរស់នៅក្នុងគោលបំណងស្វែងរកការងារ។

[7] Key Migration Terms, Migration Glossary | IOM, UN Migration

**ពលករទេសន្តរប្រវេសន៍:** ពលករទេសន្តរប្រវេសន៍គឺជាបុគ្គលដែលត្រូវចូលរួម កំពុងចូលរួម ឬបានចូលរួមក្នុងសកម្មភាពទទួលប្រាក់កម្រៃនៅក្នុងរដ្ឋដែលបុគ្គលនោះមិនមានសញ្ជាតិ។ (និយមន័យនេះគឺជានិយមន័យរបស់អង្គការ ILO និងមិនរាប់បញ្ចូលទេសន្តរប្រវេសន៍ក្នុងប្រទេស)[8] ។

**កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍:** គឺជាសំណុំវាក្យស័ព្ទ រួមមានកុមារ (អាយុក្រោម ១៨ ឆ្នាំ) ដែលកំពុងផ្លាស់ទី ឬបានផ្លាស់ទីលំនៅ ចាកចេញពីប្រទេសដើមរបស់ខ្លួន ឬឆ្លងកាត់ច្រកព្រំដែន ចូលទៅកាន់ប្រទេសមួយផ្សេងទៀត ទាំងបណ្ដោះអាសន្នក្ដី ឬអចិន្ត្រៃយ៍ក្ដី។ ចំណុចនេះរាប់បញ្ចូលទាំងកុមារដែលធ្វើទេសន្តរប្រវេសន៍ដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត (ការផ្លាស់ទីលំនៅដោយបង្ខំកើតឡើង ដោយគ្រោះមហន្តរាយធម្មជាតិ ឬសង្គ្រាម) ឬដោយហេតុផលសេដ្ឋកិច្ច សង្គម ការអប់រំ ឬវប្បធម៌។ នេះរាប់បញ្ចូលទាំងកុមារធ្វើដំណើរតែឯង ឬធ្វើដំណើរជាមួយឪពុកម្ដាយ ហើយក៏រាប់បញ្ចូលកុមារដែលឪពុកម្ដាយម្នាក់ ឬទាំងពីរនាក់ ទុកពួកគេនៅស្រុកកំណើត[9]។

**កុមារកំពុងផ្លាស់ទី:** សំណុំវាក្យស័ព្ទដែលប្រើដើម្បីពិពណ៌នាអំពីកុមារទាំងឡាយ ដែលកំពុងផ្លាស់ទី ដោយហេតុផលផ្សេងៗគ្នា ដោយស្ម័គ្រចិត្ត ឬដោយមិនស្ម័គ្រចិត្ត រវាងប្រទេស ឬក្នុងប្រទេស ដោយមានឬគ្មានឪពុកម្ដាយ ឬអាណាព្យាបាល ហើយការចល័តរបស់ពួកគេ ខណៈពេលដែលពួកគេអាចទទួលបានឱកាសការងារ វាក៏អាចធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យខ្ពស់នៃការកេងប្រវ័ញ្ចសេដ្ឋកិច្ច ឬផ្លូវភេទ ការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ឬអំពើហិង្សា[10]។ កុមារដែលកំពុងផ្លាស់ទីរួមមាន កុមារទេសន្តរប្រវេសន៍ ជនភៀសខ្លួនកុមារ កុមារស្វែងរកសិទ្ធិជ្រកកោន កុមារផ្លាស់ទីលំនៅក្នុងប្រទេស កុមារគ្មានរដ្ឋ និងកុមារដែលត្រូវបានជួញដូរ។

**កុមារនៃគ្រួសារទេសន្តប្រវេសន៍ដែលទុកនៅសហគមន៍:** សំដៅលើ កុមារនៅក្នុងសហគមន៍ដែលឪពុក ឬម្ដាយ ឬឪពុកម្ដាយទាំងពីរនាក់ ធ្វើចំណាកស្រុកនៅក្នុង ឬក្រៅប្រទេស ដើម្បីស្វែងរកការងារធ្វើ ឬស្វែងរកជីវិតកាន់តែប្រសើរ[11] ។ កុមារទាំងនេះអាចត្រូវបានទុកឱ្យនៅជាមួយសមាជិកគ្រួសារ, មិត្តភក្តិ, សហគមន៍, កន្លែងថែទាំកុមារ ឬទុកឱ្យរស់នៅដោយខ្លួនឯង។កុមារអាច ការទុកកុមារឱ្យនៅប្រទេសដើម ក្នុងរយៈពេលខ្លី ឬយូរ គឺជារឿងធម្មតា ជាពិសេសនៅក្នុងប្រទេសដែលមានទេសន្តរប្រវេសន៍តាមរដូវកាល ទាក់ទងនឹងការងារកសិកម្ម[12]។

**ជនទេសន្តប្រវេសន៍វិលត្រឡប់មកវិញ** សំដៅលើពលរដ្ឋដែលបានធ្វើចំណាកស្រុកទៅក្រៅប្រទេស ឬក្នុងប្រទេស ហើយបន្ទាប់មកត្រឡប់ទៅប្រទេស ឬស្រុកកំណើតរបស់ពួកគេវិញ។ ការត្រឡប់មកវិញនេះអាចជាការស្ម័គ្រចិត្ត ឬបង្ខំ ហើយអាចពាក់ព័ន្ធនឹងកត្តាផ្សេងៗដូចជាឱកាសសេដ្ឋកិច្ច ការជួបជុំគ្រួសារ ឬការផ្លាស់ប្តូរលក្ខខណ្ឌនយោបាយ ឬសង្គម[13]។ កុមារដែលត្រូវបានត្រឡប់មកវិញអាចដោយស្មគ្រ័ចិត្ត ឬមិនស្ម័គ្រចិត្ត ឬក្នុងលក្ខណៈបំបែកចេញឬមិនមានអ្នករួមដំណើរជាមួយ។ ការធ្វើទេសន្តរប្រវេសន៍ត្រឡប់មកប្រទេសកំណើតវិញដោយ

---

[8] Glossary of Skills and Labour Migration | International Labour Organization
[9] Child Migration | EMM2
[10] Inter-Agency Working Group on Children on the Move
[11] COM-Terminology-Brief.pdf
[12] Children-Left-Behind.pdf
[13] COM-Terminology-Brief.pdf

ស្ម័គ្រចិត្តគឺនៅពេលដែលជនទេសន្តរប្រវេសន៍ ជ្រើសរើសត្រឡប់ទៅប្រទេសដើមវិញដោយឯករាជ្យ ឬដោយការជួយជ្រោមជ្រែង[14]។ មិនមាននិយមន័យដាច់ដោយឡែកសម្រាប់កុមារទេ។ កុមារដែលត្រឡប់មកវិញដោយមិនស្ម័គ្រចិត្ត ត្រូវចាត់ទុកថាជាលក្ខណៈបំបែកចេញឬមិនមានអ្នករួមដំណើរជាមួយ។

**កុមារដែលបំបែកចេញ៖** គឺជាកុមារដែលបែកចេញពីឪពុកម្តាយទាំងពីរ ឬពីអ្នកថែទាំកុមារស្របច្បាប់ពីមុន ឬអ្នកថែរទាំចំបងរបស់ពួកគេពីមុន ប៉ុន្តែមិនចាំបាច់មកពីសាច់ញាតិផ្សេងទៀតទេ។ ដូច្នេះ ទាំងនេះអាចរួមបញ្ចូលកុមារដែលរួមដំណើរដោយសមាជិកគ្រួសារពេញវ័យផ្សេងទៀត[15]។

**កុមារដែលមិនមានអ្នករួមដំណើរជាមួយ៖** គឺកុមារដែលឃ្លាតចេញពីឪពុកម្តាយទាំងពីរ និងសាច់ញាតិផ្សេងទៀត ហើយមិនត្រូវបានមើលថែដោយមនុស្សពេញវ័យ ដែលដោយស្របច្បាប់ ឬស្ថាប័នទទួលខុសត្រូវក្នុងការថែរទាំកុមារ[16]។

**ចំណាកស្រុកដោយសារបម្រែបម្រួលអាកាសធាតុ:** ការផ្លាស់ទីរបស់បុគ្គលម្នាក់ ឬជាក្រុម ដែលភាគច្រើន ផ្លាស់ទីដោយហេតុផលប្រែប្រួលអាកាសធាតុ ដែលនាំឱ្យបរិស្ថានជុំវិញប្រែប្រួលភ្លាមៗ ឬប្រែប្រួលជាលំដាប់ ជំរុញឱ្យពួកគេត្រូវចាកចេញពីកន្លែងរស់នៅជាទម្លាប់ ឬជ្រើសរើសចាកចេញ ទាំងបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ នៅក្នុងប្រទេស ឬឆ្លងកាត់ព្រំដែនអន្តរជាតិ[17]។

**ពលរដ្ឋចំណាកស្រុកក្រៅប្រទេស** សំដៅលើជន (រួមទាំងកុមារ) ដែលផ្លាស់ទីឆ្លងកាត់ព្រំដែនអន្តរជាតិទៅកាន់ប្រទេសដែលពួកគេមិនមែនជាសញ្ជាតិ ដើម្បីបង្កើតលំនៅដ្ឋានថ្មី ទាំងបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍។ ទាំងនេះអាចកើតឡើងដោយសារហេតុផលផ្សេងៗ ដូចជាការស្វែងរកឱកាសសេដ្ឋកិច្ច រួបរួមជាមួយសមាជិកគ្រួសារ ការបន្តការអប់រំ គេចផុតពីជម្លោះ ឬការគំរាមកំហែង ឬការឆ្លើយតបទៅនឹងកត្តាបរិស្ថានដូចជាការប្រែប្រួលអាកាសធាតុ[18]។

**ពលរដ្ឋចំណាកស្រុកក្នុងប្រទេស** សំដៅលើជន (រួមទាំងកុមារ) ដែលផ្លាស់ទីនៅក្នុងប្រទេសមួយ ជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ដូចជាការផ្លាស់ប្តូរពីជនបទទៅទីក្រុងសម្រាប់ឱកាសសេដ្ឋកិច្ច ឬការអប់រំកាន់តែប្រសើរ ឬការផ្លាស់ទីលំនៅដោយសារគ្រោះមហន្តរាយធម្មជាតិ ឬសង្គ្រាម។[19]។

**ប្រព័ន្ធកិច្ចការពារកុមារ៖** អង្គការយូនីសេហ្វ កំណត់និយមន័យប្រព័ន្ធកិច្ចការពារកុមារថាជា "រចនាសម្ព័ន្ធផ្លូវការ និងមិនផ្លូវការ មុខងារ និងសមត្ថភាព ដែលត្រូវបានប្រមូលផ្តុំដើម្បីផ្តល់ការការពារ និងឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពាន ការមិនអើពើ និងការកេងប្រវ័ញ្ចលើកុមារ។ ប្រព័ន្ធកិច្ចការពារកុមារជាទូទៅត្រូវបានឯកភាពដោយមាន

---

[14] COM-Terminology-Brief.pdf
[15] COM-Terminology-Brief.pdf
[16] COM-Terminology-Brief.pdf
[17] Key Migration Terms, Migration Glossary | IOM, UN Migration
[18] COM-Terminology-Brief.pdf
[19] COM-Terminology-Brief.pdf

ជាតុផ្សំដូចខាងក្រោម៖ ធនធានមនុស្ស ហិរញ្ញវត្ថុ ច្បាប់ និងគោលនយោបាយ អភិបាលកិច្ច ការត្រួតពិនិត្យ និងការប្រមូលទិន្នន័យ ក៏ដូចជាសេវាកិច្ចការពារ និងឆ្លើយតប ហើយនិងការគ្រប់គ្រងការថែទាំ។ ប្រព័ន្ធកិច្ចការពារកុមារនេះក៏រួមបញ្ចូលនូវតួអង្គផ្សេងៗគ្នាផងដែរ ដែលរួមមាន - កុមារ គ្រួសារ សហគមន៍ អ្នកធ្វើការនៅថ្នាក់ក្រោមជាតិ ឬថ្នាក់ជាតិ និងអ្នកដែលធ្វើការអន្តរជាតិ។ អ្វីដែលសំខាន់បំផុតគឺទំនាក់ទំនង និងអន្តរកម្មរវាង និងក្នុងចំណោមសមាសធាតុ និងតួអង្គទាំងនេះនៅក្នុងប្រព័ន្ធ។ វាគឺជាលទ្ធផលនៃអន្តរកម្មទាំងនេះ ដែលរួមមានក្នុងប្រព័ន្ធ[20]។

# លទ្ធផលរកឃើញ

## បរិបទប្រទេសកម្ពុជា

រយៈពេលពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាមើលឃើញវឌ្ឍនភាពដ៏សំខាន់ក្នុងការអភិវឌ្ឍតាមរយៈកំណែទម្រង់ គោលនយោបាយគោលដៅ និងការរៀបចំដំណើរការនយោបាយ។ ខណៈមានការរីកចម្រើនការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច បានកើតឡើងមែន តែទេសន្តរប្រវេសន៍នៅតែជាបញ្ហាបន្តកើនឡើងជាចម្បងទៅកាន់ប្រទេសជិតខាង។ មុនការរាតត្បាតជំងឺកូវីដ-១៩ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ក្នុងមួយទសវត្សរ៍កន្លងទៅ។ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៩ កម្ពុជាមានអត្រាកំណើនផលិតផលសរុបក្នុងស្រុក *(GDP)* ប្រចាំឆ្នាំជាមធ្យមលើសពី ៧ ភាគរយ[21] ឈរជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ កត្តាសំខាន់ៗជាច្រើនបាននាំទៅរកការពង្រីកសេដ្ឋកិច្ចដ៏រឹងមាំនេះ។ ប្រទសកម្ពុជារក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយមានអតិផរណាទាប និងមានស្ថិរភាព។ ប្រទេសនេះនៅតែបើកចំហចំពោះពាណិជ្ជកម្មអន្តរជាតិ ដែលគាំទ្រដល់កំណើននៃការនាំចេញ។ ការវិនិយោគផ្ទាល់ពីបរទេសដ៏ច្រើនសន្ធឹកសន្ធាប់បានហូរចូលមកក្នុងប្រទេសជាបន្តបន្ទាប់ និងជួយដល់ការអភិវឌ្ឍឧស្សាហកម្មផលិតកម្ម។ វិស័យទេសចរណ៍មានកំណើតខ្លាំង តាមរយៈកំណើនភ្ញៀវទេសចរបរទេស ជួយរួមចំណែកដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ច។ ជាចុងក្រោយ ប្រទេសកម្ពុជាបានផ្លាស់ប្តូររចនាសម្ព័ន្ធឆ្ពោះទៅរកឧស្សាហកម្មផលិតកម្មនាំចេញ ដោយចាកចេញពីវិស័យកាត់ដេរប្រពៃណី[22]។

នៅឆ្នាំ ២០២៣ សេដ្ឋកិច្ចរបស់កម្ពុជានៅបន្តស្ទុះងើបឡើងវិញ ដោយកំណើនផលិតផលក្នុងស្រុក (GDP) កើនឡើងប្រមាណ ៥% ជំរុញដោយវិស័យទេសចរណ៍ និងវិស័យផលិតកម្មមិនមែនកាត់ដេរ។ អតិផរណាបានធ្លាក់ចុះដល់ ២,១% ពី ៥,៣% កាលពីឆ្នាំមុន ដោយសារសម្ពាធតម្លៃទំនិញសកលបានធូរស្រាល។ ការងើបឡើងវិញនៃវិស័យទេសចរណ៍ និងពាណិជ្ជកម្មបាន ជំរុញឱ្យគណនីចរន្តប្រែក្លាយជាអតិរេក។ គោលនយោបាយសារពើពន្ធនៅតែពង្រីកវិសាលភាព[23] គិតត្រឹមឆ្នាំ ២០២២ ប្រជាជនចំនួនប្រហែល ៣០,៥ ភាគរយ មានអាយុក្រោម ១៥ ឆ្នាំ[24] តំណាងឱ្យក្រុមយុវជនភាគច្រើន។ បច្ចុប្បន្ន ប្រទេសកម្ពុជា កំពុងឆ្លងកាត់ការផ្លាស់ប្រែប្រជាសាស្ត្រពីអត្រាមានកូនខ្ពស់ និងអត្រាមរណៈភាព ទៅជាអត្រាមានកូនទាប និងអត្រាមរណៈភាព។ នៅឆ្នាំ ២០១៨ ក្រុមអាយុក្រោម ២៤ ឆ្នាំ ក្លាយជាផ្នែកដ៏ធំនៃរចនាសម្ព័ន្ធប្រជាសាស្ត្រ មានប្រមាណ

[20] Child Protection Systems Strengthening .pdf
[21] https://www.worldbank.org/en/country/cambodia/overview
[22] https://www.adb.org/sites/default/files/publication/149852/cambodia-diversifying-country-diagnostic-study.pdf
[23] https://www.adb.org/where-we-work/cambodia/overview
[24] https://cambodia.unfpa.org/sites/default/files/pub-pdf/nap_nydc_2022_2026_eng_approved_publication.pdf

ប្រហែល ៥០,២ ភាគរយនៃចំនួនប្រជាជនសរុប[25]។ ការថយចុះអត្រានៃការមានកូន និងការកើនឡើងចំនួនយុវជន ក្នុងស្រទាប់ប្រជាជនសរុប បានបង្កើតឱកាសដល់ការបែងចែកប្រជាសាស្ត្រនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ន ប្រជាជនកម្ពុជាប្រហែលមួយភាគបីមានអាយុចន្លោះពី ១៥ ទៅ ២៩ ឆ្នាំ ដែលបង្កើតបានជាកម្លាំងពលកម្មដ៏មានសក្តានុពល។ ដោយមានរចនាសម្ព័ន្ធប្រជាសាស្ត្របែបនេះ យុវជនកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងបន្តគាំទ្រកំណើនសេដ្ឋកិច្ចក្នុងរយៈពេលបីទសវត្សរ៍ខាងមុខ។

កុមារលើស ២ នាក់ក្នុងចំណោម ៥ នាក់រស់នៅក្នុងភាពក្រីក្រពហុវិមាត្រនៅក្នុងឆ្នាំ ២០១៤ តែតួលេខនេះបានថយចុះ មកប្រហែល១ក្នុងចំណោម៥នាក់ (២០,៥%) នៅឆ្នាំ ២០២២[26]។ នៅឆ្នាំ២០១៩ ប្រជាជន វ័យចំណាស់នៅក្នុងប្រទេសកម្ពុជាមានប្រហែល ៦០% ខ្ពស់ជាងចំនួនប្រជាជនក្រុមអាយុដូចគ្នា ដែលបានជំរឿនក្នុងឆ្នាំ ២០០៨ ។ ក្នុងចំណោមប្រជាជនកម្ពុជាដែលមានវ័យចំណាស់ ៦០% នោះ មានអាយុពី ៦០ ទៅ ៦៩ ឆ្នាំ និង ៣០% មានអាយុ ៧០ ដល់ ៧៩ ឆ្នាំ និង ១០% មានអាយុ ៨០ ឆ្នាំឡើង។ ស្ត្រីវ័យចំណាស់មានចំនួនកាន់តែច្រើន ដោយបុរសមានត្រឹមតែ ៦៦,៣ នាក់ប៉ុណ្ណោះក្នុងចំណោមស្ត្រី ១០០ នាក់ បង្ហាញថាចំនួនមនុស្សចាស់ជាស្ត្រីកើនឡើង[27]។ ជនទេសន្តរប្រវេសន៍ជាច្រើនបានទុកកូនៗរបស់ពួកគេនៅជនបទ ហើយកុមារទាំងនោះជាច្រើន រស់នៅក្នុងគ្រួសារដែលមានមនុស្សចាស់មើលថែ។ គួរកត់សម្គាល់ថា ប្រទេសកម្ពុជាមានអត្រាពិការភាពខ្ពស់បំផុតក្នុងពិភពលោក ឈានដល់ ៥៧% ក្នុងចំណោមអ្នកដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ ដែលភាគច្រើនជាយាយតា ត្រូវបានទុកនៅផ្ទះឱ្យនៅមើលថែទាំចៅៗ ខណៈដែលឪពុកម្តាយរបស់កុមារទាំងនោះធ្វើទេសន្តរប្រវេសន៍រកការងារ។[28] ដូចនេះ ទេសន្តរប្រវេសន៍យ៉ាងឆាប់រហ័ស និងការឈាន ចូលវ័យ ចាស់ជរាក្នុងស្រទាបប្រជាជន គឺជាបាតុភូតពីរដែលកើតឡើងរួមគ្នាក្នុងប្រទេសកម្ពុជា។

## និន្នាការទេសន្តរប្រវេសន៍

នៅតំបន់អាស៊ីអាគ្នេយ៍មានជនទេសន្តរប្រវេសន៍អន្តរជាតិជាង ១០ លាននាក់។ ទេសន្តរប្រវេសន៍គឺជាដំណើរដ៏ស្មុគ្រស្មាញ និងពហុទិសដៅ៖ អាចមានរយៈពេលខ្លី ជាអចិន្ត្រៃយ៍ ជាចរន្ត ឬវិលត្រឡប់ទៅប្រទេសដើមវិញ។ បន្ទាប់ពីត្រឡប់មកស្រុកវិញ ពលករទេសន្តរប្រវេសន៍ត្រូវធ្វើសមាហរណកម្មទៅក្នុងគ្រួសារ សហគមន៍ និងសេដ្ឋកិច្ចក្នុងស្រុក[29]។ ទេសន្តរប្រវេសន៍ក្នុង និងក្រៅប្រទេស ដើរតួនាទីយ៉ាងសំខាន់ក្នុងកម្លាំងពលកម្មរបស់ប្រទេសកម្ពុជា។ ជាទូទៅ នៅក្នុងប្រទេសកម្ពុជា ប្រជាជនចាកចេញពីជនបទទៅទីក្រុង ដោយពួកគេបន្តធ្វើការងារគ្មានជំនាញ ឬពាក់កណ្តាលជំនាញនៅក្នុងវិស័យឧស្សាហកម្មសំណង់ និងកាត់ដេរក្នុងរាជធានីភ្នំពេញ និងតំបន់ទីក្រុងផ្សេងទៀត។ ប្រជាជនកម្ពុជាជាច្រើនក៏បានចាកចេញទៅក្រៅប្រទេសផងដែរ គិតត្រឹមឆ្នាំ ២០១៨ មានចំនួនជាងមួយលាននាក់ ត្រូវបានប៉ាន់ស្មានថា ទៅធ្វើការនៅប្រទេសជិតខាង មានដូចជា

[25] National Institute of Statistics (NIS) [Cambodia], Ministry of Health (MoH) [Cambodia], and ICF. 2022. *Cambodia Demographic and Health Survey 2021–22 Key Indicators Report*. Phnom Penh, Cambodia, and Rockville, Maryland, USA: NIS, MoH, and ICF.
[26] https://www.worldbank.org/en/country/cambodia/overview
[27] https://nis.gov.kh/nis/Census2019/Cambodia%20Demographics%20Population%20Ageing.pdf
[28] https://asianews.network/children-of-migrants-in-cambodia-bear-the-brunt-of-climate-change-says-report/
[29] https://asean.org/wp-content/uploads/2022/08/ASEAN-Migration-Outlook-Final.pdf

ប្រទេសថៃ កូរ៉េខាងត្បូង និងម៉ាឡេស៊ី[30]។ វិស័យសំខាន់ៗដែលទាក់ទាញពលករទេសន្តរប្រវេសន៍កម្ពុជារួមមាន កសិកម្ម សំណង់ ផលិតកម្ម និងសេវាកម្មក្នុងប្រទេស។

ជារឿយៗ សម្ពាធសេដ្ឋកិច្ច ជំរុញឱ្យមានទេសន្តរប្រវេសន៍អន្តរជាតិកើតឡើង។ ការជាប់បំណុលច្រើនក្នុងប្រទេសកម្ពុជា ស្របពេលជាមួយតម្រូវការកម្លាំងពលកម្មច្រើននៅប្រទេសគោលដៅ ជាកត្តាជំរុញឱ្យប្រជាជនកម្ពុជា នាំគ្នាស្វែងរកការងារនៅបរទេស ទោះបីជាមានហានិភ័យក៏ដោយ។ ជនទេសន្តរប្រវេសន៍បានចូលរួមចំណែកយ៉ាងធំដល់សេដ្ឋកិច្ចកម្ពុជាតាមរយៈការផ្ទេរប្រាក់ទៀងទាត់ ផ្ញើទៅប្រទេសកំណើត និងតាមរយៈការពង្រឹងទីផ្សារការងារ ដោយទទួលជំនាញពីបរទេសត្រឡប់មកស្រុកវិញ[31]។ បច្ចុប្បន្ននេះ ស្ត្រីរួមចំណែកជិតស្មើទៅនឹងអត្ថប្រយោជន៍ទាំងនេះ ប៉ុន្តែស្ត្រីជាពលករទាំងនេះ ប្រឈមបញ្ហាមិនសមាមាត្រទាំងដំណើរចេញ និងដំណើរចូលមកវិញ។ គេប៉ាន់ប្រមាណថា ជនទេសន្តរប្រវេសន៍កម្ពុជាគ្មានឯកសារពាប់សែននាក់កំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ នៅមុនពេលដំណើរការធ្វើឱ្យស្របច្បាប់នៅឆ្នាំ ២០១៧។ នៅតាមច្រកទ្វារតូចៗរបស់កម្ពុជា ភាពក្រីក្រ រួមទាំងទីតាំងភូមិសាស្ត្រ បានបណ្តាលឱ្យប្រទេសនេះ ក្លាយជាចំណុចសំខាន់នៃទីតាំងដើមទីសំចត និងទីតាំងគោលដៅសម្រាប់ជនទេសន្តរប្រវេសន៍មិនប្រក្រតី។ ការចំណាយខ្ពស់ទៅលើទេសន្តរ ប្រវេសន៍ស្របច្បាប់ បង្ខំឱ្យប្រជាជនកម្ពុជាជាច្រើន ជ្រើសរើសទេសន្តរប្រវេសន៍មិនប្រក្រតីតាមរយៈមេខ្យល់ ដែលធ្វើឱ្យពួកគេប្រឈមហានិភ័យនៃការជួញដូរ និងការកេងប្រវ័ញ្ច។ យុវជន និងយុវនារីក៏ធ្វើដំណើរទៅធ្វើការងារកសិកម្ម រយៈពេលខ្លី បណ្តោះអាសន្ន នៅតាមច្រកទ្វារព្រំដែនថៃ។

បម្រែបម្រួលអាកាសធាតុ និងវិបត្តិនៅក្នុងតំបន់ ក៏បានរួមចំណែកដល់ការផ្លាស់ទីដ៏ស្មុគស្មាញ ដោយជនទេសន្តរប្រវេសន៍ជាច្រើន បានចាកចេញពីប្រទេសកម្ពុជា ដើម្បីស្វែងរកឱកាសការងារកាន់តែប្រសើរនៅក្នុងប្រទេសថៃ។ ប្រទេសកម្ពុជាស្ថិតក្នុងលំដាប់កំពូល ១/៣ ក្នុងបណ្តាប្រទេសដែលកុមារប្រឈមហានិភ័យខ្ពស់ដោយបម្រែបម្រួលអាកាសធាតុ [32] នៅពេលដែលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅកម្ពុជាកាន់តែខ្លាំង ទេសន្តរប្រវេសន៍អាចកើនឡើង ដែលរួមមានការផ្លាស់ទីពីជនបទទៅទីក្រុង និងទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ជាពិសេសទៅកាន់ប្រទេសថៃ ក្នុងគោលបំណងរកឱកាសការងារដែលមានប្រាក់ខែកាន់តែប្រសើរ [33] បម្រែបម្រួលអាកាសធាតុធ្វើឱ្យហានិភ័យនៃកិច្ចការពារកុមារកាន់តែធ្ងន់ធ្ងរឡើង ដូចជាពលកម្មកុមារ អំពើហិង្សាលើកុមារ អាពាហ៍ពិពាហ៍កុមារ និងការជួញដូរមនុស្ស។

នៅក្នុងខែមករា ឆ្នាំ ២០២៥ ប្រទេសកម្ពុជាបានចេញផ្សាយសន្ទស្សន៍ហានិភ័យអាកាសធាតុរបស់កុមារ ឬ CCRI ដែលបង្ហាញថាកុមារប្រហែល ១,៦ លាននាក់ (30 ភាគរយ នៃកុមារនៅក្នុងប្រទេស) ប្រឈមមុខនឹងភាពងាយរងគ្រោះខ្ពស់ចំពោះអាកាសធាតុ និងបរិស្ថានគ្រោះថ្នាក់ ភាពតក់ស្លុត និងភាពតានតឹង។ បម្រែបម្រួលអាកាសធាតុបានបង្កើនគ្រោះទឹកជំនន់ជាញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតប បញ្ហាកិច្ចការពារកុមារជារឿយៗត្រូវបានមើលរំលងនៅពេលធ្វើការឆ្លើយតបបន្ទាន់ ដោយការឆ្លើយតបផ្តល់អាទិភាពតែទៅលើទីជម្រក អាហារ ទឹកស្អាតនិងអនាម័យ និងសុខភាព។

[30] https://asean.org/wp-content/uploads/2021/12/1.-Labour-Migration-Policy-2019-2023.pdf
[31] https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/genericdocument/wcms_735105.pdf
[32] UNICEF Cambodia Country Programme 2024-2028
[33] https://asianews.network/children-of-migrants-in-cambodia-bear-the-brunt-of-climate-change-says-report/

ក្នុងអំឡុងពេល និងក្រោយព្រឹត្តិការណ៍ដែលទាក់ទងនឹងអាកាសធាតុ កុមារកាន់តែងាយរងគ្រោះដោយអំពើហិង្សា ការបំបែកបែកចេញពីគ្រួសារ វិបត្តិចិត្តសង្គម និងអ្នកថែទាំ និង/ឬកុមារ និងក្មេងជំទង់អាចងាកទៅរកយន្តការដោះស្រាយបញ្ហាដែលបង្កគ្រោះថ្នាក់។ គ្រោះថ្នាក់ទាំងនេះធ្វើឱ្យហានិភ័យនៃកិច្ចការពារដែលមានស្រាប់កាន់តែធ្ងន់ធ្ងរឡើង ហើយបង្កើនភាពងាយរងគ្រោះរបស់កុមារទាំងផ្លូវកាយ ផ្លូវភេទ និងការរំលោភផ្សេងៗទៀត[34]។

បច្ចុប្បន្ន ប្រទេសកម្ពុជា មានចំនួនប្រជាជនក្នុងវ័យធ្វើការដ៏ច្រើន ធៀបនឹងប្រទេសជិតខាង។ ទោះយ៉ាងណាក្តី ដោយសារអត្រាការមានកូននៅបន្តតែមានកម្រិតខ្ពស់ ចំនួនប្រជាជននៅតែបន្តកើនឡើងជាលំដាប់ និងអាយុចូលវ័យចាស់ ប្រទេសកម្ពុជានឹងត្រៀមខ្លួនរួចជាស្រេចក្នុងការបន្តពង្រីកកម្លាំងការងារក្នុងស្រុករបស់ខ្លួនរហូតដល់ឆ្នាំ ២០៤៥[35]។ ផ្ទុយទៅវិញ ប្រទេសមួយចំនួនដូចជា សិង្ហបុរី ម៉ាឡេស៊ី ថៃ និងវៀតណាម បានផ្លាស់ផុតចំនួនប្រជាជនក្នុងវ័យធ្វើការដ៏ច្រើន ហើយប្រឈមការធ្លាក់ចុះបន្តិចម្តងៗ ចាប់ផ្តើមនៅឆ្នាំ ២០១០ នៅប្រទេសថៃ និងសិង្ហបុរី ឆ្នាំ, ២០១៣ នៅប្រទេសវៀតណាម និងឆ្នាំ ២០១៨ នៅប្រទេសម៉ាឡេស៊ី។ និន្នាការប្រជាសាស្ត្រ ស្រដៀងគ្នានេះ ក៏បានជះឥទ្ធិពលដល់ប្រទេសអភិវឌ្ឍន៍ជាច្រើនទៀត មានដូចជាប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូងផងដែរ។

## ពលករកម្ពុជាធ្វើទេសន្តរប្រវេសន៍ទៅកាន់ប្រទេសថៃ

យោងតាមរបាយការណ៍ថ្មីៗ ប្រទេសថៃនៅតែជាគោលដៅចម្បងសម្រាប់ទេសន្តរប្រវេសន៍ និងការជួញដូរពលករកម្ពុជា[36]។ យោងតាមមន្ត្រីជាន់ខ្ពស់នៅក្រសួងការងារ គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ ពលករទេសន្តរប្រវេសន៍កម្ពុជាប្រមាណ ១,៣លាននាក់ កំពុងរស់នៅក្រៅប្រទេស ដែលភាគច្រើនមានទីតាំងនៅប្រទេសថៃ និងប្រទេសកូរ៉េខាងត្បូង[37]។ មិនមានទិន្នន័យអំពីចំនួនកុមារដែលធ្វើទេសន្តរប្រវេសន៍ជាមួយឪពុកម្តាយរបស់ពួកគេទេ ទោះបីជាកុមារទុកនៅស្រុកមានចំនួនច្រើនជាងនេះ ក៏កុមារមួយចំនួនធំបានធ្វើទេសន្តរប្រវេសន៍ជាមួយក្រុមគ្រួសាររបស់ពួកគេ និងខ្លះធ្វើដំណើរតែម្នាក់ឯងក៏មាន។ ទិន្នន័យថ្មីៗពីមជ្ឈមណ្ឌលសំចតក្រុងប៉ោយប៉ែត ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២៤ បង្ហាញថា កុមារចំនួន ៥៤២នាក់ ត្រឡប់មកវិញ (ប្រុស ៣០៦ នាក់ ស្រី ២៣៦ នាក់)[38]។ កុមារទាំងអស់នោះមានឪពុកម្តាយអមដំណើរ។ ក្នុងរយៈពេលដូចគ្នានេះ ក្មេងស្រីចំនួន ៨ នាក់ និងក្មេងប្រុសចំនួន ៦នាក់ ត្រូវបានផ្តល់សេវាគ្រប់គ្រងករណីជួញដូរមនុស្ស។ ទោះបីទិន្នន័យនៅមានកម្រិតក្តី ក៏ការស្រាវជ្រាវដែលមានស្រាប់ និងតាមព័ត៌មានរបស់អ្នកផ្តល់សម្ភាសន៍សំខាន់ៗ (KIIs) បានផ្តល់នូវការយល់ដឹងខ្លះៗអំពីស្ថានភាពរបស់កុមារទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃ។

តាមការសិក្សាឆ្នាំ ២០១៩ ដែលធ្វើឡើងដោយអង្គការ *អន្តរជាតិទេសន្តរប្រវេសន៍(IOM)* សហការជាមួយសាកលវិទ្យាល័យ *ជូឡាឡុងកន* ប្រទេសថៃ [39] បានរកឃើញថា ជនទេសន្តរប្រវេសន៍កម្ពុជានៅក្នុង

[34] https://www.unicef.org/cambodia/media/9111/file/CCRI%20Cambodia.pdf.pdf
[35] https://documents1.worldbank.org/curated/en/224811567668159930/pdf/Main-Report.pdf
[36] https://kh.usembassy.gov/2024-trafficking-in-persons-report-cambodia/
[37] https://www.khmertimeskh.com/501521096/govt-provides-robust-assistance-to-1-3-million-migrant-workers/
[38] Report on Achievements for the First Semester of 2024 Poipet Transit Center
[39] Assessing Potential Changes in the Migration Patterns of Cambodian Migrants and their Impacts on Thailand and Cambodia, IOM 2019. https://www.iom.int/project/assessing-potential-changes-migration-patterns-cambodian-migrants-and-their-impacts-thailand-and-cambodia

ប្រទេសថៃ ភាគច្រើន មានស្ថានភាពសេដ្ឋកិច្ច "ក្រីក្រ" ដោយភាគច្រើន ផ្អែកលើការងារទទួលប្រាក់ខែតិចជាងប្រាក់ឈ្នួលអប្បបរមាក្នុងប្រទេសនេះ។ តាមការសិក្សានេះ មានការចូលរួមពីពលករទេសន្តរប្រវេសន៍កម្ពុជាជាង ៩០០ នាក់នៅទូទាំងខេត្តចំនួន ៦ ក្នុងប្រទេសថៃ។ ពួកគេបានសម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ៗប្រមាណ ១២២នាក់ រួមទាំងមន្ត្រីរដ្ឋាភិបាល និយោជក និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល។ ការសិក្សាបានរកឃើញថាជនទេសន្តរប្រវេសន៍កម្ពុជាភាគច្រើននៅក្នុងប្រទេសថៃ មានជីវភាពក្រីក្រ មុនពេលចាកចេញពីប្រទេសកំណើត ហើយពួកគេជ្រើសរើសចេញពីប្រទេសកម្ពុជា ដោយសារឱកាសការងារប្រសើរជាង និងទទួលបានប្រាក់ឈ្នួលខ្ពស់។ បច្ចុប្បន្ន ពលករភាគច្រើនលើសលុប ធ្វើការក្នុងវិស័យឧស្សាហកម្ម ដែលប្រើកម្លាំងពលកម្មដោយទទួលបានប្រាក់ឈ្នួលទាប មានដូចជា កសិកម្ម សំណង់ នេសាទ និងផលិតកម្ម។ ជនទេសន្តរប្រវេសន៍កម្ពុជាចូលចិត្តចេញពីស្រុកជាមួយប្តីប្រពន្ធរបស់ពួកគេ បើទោះបីច្បាប់របស់ប្រទេសថៃមិនអនុញ្ញាតឱ្យមានទេសន្តរប្រវេសន៍ជាលក្ខណៈគ្រួសារក៏ដោយ។ ៣/៤ក្នុងចំណោមអ្នកឆ្លើយសំណួរបានរៀបការរួច និង ៨៥%នៃអ្នកដែលបានស្នង់មតិ បានរស់នៅក្នុងប្រទេសថៃជាមួយប្តីប្រពន្ធរបស់ពួកគេ។ អ្នកឆ្លើយសំណួរជាងពាក់កណ្តាលនៃចំនួនសរុប សុទ្ធតែមានកូន ហើយជារឿយៗ ពួកគេទុកកូនក្នុងប្រទេសកម្ពុជា ទុកឱ្យសាច់ញាតិជួយមើលថែ។ លើសពីនេះ ជនទេសន្តរប្រវេសន៍កម្ពុជាមានទំនោរ ចាកចេញទៅប្រទេសថៃជាច្រើនដង។ អ្នកឆ្លើយសំណួរជិត ៣/៤ បានធ្លាប់ទៅធ្វើការនៅប្រទេសថៃកន្លងមក។ ពួកគេគ្រោងត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែមានមួយចំនួនតូចប៉ុណ្ណោះ មានបំណងត្រឡប់មកប្រទេសកម្ពុជាវិញនាពេលឆាប់ៗខាងមុខ។ ជាទូទៅ ពួកគេចង់រស់នៅប្រទេសថៃក្នុងរយៈពេលប្រាំមួយឆ្នាំ ឬយូរជាងនេះ មុនត្រឡប់មកប្រទេសកំណើតវិញ។

បទដ្ឋានយេនឌ័រក៏បង្កើតឱ្យមានទម្រង់ទេសន្តរប្រវេសន៍ផងដែរ។ ការសិក្សាថ្មីមួយរបស់អង្គការទស្សនៈពិភពលោក បានរកឃើញថា ម្តាយ និងឪពុកធ្វើចំណាកស្រុកជាមួយគ្នា ជាពិសេសនៅក្នុងគ្រួសារក្រីក្របំផុត ហើយស្ត្រីខ្លះធ្វើចំណាកស្រុកដោយខ្លួនឯង។ ជាញឹកញយ ក្មេងស្រីមានទំនួលខុសត្រូវការងារផ្ទះសម្បែង និងការមើលថែទាំ ឯក្មេងប្រុសទទួលបន្ទុកការងារស្រែចម្ការ និងការងារផ្ទះដែលមានគ្រោះថ្នាក់[40]។ ការបែងចែកកម្លាំងពលកម្មតាមយេនឌ័រនេះ អាចរំខានដល់ការសិក្សាអប់រំរបស់ពួកគេ និងបង្ខំពួកគេឱ្យទទួលខុសត្រូវការងាររបស់មនុស្សធំ។

## ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

### **ការប្តេជ្ញាចិត្ត និងសកម្មភាពអន្តរជាតិ** ពាក់ព័ន្ធនឹងកិច្ច**ការពារសិទ្ធិកុមាររងផលប៉ះពាល់ដោយ**ទេសន្តរប្រវេសន៍

| ការប្តេជ្ញាចិត្តជាអន្តរជាតិ | |
|---|---|
| ប្រទេសថៃ | ប្រទេសកម្ពុជា |
| **អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) និងពិធីសារជាជម្រើសរបស់អនុសញ្ញានេះ។**<br>អនុសញ្ញាស្តីពីសិទ្ធិកុមារ កំណត់សំណុំសិទ្ធិជាសកលរួមទាំងកុមារក្នុងបរិបទទេសន្តរប្រវេសន៍។ អនុសញ្ញានេះមានពិធីសារចំនួន៣ជម្រើស។ **ពិធីសារជម្រើសស្តីពីសិទ្ធិកុមារលើការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ** មានភាពពាក់ព័ន្ធបំផុតចំពោះកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ | |

[40] Policy Brief: Climate change contributes to unsafe migration - Addressing the impacts for vulnerable children and youth in Cambodia | World Vision East Asia | World Vision International

<table>
<tr><td>ប្រទេសថៃបានផ្តល់សច្ចាប័នដល់អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារជម្រើសចំនួន៣។</td><td>ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារជម្រើសចំនួន ២ ក្នុងចំណោមពិធីសារជម្រើសចំនួន ៣ រួមទាំងពិធីសារជម្រើសស្តីពីសិទ្ធិកុមារ ស្តីពីការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។</td></tr>
<tr><td colspan="2">អនុសញ្ញាឆ្នាំ ១៩៩០ ស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ ក្នុងបញ្ហាផ្សេងៗទៀត អនុសញ្ញាចែងថា កូនរបស់ពលករទេសន្តរប្រវេសន៍មានសិទ្ធិទទួលបានឈ្មោះ ការចុះឈ្មោះកំណើត និងសញ្ជាតិ និងសិទ្ធិទទួលបានការអប់រំដោយគោរពចំពោះស្ថាភាពទេសន្តរប្រវេសន៍មិនប្រក្រតី។</td></tr>
<tr><td>ប្រទេសថៃមិនបានចាត់វិធានការផ្តល់សច្ចាប័ន</td><td>កម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ ២០០៤</td></tr>
<tr><td colspan="2">អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ស្ត្រីទាំងអស់ រួមមានស្ត្រីស្ថិតក្នុងទម្រង់ទេសន្តរប្រវេសន៍ផងដែរ។ ផ្តល់អនុសាសន៍លុបចោលការរឹតបន្តឹង អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ការមានផ្ទៃពោះ ឬស្ថានភាពមាតុភាព និងជួយឱ្យមានគម្រោងការជួបជុំគ្រួសារឡើងវិញសម្រាប់ពលករទេសន្តរប្រវេសន៍ ដោយមិនមានការរើសអើងផ្លូវភេទឡើយ។</td></tr>
<tr><td>ប្រទេសថៃបានផ្តល់សច្ចាប័នអនុសញ្ញា CEDAW</td><td>ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញា CEDAW</td></tr>
<tr><td colspan="2">អនុសញ្ញាស្តីពីសិទ្ធិជនដែលមានពិការភាព (CRPD)៖ ទទួលស្គាល់ថា ស្ត្រី និងក្មេងស្រី ដែលមានពិការភាព តែងតែប្រឈមហានិភ័យខ្លាំង ទាំងខាងក្នុង និងក្រៅផ្ទះ ដោយអំពើហិង្សា របួស ឬការរំលោភបំពាន និងមិន ទទួលបានការយកចិត្តទុកដាក់ ឬការមិនខ្វល់ ហើយថាកុមារដែលមានពិការភាពទទួលបានសិទ្ធិ និងសេរីភាពជាមូលដ្ឋានពេញលេញ ស្មើភាពគ្នាទៅនឹងកុមារដទៃទៀត។</td></tr>
<tr><td>ប្រទេសថៃបានផ្តល់សច្ចាប័នអនុសញ្ញា CRPD</td><td>កម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញា CRPD</td></tr>
<tr><td colspan="2">កាតិកាសញ្ញាសកលសម្រាប់ទេសន្តរប្រវេសន៍ (GCM)<br>ក្នុងចំណោមបញ្ហាផ្សេងទៀត កាតិកាសញ្ញាសកលសម្រាប់ទេសន្តរប្រវេសន៍ (GCM) មានគោលបំណងការពារសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនទេសន្តរប្រវេសន៍ទាំងអស់ដោយមិនគិតពីស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេឡើយ។</td></tr>
<tr><td>ប្រទេសថៃបានចូលរួមនៅឆ្នាំ ២០២០។ អង្គការ (IOM) ធ្វើជាប្រធាននៅប្រទេសថៃ</td><td>កម្ពុជាចូលជាប្រទេសជើងឯកឆ្នាំ២០២១</td></tr>
<tr><td>អនុសញ្ញាស្តីពីសិទ្ធិការងារ</td><td></td></tr>
<tr><td>ប្រទេសថៃបានផ្តល់សច្ចាប័ន៖<br>អនុសញ្ញាស្តីពីការងារដោយបង្ខំ (C029) និងពិធីសាររបស់អនុសញ្ញានេះ។<br>អនុសញ្ញាស្តីពីប្រាក់ឈ្នួលស្មើគ្នា (C100)<br>អនុសញ្ញាស្តីពីការលុបបំបាត់ការងារដោយបង្ខំ (C105)<br>អនុសញ្ញាស្តីពីការរើសអើង (ការងារនិងមុខរបរ) (C111)<br>អនុសញ្ញាស្តីពីអាយុអប្បបរមា (C138)</td><td>កម្ពុជាបានផ្តល់សច្ចាប័ន<br>អនុសញ្ញាស្តីពីការងារដោយបង្ខំ (C029)<br>អនុសញ្ញាស្តីពីប្រាក់ឈ្នួលស្មើគ្នា (C100)<br>អនុសញ្ញាស្តីពីការលុបបំបាត់ការងារដោយបង្ខំ (C105)<br>អនុសញ្ញាស្តីពីការរើសអើង (ការងារ និងមុខរបរ) (C111)<br>អនុសញ្ញាស្តីពីអាយុអប្បបរមា (C138)</td></tr>
</table>

| | |
|---|---|
| អនុសញ្ញាទម្រង់ដ៏អាក្រក់នៃពលកម្មកុមារ (C182)។ | (កំណត់អាយុអប្បបរមាសម្រាប់មុខរបរមួយចំនួន) អនុសញ្ញាទម្រង់ដ៏អាក្រក់នៃពលកម្មកុមារ (C182)<br><br>លើសពីនេះ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន សេរីភាពនៃសមាគម និងការការពារសិទ្ធិរៀបចំអនុសញ្ញា (C087)សិទ្ធិក្នុងការរៀបចំ និងការចរចាជាសមូហភាព (C098) |

**អនុសញ្ញាស្តីពីសិទ្ធិកុមារ (ប្រទេសថៃ និងប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន)** កំណត់សំណុំសិទ្ធិជាសកលដែលបង្កើតជាស្តង់ដារអប្បបរមា ដែលរដ្ឋភាគីត្រូវធានាចំពោះកុមារគ្រប់រូបនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងកុមារក្នុងបរិបទទេសន្តប្រវេសន៍ ថាតើពួកគេ ១) ធ្វើចំណាកស្រុកតាមច្រកទ្វារអន្តរជាតិ ឬក្នុងប្រទេស ដោយមាន ឬគ្មានឪពុកម្តាយ ឬអាណាព្យាបាលជាចំបង ផ្សេងទៀត ២) កុមារកើតពីឪពុកម្តាយទេសន្តប្រវេសន៍នៅក្នុងប្រទេសគោលដៅ ឬ ៣) ស្ថិតនៅក្នុងប្រទេសដើមបន្ទាប់ពីឪពុកម្តាយម្នាក់ ឬទាំងពីរបានធ្វើចំណាកស្រុក[41]។ សិទ្ធិទាំងនេះ គួរត្រូវបានធានាដោយគ្មានការរើសអើង មិនកំណត់អាយុ ភេទ ដើមកំណើតសង្គម សញ្ជាតិ កំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមារ ឬឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារឡើយ។ នៅក្នុងសេចក្តីអធិប្បាយរួមលេខ ២៣ ស្តីពី "កាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងសិទ្ធិមនុស្សរបស់កុមារក្នុងបរិបទទេសន្តប្រវេសន៍អន្តរជាតិនៅក្នុងប្រទេសដើម ប្រទេសសំចតនិងប្រទេសគោលដៅ និងការត្រឡប់មកវិញ" គណៈកម្មាធិការអនុសញ្ញាស្តីពីសិទ្ធិកុមារ ចែងថា អនុសញ្ញាស្តីពីសិទ្ធិកុមារ "កំណត់ថា រដ្ឋភាគីត្រូវគោរព និង ធានាសិទ្ធិដែលមានចែងក្នុងអនុសញ្ញាចំពោះកុមារម្នាក់ៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងគ្រប់ប្រភេទ រួមទាំងការរើសអើងដោយស្ថានភាពទេសន្តប្រវេសន៍របស់ពួកគេ ឬឪពុកម្តាយរបស់ពួកគេ"។ លើសពីនេះ រដ្ឋគួរផ្តល់ការថែទាំ និងកិច្ចការពារសមស្របទៅដល់កុមារក្នុង បរិបទទេសន្តប្រវេសន៍[42]។

**អនុសញ្ញាឆ្នាំ ១៩៩០ ស្តីពីកិច្ចការពារសិទ្ធិពលករទេសន្តប្រវេសន៍ទាំងអស់ និងសមាជិកក្នុងគ្រួសាររបស់ពួកគេ (បានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា តែមិនត្រូវបានផ្តល់សច្ចាប័នដោយប្រទេសថៃ)**។ ក្នុងចំណោមបញ្ហាផ្សេងៗទៀត អនុសញ្ញាចែងថា កូនរបស់ពលករទេសន្តប្រវេសន៍ មានសិទ្ធិទទួលបានឈ្មោះ ការចុះឈ្មោះកំណើត និងទទួលសញ្ជាតិ និងសិទ្ធិទទួលបានការអប់រំដោយមិនគិតពីស្ថានភាពទេសន្តប្រវេសន៍មិនប្រក្រតី។

---

[41] Committee on the Rights of the Child, General comment No. 3 (2017) of the Committee on the Protection of the Rights of All Migrant Workers and Members of Their Families. It was adopted at the same time as joint general comment No. 4 (2017) of the Committee on the Protection of the Rights of All Migrant Workers and Members of Their Families and No. 23 (2017) of the Committee on the Rights of the Child on State obligations regarding the human rights of children in the context of international migration in countries of origin, transit, destination and return.
General comment No. 6, Treatment of unaccompanied and separated children outside their country of origin, 1 September 2005, CRC/GC/2005/6 (CRC Committee GC No. 6 (2005)),

[42] General Comment No. 6 'Treatment of unaccompanied and separated children outside their country of origin', the Committee on the Rights of the Child (CRC Committee) stated, "the enjoyment of rights stipulated in the Convention is not limited to children who are citizens of a State Party and must therefore, if not explicitly stated otherwise in the Convention, also be available to all children – including asylum-seeking, refugee and migrant children – irrespective of their nationality, immigration status or statelessness".

ឧបករណ៍អន្តរជាតិដែលគាំទ្រដល់អនុសញ្ញាស្តីពីសិទ្ធិកុមារ បានបញ្ជាក់បន្ថែមអំពីសិទ្ធិកុមារ និងស្តង់ដារដែលអនុវត្តចំពោះកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ ឧបករណ៍ទាំងនេះរួមបញ្ចូល ពាក់ព័ន្ធខ្លាំងមាន**ពិធីសារជម្រើសស្តីពីការលក់ដូរកុមារ ពេស្យាចារកុមារ និងរូបអាសអាភាស ឆ្នាំ ២០០០ (OPSC) គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ជម្រើសជំនួសការមើលថែទាំកុមារ ឆ្នាំ ២០១០ យុទ្ធសាស្ត្រគំរូរបស់អង្គការសហប្រជាជាតិ និងវិធានការជាក់ស្តែងស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារក្នុងវិស័យទប់ស្កាត់ឧក្រិដ្ឋកម្ម និងយុត្តិធម៌ ឆ្នាំ ២០១៤** និងសេចក្តីអធិប្បាយរួម(លេខ ៤) នៃគណៈកម្មការសិទ្ធិកុមារ និងគណៈកម្មាធិកិច្ចការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកនៃគ្រួសាររបស់ពួកគេទាំងអស់ ដែលបានបោះពុម្ពក្នុងឆ្នាំ ២០១៧: (១) គោលការណ៍ទូទៅទាក់ទងនឹងសិទ្ធិមនុស្សរបស់កុមារក្នុងបរិបទទេសន្តរប្រវេសន៍ និង (២) ពីកាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងសិទ្ធិមនុស្សរបស់កុមារក្នុងបរិបទទេសន្តរប្រវេសន៍អន្តរជាតិនៅក្នុងប្រទេសដើម ប្រទេសសំចត ប្រទេសគោលដៅ និងការត្រឡប់មកវិញ។

ក្រៅពីអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) នៅមាន**អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)** និង**អនុសញ្ញាស្តីពីសិទ្ធិជនដែលមានពិការភាព (CRPD)** ត្រូវបានផ្តល់សច្ចាប័នដោយប្រទេសថៃ និងប្រទេសកម្ពុជា (និងបណ្តាប្រទេសអាស៊ានទាំងអស់)។ អនុសញ្ញា CEDAW សង្កត់ធ្ងន់ថា រាល់ប្រភេទជនទេសន្តរប្រវេសន៍ជាស្ត្រី ត្រូវស្ថិតក្នុងវិសាលភាពកាតព្វកិច្ចរបស់រដ្ឋភាគី។ អនុសាសន៍ទូទៅលេខ ២៦ ណែនាំរដ្ឋឱ្យបង្កើតគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ដោយផ្អែកតាមយេនឌ័រ និងសិទ្ធិ និងលុបការហាម ប្រាម អាយុ ឬការរឹតត្បិតអាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ការមានផ្ទៃពោះ ឬស្ថានភាពមាតុភាព និងបង្កើតឱ្យមានគម្រោងការជួបជុំគ្រួសារឡើងវិញសម្រាប់ពលករទេសន្តរប្រវេសន៍ ដោយមិនមានការរើសអើងភេទ។ អនុសញ្ញា (CRPD) ទទួលស្គាល់ថា ស្ត្រី និងក្មេងស្រីដែលមានពិការភាព តែងតែប្រឈមហានិភ័យខ្លាំងទាំងខាងក្នុង និងក្រៅផ្ទះដោយអំពើហិង្សា របួស ឬការរំលោភបំពាន និងមិនទទួលបាន ការយកចិត្តទុកដាក់ ឬការមិនខ្វល់ ហើយថាកុមារដែលមានពិការភាពទទួលបានសិទ្ធិ និងសេរីភាពជាមូលដ្ឋានពេញលេញ ស្មើភាពគ្នាទៅនឹងកុមារដទៃទៀត។

ពិធីសារ**ទប់ស្កាត់ បង្ក្រាប និងដាក់ទោសលើការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ** បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងត្រូវបានផ្តល់សច្ចាប័នដោយប្រទេសថៃ និងកម្ពុជា (ហៅម្យ៉ាងទៀតថា "ពិធីសារ *Palermo*") មានបទប្បញ្ញត្តិពិសេសដែលអនុវត្តចំពោះបុគ្គល ហើយផ្តោតជាពិសេសចំពោះស្ត្រី និងកុមារដែលធ្លាប់ ឬប្រឈមហានិភ័យនៃការជួញដូរមនុស្ស[43]។ អនុសញ្ញានេះក៏មានគោលបំណងដោះស្រាយតម្រូវការពិសេសរបស់កុមារ រួមទាំងលំនៅដ្ឋានសមរម្យ ការអប់រំ និងការថែទាំ ព្រមទាំងទទួលស្គាល់កត្តាដែលធ្វើឱ្យស្ត្រី និងកុមារងាយរងគ្រោះដោយការជួញដូរ ដូចជា ភាពក្រីក្រ កង្វះការអភិវឌ្ឍន៍ និងកង្វះឱកាសស្មើភាពគ្នា។

[43] General Assembly Resolution 55/25 of 15 November 2000. https://www.un.org/en/development/desa/population/migration/generalassembly/docs/globalcompact/A_RES_55_25.pdf

ការណែនាំផ្សេងៗទៀត រួមមាន **គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ជម្រើសថែទាំកុមារ ឆ្នាំ ២០១០; យុទ្ធសាស្ត្រគំរូរបស់អង្គការសហប្រជាជាតិ និងវិធានការជាក់ស្តែងស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារលើផ្នែកបង្ការឧក្រិដ្ឋកម្ម និងយុត្តិធម៌ព្រហ្មទណ្ឌឆ្នាំ ២០១៤។**

គួរកត់សម្គាល់ផងដែរត្រង់អនុសញ្ញារបស់អង្គការ ILO ជាពិសេស **អនុសញ្ញាអាយុអប្បបរមារបស់អង្គការ ILO** (លេខ ១៣៨) និង**ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ** (លេខ១៨២) ដែលកំណត់អាយុអប្បបរមាសម្រាប់ការងារមួយចំនួន និងប្តេជ្ញាលុបបំបាត់ការប្រើកុមារក្នុងជម្លោះប្រដាប់អាវុធ ពេស្យាចារ និងរូបភាពអាសអាភាស និងសកម្មភាពខុសច្បាប់ ដូចជាការជួញដូរគ្រឿងញៀន និងការងារគ្រោះថ្នាក់។ ទាំងប្រទេសថៃ និងកម្ពុជាបានចូលរួមអនុសញ្ញាទាំងនេះ។

ខណៈដែលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ មិនបញ្ចូលគោលបំណង ឬគោលដៅអំពីទេសន្តរប្រវេសន៍នោះ តែសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពី**របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)**[44] ទទួលស្គាល់ "ការរួមចំណែកជាវិជ្ជមានរបស់ជនទេសន្តរប្រវេសន៍ចំពោះការរីកចម្រើនរួម និងការអភិវឌ្ឍប្រកបដោយចីរភាព"។ ទេសន្តរប្រវេសន៍ទាក់ទងនឹងគោលបំណង និងគោលដៅជាច្រើន ជួយសម្រេចបាននូវបញ្ហាទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ កំណើនសេដ្ឋកិច្ច ការអប់រំ សុខភាព និងសមភាពយេនឌ័រ។ របៀបវារៈឆ្នាំ ២០៣០ សន្យាថា មិនទុកចោលនរណាម្នាក់ឡើយ ដោយសារជនទេសន្តរប្រវេសន៍គឺជាក្រុមងាយរងគ្រោះជា ពិសេស ត្រូវបានផ្តោតជាក់លាក់នៅក្នុងគោលដៅ ៨ ស្តីពីកំណើនសេដ្ឋកិច្ច និងការងារសមរម្យ។ ជនទេសន្តរប្រវេសន៍បំពេញចន្លោះការងារនៅក្នុងប្រទេសម្ចាស់ផ្ទះ ខណៈដែលពួកគេផ្តល់ឱ្យគ្រួសារវិញ តាមរយៈសហគ្រិនភាព និងការច្នៃប្រឌិត ដោយរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ច — គោលដៅ ៥ ស្តីពីសមភាពយេនឌ័រ និងគោលដៅ ១៧.១៦ ស្តីពីការប្រមូលទិន្នន័យ។ ជនទេសន្តរប្រវេសន៍ជាស្ត្រីប្រឈមការរើសអើង និងហានិភ័យអំពើហិង្សា។ ការពង្រឹង និងធានាសុវត្ថិភាព និងឱកាសសម្រាប់ជនទេសន្តរប្រវេសន៍ជាស្ត្រី គឺជាគន្លឹះសំខាន់។ គោលដៅ ១០ មានគោលបំណងសម្របសម្រួលទេសន្តរប្រវេសន៍ប្រកបដោយសណ្តាប់ធ្នាប់ សុវត្ថិភាព ប្រក្រតី និងប្រកបដោយការទទួលខុសត្រូវ តាមរយៈគោលនយោបាយទេសន្តរប្រវេសន៍ដែលមានការគ្រប់គ្រងបានល្អ។ មានសូចនាករចំនួនពីរដើម្បីវាស់វែងវឌ្ឍនភាពគោលដៅ ១០.៧ - (១) តម្លៃជ្រើសរើសបុគ្គលិកដោយនិយោជក គិតសមាមាត្រទៅនឹងប្រាក់ចំណូលប្រចាំឆ្នាំដែលរកបាន (២)ពិនិត្យមើលចំនួនប្រទេសដែលអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ ដែលមានការគ្រប់គ្រងបានល្អ ស្របតាមស្តង់ដារសិទ្ធិមនុស្ស និងការងារអន្តរជាតិ។

ទេសន្តរប្រវេសន៍ ក៏មានឥទ្ធិពលយ៉ាងខ្លាំងដល់គោលដៅ ១ - គឺការលុបបំបាត់ភាពក្រីក្រ។ ការផ្ញើរប្រាក់ដែលផ្ញើដោយជនទេសន្តរប្រវេសន៍ត្រឡប់ទៅប្រទេសកំណើតវិញ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ ការថែទាំសុខភាព និងលំនៅដ្ឋាន។ គោលដៅ

[44] The SDGs' central reference to migration is made in Target 10.7 to facilitate orderly, safe, regular and responsible migration and mobility of people, including through the implementation of planned and well-managed migration policies, which is in Goal 10 to reduce inequality within and among countries. Some other targets also make direct connections to migration topics, including labour migration (8.7 and 8.8), international student mobility (4.b), human trafficking (5.2, 8.7 and 16.2), remittances (10.c), migration data (17.18) and more. https://www.migrationdataportal.org/sdgs?node=0

៤ ស្តីពីការអប់រំប្រកបដោយគុណភាព ពើបប្រសព្វជាមួយឧបសគ្គដែលជនទេសន្តរប្រវេសន៍ជាកុមារ ប្រឈមការទទួលបានការអប់រំ ដោយសារភាសា ស្ថានភាពផ្លូវច្បាប់ ឬបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចសង្គម។ ការធានាឱ្យមានការអប់រំសម្រាប់ទាំងអស់គ្នា រួមទាំងជនទេសន្តរប្រវេសន៍ គឺជាគន្លឹះសំខាន់។ គោលដៅ ១៣ ស្តីពីសកម្មភាពអាកាសធាតុ ទទួលស្គាល់ថា ភាពវិចវិលបរិស្ថាន និងគ្រោះមហន្តរាយ ដែលបង្កើនភាពងាយរងគ្រោះ និងជាកត្តាបង្ខំឱ្យមានការផ្លាស់លំនៅតាមរយៈទេសន្តរប្រវេសន៍។ ការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ដែលបណ្តាលមកពីអាកាសធាតុ មានសារៈសំខាន់ណាស់។ គោលដៅ ១៦ ទាក់ទងនឹងសន្តិភាព យុត្តិធម៌ និងស្ថាប័នមានទំនាក់ទំនងផ្ទាល់ទៅនឹងទេសន្តរប្រវេសន៍ តាមរយៈកិច្ចការពារសិទ្ធិជនទេសន្តរប្រវេសន៍ សិទ្ធិទទួលបានយុត្តិធម៌ និងបរិយាប័ន្នសង្គម សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ក្របខ័ណ្ឌអាស៊ាន និងការប្តេជ្ញាចិត្ត

តំបន់អាស៊ាន គ្របដណ្តប់ប្រទេសចំនួន ១០ រួមមានប្រទេសថៃ និងកម្ពុជា បង្កើតជាប្រទេសដើមប្រទេសសំចត និងប្រទេសទិសដៅ សម្រាប់ទេសន្តរប្រវេសន៍ ដោយប្រទេសខ្លះមានពហុតួនាទី។ ការចល័តរបស់ប្រជាជនក្នុងប្រទេស និងការឆ្លងច្រកទ្វារសំខាន់ៗ មានលក្ខណៈគួរឱ្យកត់សម្គាល់នៅក្នុងតំបន់អាស៊ាន។ ទេសន្តរ
ប្រវេសន៍ និងការផ្លាស់ទីលំនៅជាអន្តរជាតិ និងការផ្លាស់ទីនៅក្នុងប្រទេស ធ្វើឱ្យប៉ះពាល់ដល់ប្រទេសទាំងអស់ក្នុងតំបន់អាស៊ាន[45]។

រដ្ឋសមាជិកអាស៊ាន (រួមទាំងប្រទេសថៃ និងប្រទេសកម្ពុជា) បានប្តេជ្ញាគោរព ការពារ និងបំពេញកាតព្វកិច្ចសិទ្ធិរបស់កុមារទាំងអស់ រួមទាំងអ្នកដែលស្ថិតក្នុងបរិបទទេសន្តរប្រវេសន៍។ ដូចដែលបានពិភាក្សានៅក្នុងការពិនិត្យឡើងវិញនាពេលថ្មីៗនេះដោយអង្គការយូនីសេហ្វ រដ្ឋសមាជិកអាស៊ានបានបង្កើតឧបករណ៍គោលនយោបាយ និងច្បាប់ថ្នាក់ជាតិ ទ្វេភាគី និងថ្នាក់តំបន់ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍[46] ច្បាប់ និងគោលនយោបាយមួយចំនួនអនុវត្តចំពោះប្រភេទក្រុមកុមារជាក់លាក់ ដូចជាកុមាររងគ្រោះដោយការជួញដូរ ឬជនភៀសខ្លួន និងកុមារស្វែងរកសិទ្ធិជ្រកកោន ខណៈដែលច្បាប់ផ្សេងទៀត ជាពិសេស បង្កើតប្រព័ន្ធការពារកុមារ អនុវត្តចំពោះកុមារទេសន្តរប្រវេសន៍ និងកុមារមិនមែន ទេសន្តរប្រវេសន៍ដូចៗគ្នា។

មានកិច្ចខិតខំប្រឹងប្រែងជាច្រើននៅថ្នាក់តំបន់ ត្រូវបានបង្កើតឡើង រួមមានការអនុម័ត**សេចក្តីប្រកាសសិទ្ធិមនុស្សអង្គការអាស៊ាន**[47] រំឭកឡើងវិញនូវសិទ្ធិមនុស្សរបស់ស្ត្រី កុមារ ជនចាស់ជរា ជនដែលមានពិការភាព និងពលករទេសន្តរប្រវេសន៍។

[45] Regional Plan of Action on Implementing the ASEAN Declaration on the Rights of Children in the Context of Migration
[46] Situation Analysis of Children Affected by Migration in ASEAN Member States: Legal Review. UNICEF 2023
[47] ASEAN, 'ASEAN Human Rights Declaration', 19 November 2012

**អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ**[48] មានគោលបំណងបង្កើតទៅជាស្តង់ដារអំពីរបៀបការអនុវត្ត និងការយល់ដឹងអំពីការជួញដូរមនុស្ស ផ្តល់ការណែនាំទប់ស្កាត់ និងគាំទ្រជនរងគ្រោះ រួមទាំងកុមារ និងពង្រឹងវិធានការអនុវត្តច្បាប់។

**ការឯកភាពអាស៊ានលើកិច្ចការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍**[49] ផ្តល់គោលការណ៍ដែលត្រូវប្រកាន់ខ្ជាប់ក្នុងតំបន់ និងជាពិសេសរំឭកឡើងវិញនូវការប្តេជ្ញាចិត្តចំពោះអនុសញ្ញាស្តីពីសិទ្ធិ កុមារ។ នៅកិច្ចប្រជុំលើកទី ១៧ (ខែកញ្ញា ២០២៤) គណៈកម្មាធិការអាស៊ានស្តីពីការអនុវត្តសេចក្តីប្រកាសអាស៊ានលើកិច្ចការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ បានទទួលស្គាល់ថា មានអន្តរកម្មដ៏ស្មុគស្មាញរវាង បម្រែបម្រួលអាកាសធាតុ និងការចល័តរបស់ប្រជាជននៅក្នុងតំបន់អាស៊ាន ដោយទទួលស្គាល់ថា អាស៊ានមានសិទ្ធិច្រើនទៅលើការដោះស្រាយផលប៉ះពាល់អាកាសធាតុ ហើយថា ផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុនេះ គឺជាកត្តាជំរុញឱ្យមានទេសន្តរប្រវេសន៍[50]។

**សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិកុមារក្នុងបរិបទទេសន្តរប្រវេសន៍**[51] (ខែ វិច្ឆិកា ឆ្នាំ ២០១៩) ទទួលស្គាល់ជាពិសេសតម្រូវការក្នុងការ "ដោះស្រាយ និងពង្រឹងប្រព័ន្ធជាតិ រួមទាំងកិច្ចការពារកុមារ ការអប់រំ សុខភាព និងយុត្តិធម៌ និងផ្តល់ការគាំទ្រដល់កុមារទាំងអស់ក្នុងបរិបទទេសន្តរប្រវេសន៍"។ សេចក្តីប្រកាសនេះក៏ "លើកទឹកចិត្តឱ្យមានការបញ្ចូលការគ្រប់គ្រងករណីសម្រាប់កុមារនៅក្នុងបរិបទទេសន្តរប្រវេសន៍ ដោយវិនិយោគ និងកែលម្អ ការប្រមូល និងវិភាគទិន្នន័យ។" សេចក្តីប្រកាសក៏លើកទឹកចិត្តឱ្យរដ្ឋបង្កើត "នីតិវិធីប្រកបដោយប្រសិទ្ធភាព និងជម្រើសជំនួស ការឃុំខ្លួនជនអន្តោប្រវេសន៍ជាកុមារ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការឃុំខ្លួននេះ" ហើយជំរុញឱ្យរដ្ឋនៅក្នុងតំបន់ ធានាឱ្យកុមារនៅជាមួយគ្រួសាររបស់ពួកគេនៅក្នុងបរិយាកាស ដែលគ្មានការ ឃុំឃាំង ហើយប្រកបដោយសុវត្ថិភាព។

**គោលការណ៍ណែនាំអាស៊ានស្តីពីការវិលត្រឡប់ប្រកបដោយប្រសិទ្ធភាព និងសមាហរណកម្មពលករទេសន្តរប្រវេសន៍**[52] រៀបចំយ៉ាងលម្អិតនូវគោលការណ៍ណែនាំសម្រាប់រដ្ឋសមាជិកអាស៊ាន ទាក់ទងនឹងគោលនយោបាយ យន្តការស្ថាប័ន កម្មវិធី និងសេវានានាដែលចាំបាច់ ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងនិរន្តរភាពនៃការវិលត្រឡប់មកវិញ និងសមាហរណកម្មរបស់ពលករទេសន្តរប្រវេសន៍ ស្របតាមស្តង់ដារអន្តរជាតិ និងអង្គការ ILO និងគោលការណ៍ឯកភាពរបស់អាស៊ាន ក្រោមច្បាប់ជាតិដែលកំពុងអនុវត្ត។ គោលការណ៍ណែនាំកត់សម្គាល់ថា បុរស ស្ត្រី ដែលជាពលករទេសន្តរប្រវេសន៍ អាចជួបប្រទះបញ្ហាផ្សេងៗគ្នា ពេញមួយវដ្ត នៃទេសន្តរប្រវេសន៍។ គោលការណ៍នេះក៏រំឭកឡើងវិញនូវគោលការណ៍ទំនួលខុសត្រូវរួមរវាងប្រទេសដើម និងប្រទេសគោលដៅ និងផ្តល់អនុសាសន៍ដល់ការបង្កើតយន្តការសម្របសម្រួលពហុភាគី។ សម្រាប់ការវិលត្រឡប់មកវិញ គោលការណ៍នេះ ផ្តល់ការណែនាំឱ្យមានការសហការសម្រាប់ការត្រឡប់មកវិញប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ អំពាវនាវឱ្យរដ្ឋបញ្ជូន ទទួលជនទេសន្តរប្រវេសន៍ដែលត្រឡប់មកវិញ

[48] ACTIP.pdf
[49] ASEAN, 'ASEAN Consensus on the Protection and Promotion of the Rights of Migrant Workers', February 2012
[50] ASEAN Migration Outlook Calls for Climate-Resilient Migration | IOM Regional Office for Asia and the Pacific
[51] 4-ASEAN-Declaration-on-the-Rights-of-Children-in-the-Context-of-Migration.pdf
[52] 07-ASEAN-Guidelines-on-Effective-Return-and-Reintegration10.pdf

និងផ្តល់សេវានានា និងលើកទឹកចិត្តឱ្យពួកគេចុះឈ្មោះជាមួយអាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីជួយសម្រួលដល់ការទទួលបាន សេវាជំនួយផ្សេងៗ។ គោលការណ៍នេះស្នើឱ្យមានការវាយតម្លៃតម្រូវការដែលត្រូវអនុវត្តនៅថ្នាក់មូលដ្ឋាន ហើយថា ពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់មកវិញ និងក្រុមគ្រួសាររបស់ពួកគេគួរត្រូវបានផ្តល់លទ្ធភាពទទួលបានកិច្ចការពារសង្គម (រួមទាំងការថែទាំសុខភាព) ស្របតាមប្រព័ន្ធថ្នាក់ជាតិ។

**ផែនការសកម្មភាពក្នុងតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ** ទទួលស្គាល់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ (រួមទាំងជនទេសន្តរប្រវេសន៍ជាកុមារ ជនភៀសខ្លួន ការស្វែងរកសិទ្ធិជ្រកកោន កុមារផ្លាស់ទីលំនៅ និង/ឬកុមារដែលត្រូវបានជួញដូរ) ក្នុងចំណោមក្រុមកុមារដែលងាយរងគ្រោះដោយអំពើហិង្សា។

## កិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋសមាជិកអាស៊ាន

កិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋសមាជិកអាស៊ានមួយចំនួន មានគោលបំណងលើកទឹកចិត្តដល់ទេសន្តរប្រវេសន៍ ដើម្បីបំពេញកង្វះកម្លាំងពលកម្មនៅតាមប្រទេសដែលមានសេដ្ឋកិច្ចខ្លាំង ក្នុងតំបន់ ជាពិសេសការងារបណ្តោះអាសន្ន ការងារជំនាញទាប និងប្រាក់ឈ្នួលទាប ក្នុងវិស័យដូចជា កសិកម្ម សំណង់ ការថែទាំសុខភាព និងសេវាឧស្សាហកម្ម ។ ឧទាហរណ៍៖

- អនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងរដ្ឋាភិបាលព្រះរាជាណាចក្រថៃ និងរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីកិច្ចសហប្រតិបត្តិការ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលបានចុះហត្ថលេខាកាលពីខែកក្កដា ឆ្នាំ ២០១៧។
- អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលឡាវ ស្តីពីកិច្ចសហប្រតិបត្តិការការងារ ដែលបានចុះហត្ថលេខាក្នុងខែតុលា ឆ្នាំ២០០២។
- អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលប្រទេសថៃ និងរដ្ឋាភិបាលសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ចុះនៅខែមេសា ឆ្នាំ ២០០៩[53]។
- អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលសាធារណៈរដ្ឋសហភាពមីយ៉ាន់ម៉ា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីការពារកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ដែលជាសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលរៀងៗខ្លួន នៅក្នុងកិច្ចពិភាក្សាកម្រិតខ្ពស់នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០២០។
- ប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី មានអនុស្សរណៈនៃការយោគយល់គ្នាចំនួនពីរ ដើម្បីសហការគ្នាឱ្យកាន់តែប្រសើរឡើងលើបញ្ហាការងារ និងពលករទេសន្តរប្រវេសន៍ ដែលបង្កើតឡើងក្នុងឆ្នាំ ២០១៥ និងបន្តនៅឆ្នាំ ២០២៣។ អនុស្សរណៈនៃការយោគយល់គ្នាទីមួយ ផ្តោតលើការកែលម្អលក្ខខណ្ឌជ្រើសរើស និងការងាររបស់ពលករទូទៅ និងការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេ ខណៈអនុស្សរណៈនៃការយោគយល់គ្នាទីពីរ លើកឡើងអំពីបញ្ហាជាក់លាក់របស់ស្ត្រីពលករដែលធ្វើការតាមផ្ទះជាសញ្ជាតិកម្ពុជានៅក្នុងប្រទេសម៉ាឡេស៊ី។ អនុស្សរណៈនៃការយោគយល់គ្នានេះ គ្រោងនឹងបង្កើតក្របខ័ណ្ឌថ្មី

[53] https://www.thaianti-humantraffickingaction.org/Home/wp-content/uploads/2014/12/MoU-between-govt-of-Thailand-and-govt-of-Myanmar-on-Cooperation-to-Combat-Trafficking-in-Persons-Especially-Women-and-Children.pdf

សម្រាប់ការជ្រើសរើស អាជីព និងការធ្វើមាតុភូមិនិវត្តន៍សម្រាប់ប្រភេទក្រុមពលករពិសេសនេះ ជាចំនួនតំណាងឱ្យជនទេសន្តរប្រវេសន៍កម្ពុជាភាគច្រើននៅក្នុងប្រទេសម៉ាឡេស៊ី។

- អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលរាជាណាចក្រថៃ ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគីសម្រាប់ការលុបបំបាត់ការជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះនៃការជួញដូរ ចុះនៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៤។

កិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធបំផុតរវាងប្រទេសថៃ និងកម្ពុជា គឺជា អនុស្សរណៈនៃការយោគយល់គ្នា **(MoU) រវាងរដ្ឋាភិបាលកម្ពុជា**។ អនុស្សរណៈនៃការយោគយល់គ្នា (MOU) កំណត់យ៉ាងច្បាស់ថា កុមារ និងស្ត្រីដែលត្រូវបានជួញដូរ នឹងមិនត្រូវបាននិរទេសទេ ហើយការធ្វើមាតុភូមិនិវត្តន៍ណាមួយនឹងប្រព្រឹត្តទៅដើម្បីជាឧត្តមប្រយោជន៍ និងសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូរបស់ពួកគេ។ អនុស្សរណៈយោគយល់គ្នានេះ គូសបញ្ជាក់ពីការផ្ដល់ជំនួយចិត្តសាស្ត្រសង្គម វេជ្ជសាស្ត្រ និងជំនួយផ្សេងៗទៀតដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។

**ស្តង់ដារនីតិវិធីប្រតិបត្តិ** (SOPS) ស្ដីពី**ការគ្រប់គ្រងករណីធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញសម្រាប់ជនរងគ្រោះនៃការជួញដូរមនុស្ស** បង្កើតគោលការណ៍ណែនាំរួមរវាងប្រទេសថៃ និងប្រទេសកម្ពុជា សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មឡើងវិញដល់ជនរងគ្រោះដោយការជួញដូរ។ ស្តង់ដារនីតិវិធីប្រតិបត្តិ (SOP) កំណត់តួនាទី និងទំនួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ ទាក់ទងនឹងដំណើរការសមាហរណកម្ម និងការធ្វើមាតុភូមិនិវត្តន៍។ ឯកសារនេះមានគោលការណ៍ណែនាំ (វិធីសាស្ត្រផ្ដោតលើជនរងគ្រោះ វិធីសាស្ត្រផ្អែកលើសិទ្ធិ វិធីសាស្ត្រស្វែងរកព័ត៌មានបួសស្នាម ឯកជនភាព និងការសម្ងាត់ និងគោលការណ៍មិនបន្លំ)។ ស្តង់ដារនីតិវិធីប្រតិបត្តិ (SOP) នេះ កំណត់តួនាទី និងការទទួលខុសត្រូវរបស់ប្រទេសនីមួយៗ រួមទាំងការផ្ដល់ជំនួយផ្នែកច្បាប់។

បន្ថែមលើនេះ **សៀវភៅណែនាំស្ដីពីការធ្វើមាតុភូមិនិវត្តន៍ដែលពិពណ៌នាអំពីលំហូរ និងនីតិវិធីធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ**មកកម្ពុជាត្រូវបានបង្កើតឡើងនៅក្នុងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សក្នុងប្រទេសថៃ។ សៀវភៅណែនាំមានឧបករណ៍ជាក់ស្តែងសម្រាប់ការសម្ភាសន៍បឋម ទម្រង់ជូនដំណឹងអំពីអ្នកដែលត្រូវបានជួញដូរ និងផ្ដល់ព័ត៌មានអំពីសិទ្ធិរបស់អ្នកដែលត្រូវបានជួញដូរ[54]។

## ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយពាក់ព័ន្ធនៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជា លើកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍

| ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយពាក់ព័ន្ធក្នុងប្រទេសថៃ និងប្រទេសកម្ពុជា។ | |
|---|---|
| ប្រទេសថៃ | ប្រទេសកម្ពុជា |
| ច្បាប់អន្តោប្រវេសន៍ | |

[54] Repatriation Handbook for Foreign Victims of Trafficking (2019)

| ច្បាប់អន្តោប្រវេសន៍ (ឆ្នាំ ១៩៧៩) | ច្បាប់អន្តោប្រវេសន៍ (ឆ្នាំ ១៩៩៤) |
|---|---|
| យោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ជនគ្មានរដ្ឋនៅក្នុងប្រទេសថៃ ជាទូទៅ ត្រូវបានចាត់ទុកថាជា "ជនអន្តោប្រវេសន៍" តាមមាត្រា ៤ នៃច្បាប់នេះ។ ដូច្នេះ ចំណុចនេះក្លាយជាកម្មវត្ថុនៃការចាប់ខ្លួន ការឃុំខ្លួន និងការនិរទេសចំពោះករណីចូលក្នុងប្រទេស និងការស្នាក់នៅដោយគ្មានការអនុញ្ញាត។<br><br>មាត្រា ៥៤ ស្តីពីច្បាប់អន្តោប្រវេសន៍ ផ្តល់សិទ្ធិឱ្យមានការនិរទេសជនបរទេស ដែលចូលក្នុងប្រទេស ឬការស្នាក់នៅដោយគ្មានការអនុញ្ញាត។ មាត្រា ៥៤ ក៏ផ្តល់ឱ្យអាជ្ញាធរមានអំណាចសម្រេចទូលំទូលាយក្នុងការគ្រប់គ្រងជនអន្តោប្រវេសន៍ដែលគ្មានការអនុញ្ញាតរួមទាំងកុមារ មុនពេលនិរទេសពួកគេដោយ (១) បញ្ជាឱ្យពួកគេស្នាក់នៅកន្លែងណាមួយដែលកំណត់ដោយនៅក្រៅឃុំ ហើយបញ្ជាឱ្យរាយការណ៍ទៅមន្ត្រីមានសមត្ថកិច្ច ឬ (២) ឃុំខ្លួនពួកគេ "នៅកន្លែងមួយ" ប្រសិនចាំបាច់។<br>ប្រជាជនមកពីប្រទេសភូមា ប្រទេសឡាវ និងប្រទេសកម្ពុជា ស្ថិតក្រោមដំណើរការខុសៗគ្នា។ មាត្រា ១៩ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ចែងថា "ក្នុងការចុះត្រួតពិនិត្យ និងពិចារណាថា តើជនបរទេសត្រូវបានហាមឃាត់មិនឱ្យចូលប្រទេសថៃ ឬយ៉ាងណា ដូច្នេះ មន្ត្រីមានសមត្ថកិច្ចត្រូវមានសិទ្ធិអនុញ្ញាតិឱ្យជនបរទេសទាំងនោះស្នាក់នៅកន្លែងមួយសមរម្យ។ | មាត្រា ១៩៖ ត្រូវអនុវត្តតាមច្បាប់ការងារ។<br>មាត្រា ២៩៖ អនុញ្ញាតឲ្យជាប់ពន្ធនាគារពី ៣ ទៅ ៦ ខែ ចំពោះជនណាដែលចូលមកប្រទេសកម្ពុជាដោយសម្ងាត់ ឬដោយការក្លែងបន្លំ មុននឹងបណ្តេញចេញ។<br><br>មាត្រា ២៥ ផ្តល់អំណាចដល់ក្រសួងមហាផ្ទៃបណ្តេញជនល្មើសច្បាប់អន្តោប្រវេសន៍ រួមទាំងចូលមកខុសច្បាប់។ |
| **ការឃុំខ្លួន** | |
| **អនុស្សរណៈនៃការយោគយល់គ្នា ដើម្បីបញ្ចប់ការឃុំខ្លួនជនទេសន្តរប្រវេសន៍ នៅមណ្ឌលឃុំខ្លួនជនអន្តោប្រវេសន៍។** ប្រទេសថៃ គ្មានបទប្បញ្ញត្តិច្បាប់ណាដែលហាមឃាត់ការឃុំខ្លួនកុមារទេសន្តរប្រវេសន៍នោះទេ។ នៅថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៩ ស្ថាប័នថៃចំនួន ២៦ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីបញ្ចប់ការឃុំខ្លួនកុមារទេសន្តរប្រវេសន៍ នៅមណ្ឌលឃុំឃាំងអន្តោប្រវេសន៍។ គោលការណ៍ទូទៅនៃអនុស្សរណៈនៃការយោគយល់គ្នា រួមមាន៖ ដើម្បីទទួលស្គាល់ថា ការ | |

| | |
|---|---|
| ឃុំខ្លួនកុមារគួរត្រូវបានប្រើជាវិធានការនៃមធ្យោបាយចុងក្រោយតែប៉ុណ្ណោះ និងសម្រាប់រយៈពេលខ្លីបំផុត; និងផ្តល់ក្របខ័ណ្ឌសម្រាប់ជម្រើសនៃការឃុំឃាំងកុមារទេសន្តរប្រវេសន៍ និងម្តាយរបស់ពួកគេ។ | |
| **អនុស្សរណៈនៃការយោគយល់គ្នា (MOU) លើស្តង់ដារនីតិវិធីប្រតិបត្តិ (ការឃុំខ្លួន)**<br>ផ្តល់អាទិភាពដល់ការប្រើប្រាស់ជម្រើសសម្រាប់ការឃុំខ្លួនកុមារក្នុងស្ថានភាពងាយរងគ្រោះ។ "កុមារមិនត្រូវឃុំខ្លួនឡើយ លើកលែងតែក្នុងកាលៈទេសៈចាំបាច់ និងមិនអាចជៀសវាងបាន។ ដោយហេតុនេះ ពួកគេអាចនឹងត្រូវឃុំខ្លួននៅណ្តូលឃុំឃាំងអន្តោប្រវេសន៍ ជាមធ្យោបាយចុងក្រោយ និងក្នុងរយៈពេលខ្លីបំផុត។" មាត្រា ៤,៤ ចែងថា "ក្នុងការកំណត់វិធីផ្តល់ការថែទាំកុមារ ការថែទាំតាមគ្រួសារត្រូវផ្តល់អាទិភាពជាទីមួយ។ មណ្ឌលទទួលកុមាររបស់ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ឬមណ្ឌលទទួលកុមារដែលដំណើរការដោយក្រុមហ៊ុនឯកជន ដែលបានចុះបញ្ជីនៅក្រោមច្បាប់ពាក់ព័ន្ធ ត្រូវចាត់ជាកន្លែងចុងក្រោយ និងប្រើក្នុងរយៈពេលខ្លីបំផុត។" | |
| **អត្រានុកូលដ្ឋាន** | |
| **ច្បាប់អត្រានុកូលដ្ឋានថៃឆ្នាំ ២០០៨**<br>កំណត់ថាកុមារណាដែលកើតក្នុងប្រទេស រួមទាំងកុមារកើតក្នុងគ្រួសារជនទេសន្តរប្រវេសន៍មិនប្រក្រតីក្តី ក៏អាចទទួលបានសំបុត្រកំណើត | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិសំខាន់ៗ និងអត្តសញ្ញាណកម្ម (២០២៣) កុមារណាដែលកើតនៅក្នុងប្រទេសអាចចុះឈ្មោះកំណើត និងទទួលបានសំបុត្រកំណើតដោយចុះឈ្មោះនៅឃុំ/សង្កាត់។ |
| **គោលនយោបាយស្តីពីសញ្ជាតិថៃ ខែមីនា ឆ្នាំ ២០១៧**<br>គោលនយោបាយត្រូវបានអនុម័តអនុញ្ញាតឱ្យជនទេសន្តរប្រវេសន៍ កើតក្នុងប្រទេសថៃ និងកុមារគ្មានរដ្ឋអាចដាក់ពាក្យសុំសញ្ជាតិថៃនៅពេលបញ្ចប់ការសិក្សាពីសកលវិទ្យាល័យថៃ។ | |
| **ច្បាប់ការងារ** | |
| **ច្បាប់ការពារការងារ**<br>អាយុអប្បបរមាសម្រាប់ការងារនៅក្នុងប្រទេសថៃគឺអាយុ ១៥ ឆ្នាំ ហើយពលករដែលមានអាយុក្រោម ១៨ ឆ្នាំត្រូវបានហាមឃាត់មិនឱ្យធ្វើការក្នុងការងារដែលមានគ្រោះថ្នាក់ និងគ្មានសុវត្ថិភាព។ | **ច្បាប់ការងារ (១៩៩៧)**<br>អាយុអប្បបរមាដែលអាចអនុញ្ញាតធ្វើការ នៅអាយុ ១៥ ហើយកម្មករដែលមានអាយុក្រោម ១៨ ឆ្នាំត្រូវបានហាមឃាត់ពីការងារដែលបង្កគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌។ |

| | |
|---|---|
| **ព្រះរាជក្រឹត្យរបស់ប្រទេសថៃ ស្តីពីការគ្រប់គ្រងពលករបរទេស។** ក្រឹត្យនេះតម្រូវឱ្យពលករបរទេសនៅប្រទេសថៃត្រូវមានលិខិតឆ្លងដែន និងលិខិតអនុញ្ញាតការងារ។ | មាត្រា ២៦១ ចែងថា គ្មានជនជាតិបរទេសណាម្នាក់អាចធ្វើការបាន លុះត្រាតែពួកគេមានប័ណ្ណអនុញ្ញាតការងារ និងប័ណ្ណការងារ។ |
| | |
| **កិច្ចការការពារកុមារ** | |
| **ច្បាប់ការពារកុមាររបស់ប្រទេសថៃ**<br>ច្បាប់ការពារកុមាររបស់ប្រទេសថៃ ទាមទារឱ្យមានការប្តេជ្ញាចិត្តលើឧត្តមប្រយោជន៍ដល់កុមារ ដើម្បីប្រព្រឹត្តចំពោះកុមារណាមួយ (ហើយដូច្នេះនឹងរួមបញ្ចូលកុមារទេសន្តរ ប្រវេសន៍ និងកុមារដែលរងផលប៉ះពាល់ដោយទេសន្តរ ប្រវេសន៍ទូលំទូលាយ) និងការពិនិត្យយោងលើការអនុវត្តគោលការណ៍ណែនាំ។ គោលការណ៍ណែនាំនៅក្នុងបទបញ្ជារបស់ក្រសួង ទាក់ទងនឹងច្បាប់ការពារកុមារ រាយបញ្ជីកត្តាជាច្រើន ដែលត្រូវតែយកទៅពិចារណានៅពេលកំណត់ថាតើទង្វើណាមួយស្ថិតក្នុង ឧត្តមប្រយោជន៍ដល់កុមារដែរឬទេ។ ទាំងនេះរួមមានការការពារកុមារពីអំពើហិង្សា គ្រោះថ្នាក់ និងការកេងប្រវ័ញ្ច និងការផ្តល់ឱកាសឱ្យកុមារចូលរួមក្នុងការសម្រេចចិត្តណាដែលប៉ះពាល់ដល់ពួកគេ។ | **សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការការពារកុមារ**<br>ប្រទេសកម្ពុជាមានច្បាប់ការពារកុមារក្នុងទម្រង់ជាពង្រៀង។ សេចក្តីព្រាងច្បាប់នេះកំពុងស្ថិតក្រោមការត្រួតពិនិត្យ ហើយទាមទារឧត្តមប្រយោជន៍ដល់កុមារ ហើយផ្តល់ការណែនាំដល់ថ្នាក់ខេត្ត ស្រុក និងឃុំក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងកិច្ចការពារកុមារ។ |
| **គោលនយោបាយសិក្សាអប់រំ** | |
| **ប្រទេសថៃ** | **ប្រទេសកម្ពុជា** |
| **ការអប់រំគោលនយោបាយឆ្នាំ ១៩៩៥ ប្រទេសថៃសម្រាប់ទាំងអស់គ្នា៖**<br>ដំណោះស្រាយនេះ ធានាការទទួលបានការអប់រំដោយឥតគិតថ្លៃរយៈពេល ១៥ ឆ្នាំសម្រាប់កុមារទាំងអស់ក្នុងប្រទេសដោយមិនគិតពីសញ្ជាតិ ឯកសារ ឬស្ថានភាពផ្លូវច្បាប់។ | **មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការអប់រំជាតិ**<br>ធានាការអប់រំជាមូលដ្ឋានដល់ថ្នាក់ទី ៩ ដោយមិនគិតថ្លៃសម្រាប់ប្រជាជនកម្ពុជាដែលមានសិទ្ធិគ្រប់រូប។ |
| **ដំណោះស្រាយគណៈរដ្ឋមន្ត្រីឆ្នាំ ២០០៥ ស្តីពីការផ្តល់ការអប់រំសម្រាប់ជនដែលគ្មានឋានៈស្របច្បាប់ ឬសញ្ជាតិថៃ**<br>ប្រទេសថៃបានធានាសិទ្ធិទទួលបានការសិក្សាអប់រំដល់កុមារទេសន្តរប្រវេសន៍ និងកុមារគ្មានរដ្ឋ។ | **ផែនការយុទ្ធសាស្ត្រអប់រំ** ២០២៤- ២០២៨ កត់សម្គាល់ពីសារៈសំខាន់នៃការផ្តល់ការប្រឹក្សា និងការគាំទ្រដល់សិស្សដែលងាយរងគ្រោះ ដែលរងផលប៉ះពាល់ទេសន្តរប្រវេសន៍។ |
| **សេចក្តីប្រកាសរបស់រដ្ឋមន្ត្រីឆ្នាំ ២០១៨**<br>បានដកឧបសគ្គឯកសារទាំងឡាយ ដែលពីមុនរារាំងកុមារ | |

| | |
|---|---|
| ទេសន្តរប្រវេសន៍ ពីការចុះឈ្មោះចូលរៀននៅសាលារដ្ឋរបស់ថៃ៖ ការចុះឈ្មោះលែងត្រូវការឯកសារផ្លូវការហើយ កុមារទាំងអស់ ដោយមិនគិតពីសញ្ជាតិ អាចចុះឈ្មោះចូលរៀន។ កុមារនឹងទទួលបានលេខកូដជាអក្សរ G ដែលបំប្លែងទៅជាលេខ១៣ខ្ទង់ ហើយនឹងក្លាយជាលេខអត្តសញ្ញាណប័ណ្ណជាតិ | |
| **ដំណោះស្រាយគណៈរដ្ឋមន្ត្រីឆ្នាំ ២០០៥ ស្តីពីការផ្តល់ការអប់រំសម្រាប់ជនដែលគ្មានឋានៈស្របច្បាប់ ឬសញ្ជាតិថៃ។** ធានាសិទ្ធិ ទទួលបានការអប់រំដោយឥតគិតថ្លៃរយៈពេល ១៥ ឆ្នាំសម្រាប់កុមារទាំងអស់ក្នុងប្រទេសដោយមិនគិតពីសញ្ជាតិ ឯកសារ ឬស្ថានភាពផ្លូវច្បាប់។ | |
| **សុខភាព** | |
| ប្រព័ន្ធសុខភាពសាធារណៈ៖ ពលករទេសន្តរប្រវេសន៍ប្រក្រតី មានសិទ្ធិទទួលបានការថែទាំឧបត្ថម្ភពីប្រព័ន្ធសុខភាពសាធារណៈរបស់ប្រទេសថៃ | **គោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពជនទេសន្តរប្រវេសន៍៖** លើកកម្ពស់សិទ្ធិទេសន្តរប្រវេសន៍ក្នុងការទទួលបានសេវាសុខភាព ដូចគ្នាទៅនឹងសាធារណជនទូទៅដែរ។ កត់សម្គាល់ពីសារៈសំខាន់លើសេវាកម្មបកប្រែ |
| **គម្រោងធានារ៉ាប់រងសុខភាពទេសន្តរប្រវេសន៍** [55] ពលករទេសន្តរប្រវេសន៍មិនប្រក្រតី អាចចុះឈ្មោះទទួលការធានារ៉ាប់រងសុខភាពដោយបង់ថ្លៃជាប្រចាំឆ្នាំ។ | |

## ក្តីបារម្ភ និងបញ្ហារបស់កុមារដែលចេញទៅប្រទេសថៃ

ផ្នែកក្នុងរបាយការណ៍នេះផ្តោតទៅលើបទពិសោធន៍របស់កុមារ ក្រុមគ្រួសារ និងអ្នកថែទាំរបស់ពួកគេដែលកំពុងធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃ។ កុមារដែលទុកនៅស្រុកកំណើតក៏ជាកង្វល់ធំមួយដែរ។ ការពិនិត្យឯកសារឡើងវិញ រួមបញ្ចូលការស្រាវជ្រាវកុមារដែលទុកនៅស្រុកកំណើត ហើយព័ត៌មានលម្អិតអំពីកុមារទាំងនោះ មាននៅក្នុងឧបសម្ព័ន្ធ២។

កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ទៅប្រទេសថៃ អាចជាកុមារទៅដល់ប្រទេសថៃជាមួយឪពុកម្តាយរបស់ពួកគេហើយ ឬប្រហែលបានធ្វើដំណើរតែម្នាក់ឯង ហើយក៏មានកុមារដែលកើតនៅប្រទេសថៃផងដែរ។ ជនទេសន្តរប្រវេសន៍ទៅប្រទេសថៃ ភាគច្រើនត្រូវបានគេគិតថា ទៅដោយមធ្យោបាយមិនប្រក្រតី ហើយមិនមានកំណត់ត្រាច្បាស់លាស់នៃចំនួនកុមារកម្ពុជាដែលរស់នៅក្នុងប្រទេសថៃនោះទេ ដោយសារតែ

[55] Migrant Health - World Vision Thailand

បញ្ហាប្រឈមនឹងការកំណត់ចំនួនគំរូទេសន្តរប្រវេសន៍មិនប្រក្រតី។ សូម្បីតែឪពុកម្តាយដែលមានស្ថានភាពស្របច្បាប់ក៏ប្រហែលជាមិនមានឯកសារសម្រាប់កូនៗរបស់ពួកគេយកទៅជាមួយដែរ។

ទោះបីទេសន្តរប្រវេសន៍អាចផ្តល់ផលប្រយោជន៍ដល់កុមារ និងគ្រួសាររបស់ពួកគេក្តី វាក៏អាចធ្វើឱ្យកុមាររងស្ថានភាពគ្រោះថ្នាក់ផងដែរ។ មានកុមារខ្លះរងហានិភ័យដូចជាកុមារដែលទុកនៅស្រុកកំណើត កុមារខ្លះទៀតរងស្ថានភាពផ្សេងៗទៀត ដែលមានស្ថានភាពកាន់តែធ្ងន់ធ្ងរដោយបញ្ហាភាសា ការរើសអើង ការបំបែកចេញពីគ្រួសារ និងប្រព័ន្ធគាំទ្រនៅក្នុងប្រទេសកម្ពុជា ឬកត្តាផ្សេងទៀតជាដើម។ កុមារ និងគ្រួសារដែលងាយរងគ្រោះ រួចទៅហើយ ដោយសារភាពក្រីក្រ ការប្រែប្រួលអាកាសធាតុ និងកត្តាផ្សេងៗទៀត អាចប្រឈមនឹងបញ្ហាធំៗ។ លើសពីនេះ កុមារដែលមានពិការភាព អាចស្ថិតក្នុងចំណោមកុមារងាយរងគ្រោះបំផុត។ ពួកគេប្រឈមនឹងការខ្វះខាតជីវិតប្រចាំថ្ងៃ។ ទេសន្តរប្រវេសន៍អាចធ្វើឱ្យកាន់តែធ្ងន់ធ្ងរដល់ពិការភាពដែលមានស្រាប់ ហើយញឹកញាប់តម្រូវការរបស់ពួកគេមិនត្រូវបានរាប់បញ្ចូលក្នុងដំណើរការរៀបចំផែនការនោះទេ[56]។

## ទេសន្តរប្រវេសន៍មិនប្រក្រតី

*"ពលករទេសន្តរប្រវេសន៍មួយចំនួន អាចជំពាក់បំណុលគេដើម្បីសងមេខ្យល់ឬអ្នករត់ពន្ធ ដោយខ្ចីពីអ្នកផ្ញើកម្ចីគ្មានច្បាប់ យកទៅបង់ថ្លៃឆ្លងច្រកទ្វារ តាមមធ្យោបាយមិនប្រក្រតី។ នៅពេលដែលជំពាក់បំណុលគេហើយ ជនទេសន្តរប្រវេសន៍មួយចំនួនមានជម្រើសតិចតួច ក្រៅពីរងការកេងប្រវ័ញ្ច ដូចជាពលកម្មដោយបង្ខំ ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានដើម្បីសងបំណុលទាំងនេះ។"* ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ពីអ្នកផ្តល់សេវា NGO

*"ជារឿយៗ ដំណើរទេសន្តរប្រវេសន៍ខុសច្បាប់លឿន ហើយនៅពេលទៅដល់ក្នុងប្រទេសថៃ ពួកគេអាចផ្លាស់ប្តូរការងារដោយមិនឆ្លងកាត់បណ្តាញផ្លូវច្បាប់ណាមួយឡើយ"* ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ពីអ្នកផ្តល់សេវាអង្គការមិនមែនរដ្ឋាភិបាល

*"សម្រាប់ទេសន្តរប្រវេសន៍ខុសច្បាប់ មេខ្យល់ប្រទេសទាំងពីរធ្វើការជាមួយគ្នា – មានកត្តាដូចជាភាពក្រីក្រ និងបំណុលជំរុញឱ្យមានទេសន្តរប្រវេសន៍។ ទេសន្តរប្រវេសន៍ច្បាប់ត្រូវចំណាយប្រាក់ច្រើន និងស៊ីពេលវេលា។ ពួកគេក៏ខ្វះព័ត៌មានផងដែរ"*។ ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ពីមន្ត្រីរដ្ឋាភិបាល

ក្នុងការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ ត្រូវបានគេរាយការណ៍ថា ទេសន្តរប្រវេសន៍មិនប្រក្រតី អាចជាមធ្យោបាយសំខាន់ទៅកាន់ប្រទេសថៃ ទោះបីជាទិន្នន័យមានតិចតួចក៏ដោយ។ ទោះបីមានក្របខ័ណ្ឌច្បាប់សម្រាប់ការទទួលបានលិខិតឆ្លងដែន ទិដ្ឋាការ និងលិខិតអនុញ្ញាតការងារចាំបាច់ក៏ដោយ ការចំណាយនៃដំណើរការឯកសារទាំងនេះ រួមជាមួយនឹងការចំណាយធ្វើដំណើរ ការស្វែងរកការងារ និងការខ្វះចំណេះដឹងអំពីដំណើរការ និងពេលវេលា បានជំរុញឱ្យពួកគេធ្វើទេសន្តរ

[56] Included Every Step of the Way: Upholding the rights of migrant and displaced children with disabilities - UNICEF DATA

ប្រវេសន៍ដោយគ្មានឯកសារត្រឹមត្រូវ។ ការឆ្លងកាត់ព្រំដែនអាចមានគ្រោះថ្នាក់ដល់កុមារ ដោយបង្ខំឱ្យពួកគេមួយចំនួនឆ្លងតាមច្រកដាច់ស្រយាលខុសច្បាប់ ដើម្បីគេចចេញពីប៉ុស្តិ៍ត្រួតពិនិត្យ។ ចំណុចនេះអាច បណ្តាលឱ្យពួកគេប្រឈមហានិភ័យ រួមទាំងការជួញដូរមនុស្ស ការរំលោភបំពាន និងគ្រោះថ្នាក់ផ្សេងៗ។

សូម្បីតែឪពុកម្តាយដែលមានស្ថានភាពស្របច្បាប់ ក៏ប្រហែលជាមិនមានឯកសារសម្រាប់កូនៗរបស់ពួកគេយក ទៅជាមួយដែរ។ ជាលទ្ធផល ទេសន្តរប្រវេសន៍មិនប្រក្រតី បាននាំឱ្យមានស្ថានភាពរស់នៅមិនច្បាស់លាស់ខ្លាំងសម្រាប់កុមារជាច្រើន និងគ្រួសាររបស់ពួកគេនៅក្នុងប្រទេសថៃ ខណៈដែលពួកគេព្យាយាមបត់បែនការរស់នៅដោយគ្មានកិច្ចការពារ និងសេវាគាំទ្រ ខុសពីអ្នករស់នៅស្របច្បាប់ទទួលបានជាធម្មតា។ អ្នកដែលគ្មានស្ថានភាពស្របច្បាប់ក្នុងប្រទេសថៃ ងាយរងគ្រោះជាពិសេសបើប្រៀបធៀបទៅនឹងជនទេសន្តរ ប្រវេសន៍ ដែលបានធ្វើ ប្រក្រតីភាពស្ថានភាពរបស់ពួកគេ[57]។ លើសពីនេះ ជនទេសន្តរប្រវេសន៍មិនប្រក្រតី អាចស្នាក់នៅលើស ឬផ្លាស់ប្តូរការងារ ដែលប័ណ្ណការងាររបស់ពួកគេមិនអាចប្រើប្រាស់បានទៀត។

តាមការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) បញ្ហាប្រឈមដែលត្រូវបានរាយការណ៍ គឺជាព័ត៌មានមិនពិតអំពីការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់។ អ្នកដែលមានបំណងធ្វើទេសន្តរប្រវេសន៍ អាចទទួលបានព័ត៌មានតិចតួចអំពីវិធីធ្វើទេសន្តរប្រវេសន៍ស្របច្បាប់។ អ្នកផ្តល់ព័ត៌មានសំខាន់ៗបានរាយការណ៍ថា មានចន្លោះប្រហោងក្នុងការផ្សព្វផ្សាយព័ត៌មាន។ ឧទាហរណ៍ ផែនការអភិវឌ្ឍន៍ឃុំជាច្រើនមិនបញ្ចូលសកម្មភាពការយល់ដឹងអំពីទេសន្តរប្រវេសន៍នៅថ្នាក់មូលដ្ឋាន ដែលអាចនាំទៅដល់ទេសន្តរប្រវេសន៍ប្រកប ដោយសុវត្ថិភាព។

## ការមើលថែកុមារ

> *"ជាធម្មតា កុមាររស់នៅក្នុងលំនៅដ្ឋានរៀបជាក្រុម។ ពួកគេអាចស្នាក់នៅផ្ទះតែម្នាក់ឯងនៅពេលថ្ងៃ។ កុមារខ្លះទៅធ្វើការជាមួយឪពុកម្តាយដែលអាចរងស្ថានភាពគ្រោះថ្នាក់។" ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗជាមួយអ្នកផ្តល់សេវាពីអង្គការក្រៅរដ្ឋាភិបាល (KII)*
>
> *ប្រសិនបើពួកគេមានកូន ជាញឹកញាប់ កូនៗមិនទទួលបានការថែទាំត្រឹមត្រូវទេ ពួកគេមិនមានអ្នកមើលថែទាំត្រឹមត្រូវទេ ជួនកាលកូនធំត្រូវមើលប្អូនៗ។ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KII)*

ទោះបីមានការព្រួយបារម្ភជាច្រើននៅក្នុងអត្ថបទស្រាវជ្រាវ អំពីកុមារដែលទុកនៅស្រុកជាមួយសាច់ញាតិចាស់ៗក៏ដោយ កុមារដែលធ្វើទេសន្តរប្រវេសន៍ជាមួយឪពុកម្តាយរបស់ពួកគេក៏ត្រូវបានរាយការណ៍ថា ក៏ប្រឈមនឹងការរៀបចំការថែទាំមិនគ្រប់គ្រាន់ផងដែរ។ តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) ប្រាប់ថា កុមារអាចត្រូវបានទុកចោលដោយគ្មានការមើលខុសត្រូវពីមនុស្សធំនៅក្នុងលំនៅដ្ឋានបណ្តោះអាសន្នរបស់ពួកគេ ឬអាចត្រូវបាននាំយកទៅកន្លែងធ្វើការ។ កុមារតូចៗក៏អាចត្រូវទុកឱ្យកូនបងជួយមើលថែ។

[57] https://www.unhcr.org/countries/thailand

កុមារដែលត្រឡប់ពីប្រទេសថៃវិញ ទោះក្នុងកាលៈទេសៈណាក៏ដោយ ក៏អាចប្រឈមនឹងការរៀបចំការថែទាំមិនបានគ្រប់គ្រាន់ដែរ។ កុមារដែលត្រឡប់មកវិញជាមួយឪពុកម្ដាយអាចនៅតែប្រឈមនឹងជីវភាពក្រីក្រ និងហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ ឯកុមារដែលត្រឡប់មកវិញដោយគ្មានឪពុកម្ដាយមកជាមួយ អាចត្រូវបានមើលថែដោយសាច់ញាតិចាស់ៗ ដែលប្រហែលជាមិនអាចផ្ដល់ការមើលថែបានគ្រប់គ្រាន់នោះទេ។ កុមារទាំងនេះអាចប្រឈមនឹងហានិភ័យដូចគ្នានឹងកុមារដែលទុកនៅស្រុកកំណើតដែរ។

## ការចុះបញ្ជីកំណើត និងឯកសារច្បាប់

> "ឪពុកម្ដាយទេសន្តរប្រវេសន៍ដែលគ្មានឯកសារ ភ័យខ្លាចទៅចុះឈ្មោះកំណើត។ ពួកគេគិតថា អាជ្ញាធររកពួកគេឃើញ ហើយនិរទេសពួកគេ"។ ការសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ ពីអ្នកផ្ដល់ សេវាអង្គការមិនមែនរដ្ឋាភិបាល

ការចុះបញ្ជីកំណើត ជាសិទ្ធិជាមូលដ្ឋានដែលទទួលស្គាល់ដោយអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ ទោះបីជាសិទ្ធិនេះត្រូវបានគោរពដោយប្រទេសថៃក៏ដោយ ក៏ពលករទេសន្តរប្រវេសន៍ប្រឈមនឹងការចុះបញ្ជីដល់កូនៗរបស់ពួកគេ។ ច្បាប់ចុះអត្រានុកូលដ្ឋានរបស់ប្រទេសថៃឆ្នាំ ២០០៨ ចែងថា កុមារណាដែលកើតក្នុងប្រទេស រួមទាំងកុមារដែលកើតពីជនទេសន្តរប្រវេសន៍មិនប្រក្រតី អាចទទួលបានសំបុត្រកំណើត ប៉ុន្តែបញ្ហាប្រឈមជាក់ស្ដែងនៅតែមាន។ នៅក្នុងការពិនិត្យឯកសារស្រាវជ្រាវ គេកំណត់ថា មានកត្តាដូចជាឧបសគ្គផ្នែកភាសា និងការយល់ដឹងអំពីដំណើរការដាក់ពាក្យមានកម្រិត នៅតែអាចរារាំងកុមារទេសន្តរប្រវេសន៍ពីការទទួលបានឯកសារដ៏សំខាន់ទាំងនេះ។

តាមការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ៗ (KIIs) ត្រូវបានបញ្ជាក់។ បញ្ហាប្រឈមជាច្រើនបានកើតឡើងតាមរយៈការចុះបញ្ជីកំណើតសម្រាប់កុមារកម្ពុជាដែលកើតនៅប្រទេសថៃ។ បញ្ហាទាំងនេះរួមមានគ្រួសារដែលមិនដឹងពីរបៀបចុះបញ្ជីកំណើតនៅប្រទេសថៃ និងខ្លាចពេលទៅ អាជ្ញាធររកពួកគេឃើញ និងនិរទេសប្រសិនបើពួកគេគ្មានស្ថានភាពផ្លូវច្បាប់ច្បាស់លាស់។

បញ្ហាប្រឈមផ្សេងទៀតជាមួយនឹងលទ្ធផលឯកសារផ្លូវច្បាប់ នៅពេលដែលសញ្ជាតិរបស់កុមារមិនអាចស្រាវជ្រាវតាមដានបាន។ ឧទាហរណ៍ បើឪពុកឬម្ដាយជាជនជាតិថៃ និងឪពុកឬម្ដាយម្នាក់ទៀតជាជនខ្មែរម្នាក់ស្លាប់។ ក្នុងស្ថានភាពខ្លះ គ្រួសារមិនអាចស្រាវជ្រាវតាមដានបាន ហើយកត្តានេះបានធ្វើឱ្យមានស្ថានភាពពិបាកក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណកុមារថាជាខ្មែរ ឬថៃ។

ឯកសារផ្លូវច្បាប់ផ្សេងទៀតដែលខ្វះគឺទិដ្ឋាការសម្រាប់កុមារ។ គេរកឃើញថា កុមារអាចខ្វះទិដ្ឋាការសមស្របក្នុងការស្នាក់នៅក្នុងប្រទេសថៃ។ ទោះបីឪពុកម្ដាយមានទិដ្ឋាការ និងប័ណ្ណការងារក៏ដោយ ក៏កូនរបស់ពួកគេប្រហែលជាមិនត្រូវបានរាប់បញ្ចូលក្នុងការរៀបចំឯកសាទាំងនេះទេ ដែលបង្កឱ្យមានភាពប្រថុយប្រថាន។

សម្រាប់ហេតុផលផ្សេងៗដែលបានពិពណ៌នាកន្លងមក កុមារអាចមិនមានឯកសារអត្តសញ្ញាណ។ ឧទាហរណ៍ ពួកគេអាចកើតនៅក្នុងប្រទេសថៃ ហើយគ្រួសាររបស់ពួកគេមិនទទួលបានសំបុត្រកំណើត។ បញ្ហា

នេះបណ្ដាលជាឧបសគ្គដល់កុមារពីលទ្ធភាពធ្វើអត្តសញ្ញាណប័ណ្ណនៅក្នុងប្រទេសកម្ពុជា ហើយនឹងធ្វើឱ្យមានការលំបាកក្នុងការទទួលបានសេវានានា។ ដូចដែលបានកត់សម្គាល់នៅខាងដើមក្នុងរបាយការណ៍នេះ កុមារដែលកើតនៅក្នុងប្រទេសថៃអាចទទួលបានសំបុត្រកំណើត ប៉ុន្ដែជាញឹកញាប់ ឪពុកម្ដាយមានការភ័យខ្លាចក្រែងអាជ្ញាធររកឃើញ ឬក៏ប្រហែលជាពួកគេមិនដឹងពីរបៀបទទួលបានសំបុត្រកំណើតនេះក៏ថាបាន។

## ការសិក្សាអប់រំ

"កុមារទេសន្ដរប្រវេសន៍ជាច្រើនមិនបានចូលរៀនទេ។ ពេលខ្លះ ពួកគេខ្លាចពេលចេញក្រៅ ខ្លាចត្រូវនិរទេស ឬមិនដឹងពីរបៀបចុះឈ្មោះកូនរបស់ពួកគេ"។ ការសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ អង្គការមិនមែនរដ្ឋាភិបាល

*"មជ្ឈមណ្ឌលទទួលជនទេសន្ដរប្រវេសន៍ និងជម្រើសនៃការអប់រំផ្សេងៗទៀត មានប្រយោជន៍ ប៉ុន្ដែកន្លែងទាំងនេះមានលក្ខណៈក្រៅផ្លូវការ។ កន្លែងទាំងនេះមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការផ្ដល់ការអប់រំល្អដល់កុមារនោះទេ"*។ ការសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ អង្គការមិនមែនរដ្ឋាភិបាល

ការអប់រំ គឺជាសិទ្ធិមូលដ្ឋានរបស់មនុស្សដែលមាននៅក្នុង**សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស**។ ប្រទេសថៃបានបោះជំហានទៅមុខក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ ជួយដល់កុមារទេសន្ដរប្រវេសន៍ជាច្រើនបានចុះឈ្មោះចូលរៀននៅសាលារដ្ឋរបស់ប្រទេសថៃ ព្រមទាំងមណ្ឌលថែទាំកុមារតូចនៅតាមសាលារដ្ឋ សាលាឯកជន ការអប់រំក្រៅប្រព័ន្ធ និងមណ្ឌលសិក្សាទេសន្ដរប្រវេសន៍[58]។

ទោះបីប្រទេសថៃមានគោលនយោបាយរីកចម្រើនយ៉ាងណាក៏ដោយ ក៏ការប៉ាន់ប្រមាណបង្ហាញថា អង្គការយូនីសេហ្វ បានកំណត់ចំនួនកុមារច្រើនជាង ៦០ ភាគរយក្នុងឆ្នាំ ២០១៩ [59] កំណត់ថា កុមារទេសន្ដរប្រវេសន៍ មិនមានបានចូលសាលាទេ។ កុមារចំនួនច្រើនជាង ៣០ ភាគរយប៉ុណ្ណោះ បានចូលរៀន ហើយប្រហែល ៥ ភាគរយ ចូលរៀននៅមជ្ឈមណ្ឌលសិក្សាទេសន្ដរប្រវេសន៍[60]។

គេរាយការណ៍ថា មានកុមារទេសន្ដរប្រវេសន៍ប្រឈមនឹងឧបសគ្គធំៗ ដូចជា បញ្ហាភាសា មធ្យោបាយធ្វើដំណើរ កង្វះការយល់ដឹងអំពីដំណើរការចុះឈ្មោះ និងនីតិវិធី ការយល់អវិជ្ជមានចំពោះកុមារទេសន្ដរប្រវេសន៍ បញ្ហាប្រឈមផ្នែករដ្ឋបាលនៅសាលារៀន ក្នុងចំណោមបញ្ហាផ្សេងៗទៀត។ ឧទាហរណ៍ ក្នុងករណីខ្លះទោះបីជាឯកសារមិនចាំបាច់តម្រូវឱ្យមានក៏ដោយ ក៏ជួនកាលសាលាទារឯកសារផ្លូវការទាំងនេះដែរ។

ទន្ទឹមនេះ ជនទេសន្ដរប្រវេសន៍មួយចំនួនខ្វះការយល់ដឹងអំពីសិទ្ធិ និងជម្រើសនៃការអប់រំដែលមានស្រាប់ នីតិវិធីចុះឈ្មោះ និងកាលបរិច្ឆេទចុះឈ្មោះ។ បញ្ហាទាំងនេះត្រូវបានរកឃើញនៅក្នុងការពិនិត្យឯកសារ

[58] Make learning count EN.pdf
[59] https://www.unicef.org/thailand/media/11691/file/Make%20learning%20count%20EN.pdf
[60] Children of Cambodian migrants still denied access to education | Prachatai English

ស្រាវជ្រាវ[61] និងបញ្ជាក់តាមការសម្ភាសន៍ន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ។ ក្រៅពីនេះ ការភ័យខ្លាចនៃការចាប់ខ្លួន ការនិរទេស និងបញ្ហាសេដ្ឋកិច្ច គឺជាឧបសគ្គដល់ឪពុកម្តាយ។ ឪពុកម្តាយខ្លះមិនឱ្យតម្លៃការអប់រំរបស់ប្រទេសថៃនោះទេ ដោយសារពួកគេមានគម្រោងស្នាក់នៅបណ្តោះអាសន្នប៉ុណ្ណោះ[62]។

មជ្ឈមណ្ឌលធនធានទេសន្តរប្រវេសន៍បានក្លាយជាជម្រើសមួយសម្រាប់កុមារទទួលការអប់រំ ដែលជាញឹកញាប់ រៀនជាភាសាថៃ ឬភាសាអង់គ្លេស ហើយមណ្ឌលខ្លះផ្តោតលើកុមារមកពីប្រទេសភូមា។ ប៉ុន្តែ ចំពោះកុមារទេសន្តរប្រវេសន៍ទាំងនោះដែលចុះឈ្មោះចូលរៀននៅតាមមជ្ឈមណ្ឌលសិក្សាទេសន្តរប្រវេសន៍ បានជួបប្រទះបញ្ហាគុណភាពបង្រៀនមិនច្បាស់លាស់ និងមិនទៀងទាត់ ដែលរារាំងដល់ការរំពឹងទុកនាពេលអនាគតរបស់ពួកគេ[63]។

តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) រាយការណ៍ថា ឧបសគ្គដែលកុមារមិនបានចូលរៀនមកពីការរំពឹងទុករបស់ឪពុកម្តាយសម្រាប់កុមារ។ ដូចបានបង្ហាញក្នុងការពិនិត្យឯកសារស្រាវជ្រាវដែលមានស្រាប់ ឪពុកម្តាយដែលមិនមានគម្រោងស្នាក់នៅយូរអង្វែង មិនឃើញពីតម្លៃនៃការអប់រំរបស់ប្រទេសថៃទេ។ ឯឪពុកម្តាយខ្លះទៀតកំពុងប្រើកូនរបស់ខ្លួនឱ្យជួយមើលថៃប្អូនតូចៗ ឬទៅរកការងារបង្កើតប្រាក់ចំណូល។

កុមារដែលត្រឡប់មកពីប្រទេសថៃ មានសិទ្ធិចូលរៀននៅសាលាខ្មែរ តែបញ្ហាដូចជាភាសា និងឯកសារផ្លូវច្បាប់អាចជាឧបសគ្គ។ ក្រៅពីនេះ កុមារអាចមានជីវភាពក្រីក្រ ហើយតម្រូវឱ្យធ្វើការជួយបង្កើតប្រាក់ចំណូលដល់គ្រួសារ ឬទទួលខុសត្រូវជួយមើលថែទាំសាច់ញាតិចាស់ៗ ដែលធ្វើឱ្យពួកគេមិនបានចូលរៀន។ កុមារគ្មានឯកសារអត្តសញ្ញាណ ច្រើនតែត្រូវបានផ្តល់ការអប់រំក្រៅផ្លូវការ តាមរយៈការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល។

## ការទទួលបានសេវាសុខភាព

*"កូនៗរបស់ខ្ញុំអាចចូលប្រើសេវាសុខភាពនៅប្រទេសថៃ។ ពួកគេមើលថែយើងបានល្អ"* ឪពុកម្តាយរបស់កុមារត្រឡប់មកពីប្រទេសថៃ

គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានលើកឡើងថា ការថែទាំសុខភាពគឺជាសិទ្ធិមូលដ្ឋានដែលមិនអាចខ្វះបានសម្រាប់ការអនុវត្តសិទ្ធិមនុស្សផ្សេងៗទៀត[64]។ អនុសញ្ញាស្តីពីសិទ្ធិកុមារធានាដល់កុមារគ្រប់រូបនូវសិទ្ធិទទួលបានសេវាថែទាំសុខភាព និងបរិក្ខារនានា ដោយមិនគិតពីសញ្ជាតិ ទីលំនៅ ឬស្ថានភាពផ្លូវច្បាប់របស់ពួកគេឡើយ[65]។ ប្រទេសថៃបានបង្កើតជម្រើសទូលំទូលាយ ដើម្បីធានាឱ្យពលករទេសន្តរប្រវេសន៍ឱ្យទទួលបានការធានារ៉ាប់រងសុខភាព ចំណែកអ្នកដែលមិនមានសិទ្ធិ ពួកគេអាចទទួលបានជម្រើសសមរម្យសម្រាប់គ្រួសារ និងកុមារ តាមរយៈគម្រោងធានារ៉ាប់រងសុខភាពទេសន្តរប្រវេសន៍របស់ក្រសួងសុខភាពសាធារណៈ[66]។ ប៉ុន្តែ តាមការពិនិត្យឯកសារស្រាវជ្រាវបានរកឃើញ

---

[61] Asian Research Center for Migration. (2022) *Investing in a Global Future: A Situation Analysis of Migrant Children's Education in Thailand.* UNICEF Chulalongkorn University: Bangkok.

[62] Education knows no border - report.pdf

[63] Asian Research Center for Migration. (2022) *Investing in a Global Future: A Situation Analysis of Migrant Children's Education in Thailand.* UNICEF Chulalongkorn University: Bangkok.

[64] Right to health | Attorney-General's Department

[65] Convention on the Rights of the Child | UNICEF

[66] International Office of Migration (IOM) (2022) *Annual Report Thailand. Bangkok*

ថា បញ្ហាប្រឈមសំខាន់ៗនៅតែផ្សារភ្ជាប់ទៅនឹងលទ្ធភាពទទួលបានការថែទាំសុខភាពសម្រាប់កុមារទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃ។

កុមារទេសន្តរប្រវេសន៍ជាច្រើន ជាពិសេស កុមារគ្មានឯកសារ មិនអាចទទួលបានសេវាសុខភាពជាមូលដ្ឋានបានឡើយ។ បញ្ហាសំខាន់ៗរួមមានកង្វះស្ថានភាពផ្លូវច្បាប់ ដែលរារាំងកុមារទេសន្តរប្រវេសន៍គ្មានឯកសារភាគច្រើន អាចចូលទៅប្រើសេវាសុខភាពរបស់រដ្ឋាភិបាល ទោះបីពួកគេមានឯកសារអត្តសញ្ញាណ ឬប័ណ្ណស្នាក់នៅហើយក៏ដោយ។ ជនទេសន្តរប្រវេសន៍ដែលមានឯកសារ ច្រើនតែប្រឈមការលំបាកក្នុងការបញ្ជាក់ពីស្ថានភាពស្របច្បាប់របស់ពួកគេ។ លើសពីនេះ ឧបសគ្គភាសាគឺជាបញ្ហាទូទៅ។ កង្វះអ្នកបកប្រែទូទៅ និងព័ត៌មានសុខភាពដែលបានបកប្រែស្រាប់។ ការភ័យខ្លាចចំពោះអាជ្ញាធរ កាន់តែបង្អាក់លទ្ធភាពទទួលបានសេវាថែទាំសុខភាព ដោយសារតែគ្រួសារទេសន្តរប្រវេសន៍ ជាពិសេសអ្នកគ្មានឯកសារ មានទំនោរជៀសវាងសេវារបស់រដ្ឋាភិបាល ដោយសារមានការព្រួយបារម្ភខ្លាចមានគេរាយការណ៍ និងត្រូវបាននិរទេស។ បញ្ហានេះរារាំងកុមារមានជំងឺពីការទទួលការថែទាំសេវាពេទ្យចាំបាច់។

មានកម្មវិធីសុខភាព ឬគ្លីនិកតិចតួចណាស់ដែលត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការវប្បធម៌ និងភាសារបស់សហគមន៍ជនទេសន្តរប្រវេសន៍ និងជាពិសេស ផ្តោតលើកុមារទេសន្តរប្រវេសន៍។ សេវាសុខភាពរបស់រដ្ឋាភិបាលភាគច្រើនមិនត្រូវបានបង្កើតឡើងសម្រាប់ប្រភេទប្រជាជនទាំងនេះទេ។ តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs) ជាមួយឪពុកម្តាយដែលបានត្រឡប់មកពីប្រទេសថៃវិញ ពួកគេមានទស្សនៈខុសគ្នាបន្តិចពីការពិនិត្យឯកសារស្រាវជ្រាវ។ ឪពុកម្តាយពីរបីនាក់ដែលបានព្យាយាមទទួលបានការថែទាំសុខភាពដល់កូនៗរបស់ពួកគេនៅក្នុងប្រទេសថៃដោយជោគជ័យ ប្រាប់ថា កូនៗរបស់ពួកគេបានទទួលការព្យាបាលយ៉ាងល្អ។ តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs) បានឱ្យដឹងថា កុមារដែលត្រឡប់មកពីប្រទេសថៃអាចប្រឈមនឹងឧបសគ្គមួយចំនួនក្នុងការទទួលបានសេវាថែទាំសុខភាព ប្រសិនបើពួកគេមិនមានឯកសារស្របច្បាប់ដើម្បីអាចទទួលបានឯកសារអត្តសញ្ញាណ។

**ពលកម្មកុមារ**

> *"ពលកម្មកុមារកើតឡើងទូទៅនៅតាមវិស័យកសិកម្ម និងនេសាទ ក្នុងប្រទេសថៃ"* ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KII) រដ្ឋាភិបាល
>
> *"ជួលកាល ឪពុកម្តាយបង្ខំកូនៗ ចូលរួមពលកម្មកុមារ ឬស្ថានភាពឧក្រិដ្ឋ"* ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KII) ភ្នាក់ងារអង្គការសហប្រជាជាតិ

ពលកម្មកុមារត្រូវបានលើកឡើងជាក្តីបារម្ភទាំងកុមារដែលទុកនៅស្រុក និងកុមារនៅប្រទេសថៃ។ ពលកម្មកុមារត្រូវបានរាយការណ៍ថា កើតឡើងជាទូទៅនៅក្នុងឧស្សាហកម្មមួយចំនួន ហើយជួនកាលកុមារត្រូវបានបញ្ជូនទៅសុំទាន ឬចូលរួមប្រភេទពលកម្មផ្សេងទៀត។ កត្តាជំរុញពលកម្មកុមារមានដូចជា ភាពក្រីក្រ និង

ការប្រែប្រួលអាកាសធាតុ ដោយការប្រែប្រួលអាកាសធាតុ និងភាពតានតឹង បានរួមចំណែកដល់ទុក្ខលំបាកហិរញ្ញវត្ថុដល់ក្រុមគ្រួសារទេសន្តរប្រវេសន៍នៅកម្ពុជា[67]។

នៅប្រទេសថៃ ពលកម្មកុមារត្រូវបានចងក្រងជាឯកសារតាមផ្នែកផ្សេងៗគ្នា។ នៅក្នុងឧស្សាហកម្មសំណង់ ដែលពឹងផ្អែកខ្លាំងលើពលកម្មទេសន្តរប្រវេសន៍ របាយការណ៍បង្ហាញថាកុមារ បានរៀបចំការុង ឬដឹកខ្សាច់ ហើយធ្វើការងារផ្សេងទៀតនៅឯការដ្ឋានសំណង់ ដូចជា មើលថែកុមារតូចៗ ធ្វើការនៅតាមផ្ទះ ឬការងារតាមភោជនីយដ្ឋាន។ កុមារក៏ទទួលរងស្ថានភាពពលកម្មដោយបង្ខំ ពាក់ព័ន្ធនឹងការលក់ដូរ ការងារនៅតាមផ្ទះ ផលិតកម្មកាត់ដេរ កសិកម្ម ការកែច្នៃអាហារគ្រឿងសមុទ្រ និងនេសាទ។ កុមារបានចូលរួមសុំទានដោយមានការរៀបចំផងដែរ។ កត្តាដូចជាបម្រែបម្រួលអាកាសធាតុកំពុងជំរុញឱ្យមានការកើនឡើងនៃពលកម្មកុមារ។

យោងតាមអង្គការ *មិត្តសម្លាញ់-អន្តរជាតិ* បានឲ្យដឹងថា បច្ចុប្បន្ននេះ កុមារទេសន្តរប្រវេសន៍កម្ពុជាជាង ១៥,០០០នាក់ កំពុងធ្វើការមិនច្បាស់លាស់នៅក្នុងប្រទេសថៃ និងមានហានិភ័យខ្ពស់ដោយការរំលោភបំពាន និងការកេងប្រវ័ញ្ច[68]។ មនុស្សជាច្រើនបានចូលទៅប្រទេសថៃតាមមធ្យោបាយមិនប្រក្រតី ធ្វើដំណើរតែម្នាក់ឯង ឬជាមួយក្រុមគ្រួសាររបស់ពួកគេ ដោយសង្ឃឹមថា នឹងទទួលបានជីវភាពកាន់តែប្រសើរឡើង។ ទន្ទឹមនេះ យោងតាមការប៉ាន់ប្រមាណពីអង្គការ*មិត្តសម្លាញ់-អន្តរជាតិ* កុមារកម្ពុជាយ៉ាងតិច ៦០០នាក់ បានចូលប្រឡូកក្នុងការងារគ្រោះថ្នាក់ និងរស់នៅជុំវិញផ្សារព្រំដែនដ៏ធំ ក្នុងក្រុង*អារញ្ញប្រាថេត* ប្រទេសថៃ ដោយឆ្លងកាត់ច្រកក្រុងប៉ោយប៉ែត ចេញពីប្រទេសកម្ពុជា។ ពីមួយថ្ងៃទៅមួយថ្ងៃ កុមារឆ្លងព្រំដែនខុសច្បាប់ ប្រឈមនឹងការជួញដូរ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងបញ្ហានៅចំពោះមុខច្បាប់ជាប្រចាំ។ កុមារជាច្រើនមិនអាចទៅរៀនបាន ដោយសារគ្រួសាររបស់ពួកគេពឹងផ្អែកលើប្រាក់ចំណូលប្រចាំថ្ងៃរបស់កុមារទាំងនោះ[69]។

តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) បានប្រាប់ថា ជារឿយៗ កុមារបានចូលរួមពលកម្មកុមារ - តាមពិតកុមារជាច្រើនទៅរកការងារធ្វើនៅប្រទេសថៃ – ដូចបានរកឃើញក្នុងការពិនិត្យឯកសារស្រាវជ្រាវ ពលកម្មទាំងនេះរួមមាន ការសុំទាន ការងារកសិកម្ម ការងារតាមផ្ទះ និងការងារផ្សេងៗទៀត។ កុមារដែលមានពិការភាពអាចស្ថិតក្នុងចំណោមជនងាយរងគ្រោះបំផុត ដោយសារពួកគេអាចត្រូវបានជ្រើសរើសឱ្យទៅសុំទាន ហើយមិនមានលទ្ធភាពទទួលបានសេវាគ្រប់គ្រាន់។ កុមារដែលកំពុងធ្វើការ ក៏មិនអាចចូលសាលាបាន និងបណ្តាលឱ្យកើតឡើងវដ្តនៃភាពក្រីក្រតទៅទៀត។

## ការជួញដូរកុមារ

> *"ទេសន្តរប្រវេសន៍ខុសច្បាប់ និងការរត់ពន្ធមនុស្ស មានមូលហេតុដូចគ្នា។ ជួនកាល ពួកគេចាញ់បោកមេខ្យល់ ជាប់បំណុលក្នុងគ្រួសារ ឬជំពាក់មេបំណុល"* អ្នកផ្តល់សេវាអង្គការមិនមែនរដ្ឋាភិបាល

[67] Policy Brief_Climate Migration Vulnerability_CAMBODIA_FINAL 0.3_Designed
[68] https://friends-international.org/blog/index.php/protect-children-migrants/
[69] https://www.friends-international.org/support/fundraisingneed3.php?mm=su&sm=fn

*"ទេសន្តរប្រវេសន៍មិនប្រក្រតី បង្កើនហានិភ័យនៃការកេងប្រវ័ញ្ច និងការជួញដូរកុមារ"* ភ្នាក់ងារអង្គការសហប្រជាជាតិ

កុមារទេសន្តរប្រវេសន៍ក្នុងប្រទេសថៃ ជាពិសេស កុមារដែលចូលប្រទេសដោយមធ្យោបាយមិនប្រក្រតី ឬខ្វះឯកសារត្រឹមត្រូវ ទទួលរងហានិភ័យខ្ពស់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច។ នៅទូទាំងតំបន់ កុមារត្រូវបានជួញដូរដោយគោលបំណងកេងប្រវ័ញ្ចផ្សេងៗដូចជា ការងារតាមផ្ទះ ផលិតកម្ម កសិកម្ម នេសាទ សំណង់ សុំទានដោយបង្ខំ និងការរៀបការក្លែងក្លាយ ក្នុងចំណោមគោលបំណងផ្សេងទៀត[70]។ ករណីជួញដូរមនុស្សក្នុងប្រទេសថៃត្រូវបានគេរាយការណ៍ថា ជាប់ទាក់ទងទៅនឹងឧស្សាហកម្មពាណិជ្ជកម្មផ្លូវភេទផងដែរ[71]។ ប្រកនៃ ការកេងប្រវ័ញ្ចទូទៅ គឺស្ថិតនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ រួមមានការជួញដូរកុមារពីប្រទេសកម្ពុជាទៅប្រទេសថៃក្នុងគោលបំណងបង្ខំឱ្យសុំទាន បម្រើការងារតាមផ្ទះ និងលក់ដូរតាមចញ្ចើមផ្លូវ[72]។

## ការឃុំខ្លួន

*"អាជ្ញាធរថៃបានឃុំខ្លួនជនទេសន្តរប្រវេសន៍ក្នុងរយៈពេលមួយចាប់ពី ៥ ឬ ១០ ថ្ងៃ ករណីខ្លះ ១ ឆ្នាំ ឬ ២ ឆ្នាំមុនពេលធ្វើមាតុភូមិនិវត្តន៍។"* ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KII) ពីអ្នកផ្តល់ សេវាអង្គការក្រៅរដ្ឋាភិបាល

*"នៅពេលប៉ូលីសជួបជនទេសន្តរប្រវេសន៍ខុសច្បាប់នៅប្រទេសថៃ ពួកគេត្រូវចាប់ខ្លួន។ មានមួយចំនួនត្រូវបានបញ្ជូនចេញភ្លាមៗ ភាគច្រើនត្រូវជាប់ពន្ធនាគាររយៈពេលពី ១ ទៅ ៦ខែ។ ជាធម្មតាកុមារមិនត្រូវជាប់ឃុំនោះទេ តែការរកដំណោះស្រាយសម្រាប់ពួកគេ ជាការលំបាក ខណៈឪពុកម្តាយរបស់ពួកគេត្រូវជាប់ឃុំ"*

សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិកុមារក្នុងបរិបទទេសន្តរប្រវេសន៍ ជំរុញឱ្យមានជម្រើសក្នុងការឃុំខ្លួនកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ ទោះបីមិនមានបទប្បញ្ញត្តិផ្លូវច្បាប់នៅក្នុងប្រទេសថៃដែលហាមឃាត់ការប្រើប្រាស់ការឃុំឃាំងចំពោះជនទេសន្តរប្រវេសន៍ក៏ដោយ ក៏រដ្ឋាភិបាលថៃបានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការបង្កើនជម្រើសសហគមន៍ជំនួសជាការឃុំឃាំងជនអន្តោប្រវេសន៍ជាកុមារ និងក្រុមគ្រួសាររបស់ពួកគេ[73]។

បច្ចុប្បន្ន ប្រទេសថៃមានមណ្ឌលឃុំឃាំងអន្តោប្រវេសន៍ចំនួន ២២ កន្លែង ដែលគ្រប់គ្រងដោយការិយាល័យអន្តោប្រវេសន៍របស់ប៉ូលិសថៃ។ ទោះបីជាមានការប្តេជ្ញាចិត្តក្នុងយកសហគមន៍ជំនួសការឃុំឃាំងក៏ដោយ របាយការណ៍ដែលបានពិនិត្យនៅក្នុងឯកសារស្រាវជ្រាវបានរកឃើញថា កុមារទេសន្តរប្រវេសន៍នៅបន្ត

[70] Blackburn, Ashley G., et al. (2010), "Understanding the Complexities of Human Trafficking and Child Sexual Exploitation: The Case of Southeast Asia", Women & Criminal Justice 20(1–2) (2010): 108.

[71] https://www.state.gov/reports/2023-trafficking-in-persons-report/thailand; https://www.unodc.org/roseap/uploads/archive/documents/download/2017/TiP_to_Thailand_20_Oct_2017.pdf

[72] Ibid.

[73] https://resourcecentre.savethechildren.net/document/unlocking-childhood-current-immigration-detention-practices-and-alternatives-child-asylum/; https://www.researchgate.net/publication/334511562_Detention_of_Refugee_Children_in_Malaysia_and_Thailand

ក្លាយជាគោលដៅនៃការចាប់ខ្លួន ការឃុំខ្លួន ខណៈដែលបទប្បញ្ញត្តិក្នុងអនុស្សរណៈនៃការយោគយល់គ្នា (MOU) អនុវត្តបានតែនៅពេលដែលអាជ្ញាធរអន្តោប្រវេសន៍ចាប់ខ្លួនកុមាររួចហើយ[74]។

តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា ការអនុវត្តជាទូទៅចំពោះកុមារគឺត្រូវបញ្ជូនពួកគេទៅមណ្ឌលថែទាំសិន ប្រសិនឪពុកម្តាយរបស់ពួកគេត្រូវបានចាប់ខ្លួន ទោះបីជាមានរបាយការណ៍មួយចំនួនអំពីការឃុំខ្លួនក៏ដោយ។ មានសេចក្តីរាយការណ៍មកថា អ្វីជាបញ្ហាប្រឈមនោះគឺ កុមារតែងតែស្នាក់នៅក្នុងមណ្ឌលថែទាំរយៈពេលយូរ មុនពេលធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជា ឬពួកគេរស់នៅក្នុងស្ថានភាពថែទាំមិនគ្រប់គ្រាន់ជាមួយគ្រួសារធំ។

## ប្រព័ន្ធកិច្ចការពារកុមារ

ប្រព័ន្ធកិច្ចការពារកុមារគឺជាសំណុំច្បាប់ គោលនយោបាយ បទប្បញ្ញត្តិ និងសេវាកម្មផ្សេងៗដែលចាំបាច់នៅគ្រប់វិស័យសង្គម ជាពិសេស សុខុមាលភាពសង្គម ការអប់រំ សុខភាព សន្តិសុខ និងយុត្តិធម៌ ដែលគាំទ្រដល់ការការពារ និងការឆ្លើយតបចំពោះហានិភ័យនៃកិច្ចការពារកុមារ។ ហានិភ័យទាំងនេះរួមមាន អំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើ[75]។ មានបញ្ហាប្រឈមយ៉ាងខ្លាំង ក្នុងការធានាឱ្យទទួលបានសេវាកិច្ចការពារកុមារនិងសេវាឆ្លើយតបក្នុងស្ថានភាពឆ្លងច្រកព្រំដែន ជាពិសេស នៅពេលដែលកុមារធ្វើដំណើរឆ្លងកាត់ព្រំដែនអន្តរជាតិ។ ប្រព័ន្ធកិច្ចការពារកុមារទាំងក្នុងប្រទេសកម្ពុជា និងប្រទេសថៃ មានទំនាក់ទំនងនឹងកិច្ចការពារកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ ផ្នែកខាងក្រោមផ្តល់នូវទិដ្ឋភាពសង្ខេបច្បាប់ គោលនយោបាយនិងសេវាផ្សេងៗដែលមានស្រាប់ សម្រាប់កុមារទេសន្តរប្រវេសន៍កម្ពុជា ទៅកាន់ប្រទេសថៃ ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ។

### ប្រព័ន្ធកិច្ចការពារកុមារនៅប្រទេសកម្ពុជា

ប្រព័ន្ធកិច្ចការពារកុមារប្រទេសកម្ពុជា ឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ រួមទាំងកុមារដែលទុកនៅស្រុកកំណើត និងកុមារត្រឡប់មកប្រទេសកម្ពុជាវិញ។ កុមារដែលត្រូវបានទុកនៅស្រុកកំណើតក្រោមការថែទាំរបស់សាច់ញាតិ ឬអ្នកដ៏ទៃ ឬកុមារដែលបានត្រឡប់មកកម្ពុជាវិញ អាចទទួលបានសេវាកិច្ចការពារដូចគ្នា (សូមមើលផ្នែកខាងលើ) ដូចកុមារដទៃទៀតនៅក្នុងប្រទេសកម្ពុជាដែរ។

នៅប្រទេសកម្ពុជា មានកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ ក្នុងការពង្រឹងការឆ្លើយតបទៅលើកិច្ចការពារកុមារ។ ផែនការអនុវត្តវិស័យការពារកុមារកត់សម្គាល់ថា ការអភិវឌ្ឍប្រព័ន្ធការពារកុមារនេះត្រូវបានបង្ហាញដោយយោងតាមឧត្តមប្រយោជន៍កុមារ សមធម៌ ការពង្រឹងប្រព័ន្ធ ការសហការ និងភាពជាដៃគូ ការបង្កើត និង

---

[74]FID/UCL (2024) *Out of Sight: Human Rights Violations in Immigration Detention Centers* Accessed at: out_of_sight_-_human_rights_violations_in_thailand_s_idcs.pdf

[75] UNICEF 2021-2030 Child Protection Strategy - Global Social Service Workforce Alliance

ប្រើប្រាស់កស្តុតាង។ជាតុសំខាន់ៗរួមមានការបង្កើតក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ រចនាសម្ព័ន្ធអភិបាលកិច្ច ការសម្របសម្រួល បង្កើតសេវាបន្ត បង្កើតស្តង់ដារអប្បបរមា និងយន្តការត្រួតពិនិត្យ ការកែលម្អធនធានហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធមនុស្ស លើកកម្ពស់យន្តការការចូលរួមរបស់កុមារ ការចូលរួមសហគមន៍ ការប្រមូលទិន្នន័យ និងប្រព័ន្ធតាមដានសកម្មភាព[76]។

បច្ចុប្បន្ននេះ មានសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការការពារកុមារកំពុងស្ថិតក្រោមការត្រួតពិនិត្យ។ នៅឆ្នាំ 2023 សៀវភៅមគ្គុទ្ទេសក៍ស្តីពីនីតិវិធីប្រតិបត្តិការការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក និងខណ្ឌត្រូវបានអនុម័ត និងផ្សព្វផ្សាយអំពីនីតិវិធីទាំងនេះសម្រាប់ឆ្លើយតបទៅនឹងករណីកិច្ចការពារកុមារ។ កុមារដែលឪពុកម្តាយទុកនៅស្រុកកំណើត អាចទទួលបានការគាំទ្រ និងសេវាពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MoSVY) និងការិយាល័យសង្គមកិច្ច ថ្នាក់ស្រុក និងខេត្ត។ ការគាំទ្រទាំងនេះ មានដូចជា ការគ្រប់គ្រងករណី ការផ្តល់ និងការបញ្ជូនបន្ត សម្រាប់សេវាកម្មរកបាន និងមិនសូវមានសមត្ថភាពបំពេញការងារ។ សេវាភាគច្រើនដែលអាចរកបាន មិនត្រូវបានតម្រង់ឱ្យចំគោលដៅ ពិសេស ចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នោះទេ[77]។ ម្យ៉ាងវិញទៀត កុមារមួយចំនួនដែលឪពុកម្តាយទុកនៅស្រុក អាចផ្លាស់ទីលំនៅពីសាច់ញាតិ/អ្នកមើលថែម្នាក់ទៅម្នាក់ទៀត ដែលកាន់តែពិបាកក្នុងការតាមដានពួកគេ។

ជំនួយរបស់រដ្ឋាភិបាល ត្រូវបានបំពេញបន្ថែមដោយសេវាជាច្រើនរបស់អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រដល់គ្រួសារទេសន្តរប្រវេសន៍ និងកុមារក្នុងស្ថានភាពសេដ្ឋកិច្ចលំបាក តាមរយៈជំនួយផ្នែកហិរញ្ញវត្ថុ (តាមរយៈការទូទាត់តាមដំណាក់កាល ឬទូទាត់តែមួយលើក) ឬមានជំនួយផ្សេងៗទៀត ដូចជាអាហារផលិតផលអនាម័យ ការបង្កើតប្រាក់ចំណូល និងការគាំទ្រផ្នែកសិក្សា។ ទោះបីសេវាទាំងនេះអាចរកបានក្តី តែវានៅមិនទៀងទាត់ និងទូលំទូលាយនោះទេ។ ប្រព័ន្ធកិច្ចការពារកុមារកំពុងត្រូវបង្កើត រីឯសេវានៅមានកម្រិតនៅឡើយ ទាំងសមត្ថភាព និងគុណភាព។ លើសពីនេះ ប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជា មិនទាន់ប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ ដែលអាចវិភាគដោយបំបែកជាក្រុម ក្នុងការតាមដានស្ថានភាព និងឆ្លើយតបដល់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ដែលឪពុកម្តាយពួកគេទុកនៅ ស្រុកកំណើត ឬកុមារដែលធ្វើដំណើរជាមួយឪពុកម្តាយរបស់ពួកគេ។

ជោគជ័យដ៏សំខាន់មួយ គឺការពង្រឹងប្រព័ន្ធគ្រប់គ្រងករណី *Primero CPIMS+* សម្រាប់ការឆ្លើយតបទៅនឹងករណីកិច្ចការពារកុមារ។ នេះគឺជាប្រព័ន្ធគ្រប់គ្រងករណីការពារកុមារដែលត្រូវបានកែសម្រួលទៅតាមបរិបទប្រទេសកម្ពុជា។ នៅតាមខេត្ត និងស្រុកនីមួយៗ ជនបង្គោល និងបុគ្គលិកកាន់ករណី ត្រូវបានជ្រើសរើស និង បណ្តុះបណ្តាល ដើម្បីផ្តល់ការឆ្លើយតបកិច្ចការពារកុមារ។ ការអនុវត្ត *Primero CPIMS+* ត្រូវបានណែនាំដោយស្តង់ដារនិតិវិធីប្រតិបត្តិ ដែលបង្ហាញពីតួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់អាជ្ញាធរពាក់ព័ន្ធនៅតាមសាលាក្រុង និងខណ្ឌ លើការឆ្លើយតបទៅនឹងកិច្ចការពារកុមារ[78]។ សម្រាប់កុមារដែលរងផលប៉ះពាល់

[76] MoSVY (2022). *Child Protection Sector Implementation Plan 2022-2026*
[77] UNICEF Migration Country brief Cambodia.pdf
[78] MoSVY (2023). *Guidebook on Child Protection Operation Procedures for Municipal, District, and Khan Administration*

ដោយទេសន្តរប្រវេសន៍ សេវាការពារកុមារផ្តោតលើកុមារដែលត្រូវបានទុកនៅស្រុកកំណើត និងកុមារដែលវិលត្រឡប់មកវិញពីទេសន្តរប្រវេសន៍។ កុមារដែលកំពុងដំណើរការធ្វើមាតុភូមិនិវត្តន៍មិនត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធនេះទេ ហើយក៏អាចមានចន្លោះប្រហោងចំពោះកុមារដែលធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត ឬដោយមិនស្ម័គ្រចិត្ត។

*ស្តង់ដារនីតិវិធីប្រតិបត្តិ (SOP) "ធានាថា កុមារទាំងអស់ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ត្រូវបានគ្របដណ្តប់ដោយស្តង់ដារនីតិវិធីប្រតិបត្តិ SOPs ។ នេះរាប់បញ្ចូលទាំងកុមារដែលមានសញ្ជាតិកម្ពុជា ក៏ដូចជាប្រភេទក្រុមកុមារទាំងអស់ដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ (ដូចជាការស្វែងរកសិទ្ធិជ្រកកោន*
*ជនភៀសខ្លួន ជនទេសន្តរប្រវេសន៍ ការផ្លាស់ទីលំនៅក្នុងប្រទេស ការជួញដូរ និងកុមារគ្មានរដ្ឋ "កុមារដែលកំពុងផ្លាស់ផ្លាស់ទី" និង "កុមារដែលទុកនៅស្រុកកំណើត")។ កុមារដែលគ្មានឯកសារកំណើតជាកស្តុតាង ឯកសារអត្តសញ្ញាណ ឬឯកសារស្នាក់នៅក៏ត្រូវបានគ្របដណ្តប់ដោយស្តង់ដារនីតិវិធីប្រតិបត្តិ SOPs ផងដែរ"[79] ។*

បច្ចុប្បន្នប្រព័ន្ធគ្រប់គ្រងករណី *Primero CPIMS+ នៅកម្ពុជា* មានការបន្ថែមក្រុមប្រភេទមួយដែលកត់ត្រាថា "កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍"។ លើសពីនេះ ចំណុចទិន្នន័យដូចជាប្រភេទនៃការថែទាំអ្នកមើលថែជាដើម ក៏ត្រូវបានប្រមូលផងដែរ។ តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) បានឱ្យដឹងថា ទិន្នន័យបច្ចុប្បន្ន មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីកុមារដែលត្រូវបានទុកនៅស្រុកកំណើតនោះទេ។ ឧទាហរណ៍ ទិន្នន័យមិនផ្តល់ការយល់ច្បាស់អំពីស្ថានភាពរបស់ឪពុកម្តាយនោះទេ។

ដើម្បីពង្រឹងប្រព័ន្ធឱ្យអាចដំណើរការកំណត់អត្តសញ្ញាណ កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍បានគ្រប់គ្រាន់ (ប៉ុន្តែនេះត្រូវបានមើលឃើញថាមានលក្ខណៈទូលំទូលាយពេក) គេចាំបាច់ត្រូវការប្រភេទក្រុមបន្ថែម ដើម្បីផ្តល់ការយល់កាន់តែច្បាស់ ណែនាំដល់ការឆ្លើយតបប្រកបដោយគុណភាព។ ឧទាហរណ៍ កុមារទុកនៅស្រុកកំណើត (ឪពុកម្តាយតែម្នាក់ ឬទាំងពីរនាក់ បច្ចុប្បន្នធ្វើទេសន្តរប្រវេសន៍) កុមារដែលបានត្រឡប់ពី
ទេសន្តរប្រវេសន៍វិញដោយស្ម័គ្រចិត្ត កុមារដែលបានត្រឡប់មកវិញដោយមិនស្ម័គ្រចិត្ត កុមារដែលត្រូវបានបំបែក និងគ្មានអ្នកអមដំណើរជាមួយ កុមារចំណាកស្រុកក្នុងប្រទេស។ បូកផ្សំការទទួលបានព័ត៌មានអំពីអ្នកថែទាំ នឹងផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីស្ថានភាពកុមារ។

ដោយសារបម្រែបម្រួលអាកាសធាតុនៅកម្ពុជា មនុស្សអាចនឹងបង្កើនការធ្វើចំណាកស្រុក លទ្ធភាពទទួលបានសេវាសង្គមជាមូលដ្ឋានអាចនឹងកាត់បន្ថយ វិសមភាពយេនឌ័រកើនឡើង និងធ្វើឱ្យជីវភាពរស់នៅ និងសន្តិសុខស្បៀងកាន់តែយ៉ាប់យ៉ឺន។ ដូច្នេះហើយ បញ្ហាប្រឈមដែលកំពុងកើតឡើងថ្មីៗដោយសារផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ តម្រូវឱ្យមានប្រព័ន្ធការពារកុមារដែលមានភាពឆ្លាតវៃខាងអាកាសធាតុ (climate

[79] MoSVY MoSVY (2023). *Guidebook on Child Protection Operation Procedures for Municipal, District, and Khan Administration*

smart)។ ជូនពេលដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងបង្កើត ការរួមចំណែករបស់ជាតិ ឬ NDCs ដែលរួមបញ្ចូលកិច្ចខិតខំប្រឹងប្រែងដើម្បីសម្របខ្លួនទៅនឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ។

## ប្រព័ន្ធកិច្ចការពារកុមារនៅប្រទេសថៃ

"នៅពេលមានបញ្ហា ក្រុមគ្រួសារមិនស្វែងរកជំនួយទេ ព្រោះពួកគេខ្លាចគេរកឃើញ និងបណ្ដេញចេញ ពួកគេត្រូវការការងារធ្វើ" *ប្រភពពីការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ៗ*

**ច្បាប់ស្ដីពីកិច្ចការពារកុមារ**របស់ប្រទេសថៃ រួមមានកុមារកម្ពុជា ដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ទៅរស់នៅក្នុងប្រទេសថៃ។ ច្បាប់នេះ តម្រូវឱ្យគិតដល់ឧត្តមប្រយោជន៍កុមារ ក្នុងការប្រព្រឹត្តណាមួយទាក់ទងនឹងកុមារ (រួមបញ្ចូលទាំងកុមារទេសន្តរប្រវេសន៍ និងកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍និយាយជាទូទៅ) ហើយពិនិត្យលើការអនុវត្តគោលការណ៍ណែនាំនេះ។

តាមការអនុវត្តជាក់ស្តែង កុមារអាចទទួលបានសេវាការពារ ប៉ុន្តែដោយសារគ្រួសាររបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នៅដាច់ឆ្ងាយពីគេ ពួកគេជារឿយៗមិនទាក់ទងសុំជំនួយ ហើយពេលខ្លះមិនដឹងពីរបៀបទទួលបានសេវា។ ជាធម្មតា អាជ្ញាធរពាក់ព័ន្ធក្នុងប្រទេសថៃបានផ្តល់សេវា នៅពេលដែលកុមារចូលដល់ស្ថានភាពត្រូវបោះបង់ចោល ឬនៅពេលមានការរៀបចំធ្វើមាតុភូមិនិវត្តន៍ដោយមិនស្ម័គ្រចិត្ត។ ពេលនោះ កុមារស្ថិតក្រោមការមើលថែរបស់រដ្ឋាភិបាលនៃប្រទេសថៃ។ អាជ្ញាធរក៏ចូលរួមករណីពាក់ព័ន្ធនឹងការជួញដូរពលកម្មកុមារ និងបញ្ហាកិច្ចការពារកុមារផ្សេងៗទៀត។ ដូចដែលបានកត់សម្គាល់នៅគ្រប់នីតិវិធីសម្រាប់ការឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយការជួញដូរគឺកាន់តែច្បាស់។

## ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញនៅក្នុងប្រទេសកម្ពុជា

កុមារត្រឡប់មកស្រុកកំណើតពីប្រទេសថៃតាមរយៈបណ្តាញជាច្រើន។ កុមារអាចត្រឡប់មកវិញដោយស្ម័គ្រចិត្ត ឬអាចត្រឡប់មកវិញតាមរយៈដំណើរការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការ ដោយឪពុកម្តាយពួកគេត្រូវចាប់ខ្លួននៅប្រទេសថៃ។ កុមារដែលត្រឡប់មកវិញ អាចប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើន ប្រឈមដំណើរការមិនច្បាស់លាស់សម្រាប់ការវិលត្រឡប់ និងប្រឈមការធ្វើមាតុភូមិនិវត្តន៍ដែលចាំបាច់ត្រូវការជំនួយ និងកិច្ចការពារកុមារ។ ប្រទេសកម្ពុជា និងប្រទេសថៃ មានតួនាទីរៀបចំការវិលត្រឡប់ និងការធ្វើសមាហរណកម្មឡើងវិញដល់កុមារ។ ខាងក្រោមនេះគឺជាការសង្ខេបដោយផ្អែកលើការត្រឡប់មកវិញដោយស្ម័គ្រចិត្ត និងការវិលត្រឡប់ដោយមិនស្ម័គ្រចិត្តដែលកំពុងអនុវត្តបច្ចុប្បន្ន។

កុមារដែលបានធ្វើទេសន្តរប្រវេសន៍ទៅកាន់ប្រទេសថៃជាមួយឪពុកម្តាយរបស់ពួកគេ អាចស្នាក់នៅរយៈពេលខ្លី ឬរយៈពេលវែង។ កត្តានេះ អាចនាំឱ្យមានបញ្ហាប្រឈមនៅពេលពួកគេត្រឡប់មកប្រទេសកម្ពុជា។ ក្នុងការរស់នៅក្នុងប្រទេសថៃ កុមារជាច្រើនដែលបានធ្វើទេសន្តរប្រវេសន៍ជាមួយឪពុកម្តាយរបស់ពួកគេបានរៀនភាសាថៃដើម្បីអាចទៅសាលារៀន ការធ្វើបែបនេះអាចនឹងបាត់បង់ ឬមិនមានជំនាញភាសាខ្មែរគ្រប់គ្រាន់។ កុមារទាំងនោះ ក៏ធ្លាប់រស់នៅក្នុងស្ថានភាពដ៏លំបាកផងដែរ។ នេះអាចជះឥទ្ធិពលអវិជ្ជមានដល់លទ្ធភាព

ទៅសាលារៀន ការចូលរួមក្នុងសហគមន៍របស់ពួកគេជាមួយក្រុមគ្រួសារ និងមិត្តភក្តិ។ តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) បានឱ្យដឹងថា កុមារមួយចំនួនតែងតែមានគម្រោងត្រឡប់ទៅប្រទេសថៃវិញ ដោយសារតែជួបបញ្ហាភាសា និងភាពប្លែកនៃវប្បធម៌នៅក្នុងប្រទេសកំណើតរបស់ពួកគេ បន្ទាប់ពីរស់នៅក្នុងប្រទេសថៃអស់រយៈពេលជាយូរ។

### *ការវិលត្រឡប់ដោយស្ម័គ្រចិត្ត*

*"កុមារជាច្រើនដែលត្រឡប់ទៅផ្ទះដោយស្ម័គ្រចិត្តជាមួយឪពុកម្តាយរបស់ពួកគេ។ ពួកគេអាចទៅស្រុកកំណើតបានភ្លាម។" មន្ទីរសង្គមកិច្ច (DoSVY)*

*"អ្នកខ្លះ បញ្ជូនកូនៗរបស់ពួកគេត្រឡប់ទៅផ្ទះវិញជាមួយសាច់ញាតិ។ យើងមិនអាចកំណត់រកពួកគេបានទេ ហើយគ្រួសារទាំងនេះអាចនឹងងាយរងគ្រោះ។" មន្ទីរសង្គមកិច្ច (DoSVY)*

កុមារដែលត្រឡប់មកពីប្រទេសថៃដោយស្ម័គ្រចិត្ត តាមវិធីផ្សេងៗ។ ពួកគេអាចត្រឡប់ទៅផ្ទះជាមួយឪពុកម្តាយរបស់ពួកគេ។ នេះជារឿងធម្មតាបំផុតនៅពេលដែលកុមារមានឯកសារស្របច្បាប់។ ក្នុងករណីនេះ កុមារត្រឡប់ទៅស្រុកកំណើតវិញបានភ្លាមៗ។ កុមារផ្សេងទៀតអាចត្រឡប់ចូលប្រទេសវិញដោយស្ម័គ្រចិត្តជាមួយអ្នកឯទៀត។ នេះអាចជាសមាជិកគ្រួសារ មិត្តភ័ក្តិ ឬអ្នកត្រឡប់មកវិញផ្សេងទៀត។ ករណីទាំងនេះ សមត្ថកិច្ចមិនដឹងថា ពួកគេបានវិលត្រឡប់មកវិញទេ។ ជួនកាលក្នុងស្ថានភាពទាំងនេះ កុមារត្រឡប់ទៅរកស្ថានភាពថៃទាំដែលអាចមានហានិភ័យខ្លះ។

បញ្ហាប្រឈមមួយដែលគេកត់សម្គាល់នោះ គឺគ្មានប្រព័ន្ធជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធ អំពីពេលវេលាដែលកុមារ ឬឪពុកម្តាយត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍វិញ។ ចំណុចនេះនាំឱ្យអាជ្ញាធរទទួលបន្ទុកកិច្ចការពារកុមារដែលពាក់ព័ន្ធ មិនបានដឹងពីការវិលត្រឡប់មកវិញរបស់ពួកគេ ដូច្នេះហើយមិនអាចផ្តល់សេវាគាំទ្រដែលចាំបាច់បានឡើយ។

### *ការវិលត្រឡប់ដោយមិនស្ម័គ្រចិត្ត*

*"សម្រាប់កុមារដែលត្រូវបានចាប់ខ្លួនក្នុងប្រទេសថៃ ការអនុវត្តគឺពួកគេដាក់កុមារនៅក្នុងមណ្ឌលក្នុងប្រទេសថៃ។ ពួកគេជូនដំណឹងដល់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត (PTC) បន្ទាប់មកមន្ទីរសង្គមកិច្ច ទទួលដំណឹងពី ខាងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (PTTC)"* មន្ទីរសង្គមកិច្ច (DoSVY)

*"ចំពោះករណីធ្វើមាតុភូមិនិវត្តន៍ យើងត្រូវសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយប្រទេសថៃ - ក្រសួងពាក់ព័ន្ធ យើងត្រូវការកាលបរិច្ឆេទពិតប្រាកដនៃពេលវេលាដែលយើងត្រូវការជំនួយ ឧទាហរណ៍ កុមារអាចនឹងស្នាក់នៅក្នុងមណ្ឌលគ្រប់គ្រងដោយរដ្ឋមួយរយៈ ហើយបន្ទាប់មកត្រឡប់ទៅកម្ពុជាវិញ"* មជ្ឈមណ្ឌលសំចតក្រុងប៉ោយប៉ែត

*"អាជ្ញាធរថៃបានជូនដំណឹងដល់នគរបាលអន្តោប្រវេសន៍នៅព្រំដែន បន្ទាប់មកបានជូនដំណឹងដល់យើង (មណ្ឌល ទទួលពលករកំរៀង KMC) ហើយយើងបានជួយនាំពួកគេមកទីនេះ ដើម្បីការវាយតម្លៃ និងការគាំទ្រនៅពេលចាំបាច់"។ មណ្ឌលទទួលពលករកំរៀង KMC*

ការវិលត្រឡប់មកវិញដោយមិនស្ម័គ្រចិត្ត ត្រូវបានផ្សារភ្ជាប់ជាទូទៅទៅនឹងករណីដែលឪពុកម្តាយត្រូវបានចាប់ខ្លួននៅក្នុងប្រទេសថៃ។ នៅពេលដែលឪពុកម្តាយត្រូវបានចាប់ខ្លួនពីបទរំលោភច្បាប់អន្តោប្រវេសន៍ ពួកគេអាចនឹងត្រូវឃុំខ្លួន។ ដូចដែលបានរៀបរាប់ខាងលើ គេផ្តល់អាទិភាពក្នុងការលុបបំបាត់ ឬកាត់បន្ថយការប្រើប្រាស់ការឃុំខ្លួនកុមារ។ ដំណើរការក្រៅផ្លូវការមួយចំនួនបានលេចចេញឡើង ដើម្បីអនុវត្តចំពោះកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ នៅពេលពួកគេវិលត្រឡប់ និងធ្វើមាតុភូមិនិវត្តន៍មកវិញ ដោយយកចេញពីដំណើរការដែលអនុវត្តចំពោះកុមារដែលរងផលប៉ះពាល់ដោយការជួញដូរ។

តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) បានរាយការណ៍ថា ជាដំបូង កុមារត្រូវបានដាក់នៅមណ្ឌលមួយក្នុងប្រទេសថៃ។ នាយកដ្ឋានទទួលបន្ទុករដ្ឋាភិបាលថៃ ទាក់ទងទៅកាន់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីជូនដំណឹងដល់ពួកគេអំពីការវិលត្រឡប់មកវិញរបស់កុមារ។ អាជ្ញាធរថៃ ជាញឹកញាប់ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់សេវា និងទំនាក់ទំនងក្នុងប្រទេសថៃ។ មជ្ឈមណ្ឌលសំចតប៉ោយប៉ែតជូនដំណឹងដល់មន្ទីរសង្គម កិច្ច DoSVY ដែលពាក់ព័ន្ធអំពីការត្រឡប់មកវិញរបស់កុមារ។

ឧត្តមប្រយោជន៍កុមារពាក់ព័ន្ធនឹងដំណើរការនៃការធ្វើមាតុភូមិនិវត្តន៍ និងការត្រឡប់មកវិញ។ ច្បាប់អន្តរជាតិមិនហាមឃាត់ការធ្វើមាតុភូមិនិវត្តន៍របស់កុមារទេ ទោះបីកុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះក៏ដោយ។ នីតិវិធីនេះពាក់ព័ន្ធនឹងការវាយតម្លៃអំពីស្ថានភាព និងហានិភ័យរបស់កុមារម្នាក់ៗ ការសិក្សាជាលក្ខណៈគ្រួសារអំពីវត្តមាន និងស្ថានភាពរបស់សាច់ញាតិនៅក្នុងប្រទេស ឬប្រភពដើម និងប្រទេសរស់នៅ ការវាយតម្លៃសុវត្ថិភាព និងហានិភ័យដែលមាន កម្រិតនៃការធ្វើសមាហរណកម្មរបស់កុមារនៅក្នុងប្រទេសទីលំនៅ និង រយៈពេលអវត្តមានរបស់ពួកគេពីប្រទេសដើម និងលក្ខណៈជាតិសាសន៍ សាសនា វប្បធម៌ និងភាសារបស់កុមារ។ ការកំណត់ឧត្តមប្រយោជន៍កុមារ ត្រូវតែជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តនាពេលអនាគតចំពោះកុមារ។ លទ្ធផលបីគឺអាចធ្វើទៅបាន៖ ការធ្វើមាតុភូមិនិវត្តន៍ ការធ្វើសមាហរណកម្មទៅក្នុងប្រទេសដែលរស់នៅ ឬផ្ទេរទៅប្រទេសទីបី[80]។

កុមារដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ដោយមិនស្ម័គ្រចិត្ត ត្រូវតែមានសិទ្ធិទទួលបានសេវាច្បាប់ និងមានសិទ្ធិប្តឹងឧទ្ធរណ៍។ ការបំបែកកុមារពីឪពុកម្តាយ ឬសមាជិកគ្រួសារផ្សេងទៀតគួរត្រូវបានជៀសវាង លុះត្រាតែការអបដំណើរណាមួយដែលអាចបណ្តាលឱ្យកុមារមានគ្រោះថ្នាក់។ កុមារមិនគួរត្រូវបានដកហូតសេរីភាពនោះទេ។ ដំណើរការណាមួយត្រូវតែទទួលស្គាល់ទីភ្នាក់ងារតំណាងរបស់កុមារធំ និងផ្តល់អ្នកតំណាងផ្នែកច្បាប់ដល់កុមារណាដែលគ្មានអ្នកមកជាមួយ។ កុមារដែលត្រូវបានបញ្ជូនមកវិញ ត្រូវទទួលបានការគាំទ្រ និងការបញ្ជូន

[80] International Child Repatriation Guidelines

ត្រូវធ្វើតាមរយៈបុគ្គលិកសុខុមាលភាពសង្គម ជំនួសឱ្យការ "ប្រគល់" ទៅមន្ត្រីប្រចាំការនៅច្រកព្រំដែន ។ បច្ចុប្បន្នមិនមានដំណើរការណាមួយដើម្បីធានាបាននូវការកំណត់ឧត្តមប្រយោជន៍ និងផែនការនោះទេ[81]។

## ភាគីពាក់ព័ន្ធសំខាន់ៗក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញ

បច្ចុប្បន្ននេះ មិនទាន់មានដំណើរការច្បាស់លាស់សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នៅឡើយទេ។ ដំណើរការការត្រឡប់មកវិញដោយមិនស្ម័គ្រចិត្តដែលបានលេចឡើង ជាទូទៅ អនុលោមទៅតាមដំណើរការដែលបានអនុវត្តនៅក្នុងស្តង់ដានីតិវិធីប្រតិបត្តិ (SOPs)ដែលឆ្លើយតបទៅនឹងការជួញដូរ។ រៀបរាប់នៅក្នុងតារាងទី ១ ខាងក្រោមគឺជាតួអង្គ តួនាទី និងទំនួលខុសត្រូវសំខាន់ៗ ដូចដែលបានកើតឡើងស្របគ្នាទៅនឹងការធ្វើមាតុភូមិនិវត្តន៍ដោយមិនស្ម័គ្រចិត្ត។

### តារាងទី ១: អ្នកពាក់ព័ន្ធសំខាន់ៗ

| ប្រទេសថៃ | ប្រទេសកម្ពុជា |
|---|---|
| **នាយកដ្ឋានកុមារ និងយុវជនប្រទេសថៃ** (MHDHS) ផ្តល់ការថែទាំ និងកិច្ចការពារក្នុងប្រទេសថៃ ថែទាំកុមារដែលត្រឡប់មកប្រទេសវិញដោយមិនស្ម័គ្រចិត្ត ភ្ជាប់ទំនាក់ទំនងជាមួយមន្ត្រីកម្ពុជា នៅពេលត្រឡប់មកវិញ។<br><br>**អង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសថៃ** ផ្តល់ជំនួយដល់កុមារនៅក្នុងប្រទេសថៃ និងធ្វើជាបណ្តាញភ្ជាប់ទំនាក់ទំនងដល់កុមារដែលត្រូវបានបញ្ជូនមកវិញដោយមិនស្ម័គ្រចិត្ត។ អង្គការក្រៅរដ្ឋាភិបាលសំខាន់ៗ រួមមាន អង្គការមិត្តសម្លាញ់អន្តរជាតិ, អង្គការទស្សនៈពិភពលោក បណ្តាញអង្គការ C-TIP Network, មណ្ឌលសំចត<br>ស្ថានទូតកម្ពុជាភ្ជាប់ និងគាំទ្រការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ<br>មន្ត្រីអន្តោប្រវេសន៍ភ្ជាប់ទំនាក់ទំនងក្នុងការគ្រប់គ្រងការត្រឡប់មកវិញនៅពេលមកដល់ព្រំដែន។ | **មន្ត្រីអន្តោប្រវេសន៍៖** ពេលមកដល់ព្រំដែន មន្ត្រីអន្តោប្រវេសន៍កម្ពុជាទទួលកុមារដែលធ្វើមាតុភូមិនិវត្តន៍ដោយមិនស្ម័គ្រចិត្ត ផ្ទៀងផ្ទាត់អត្តសញ្ញាណ និងទាក់ទងទៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត<br><br>**មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** (ពហុវិស័យ) ទទួលកុមារ និងអាចផ្តល់ការថែទាំបណ្តោះអាសន្ន។ តាមរយៈការជូនដំណឹងជាមុន មជ្ឈមណ្ឌលសំចតប៉ោយប៉ែត (ប្រើទម្រង់វែងសម្រាប់ការជួញដូរ) វាយតម្លៃ និងទាក់ទងទៅមន្ទីរសង្គមកិច្ចខេត្ត (PDoSVY)<br><br>**មណ្ឌលទទួលពលករកំរៀង** ក៏មានប្រតិបត្តិការនៅច្រកព្រំដែន (ខេត្តបាត់ដំបង) ហើយអាចទទួលការបញ្ជូនពីមន្ត្រីព្រំដែន ឬពីជនទេសន្តរប្រវេសន៍ផ្ទាល់។ មណ្ឌលជួយដល់ការវាយតម្លៃតម្រូវការ និងដំណើរការសមាហរណកម្មឡើងវិញ។<br><br>**មន្ទីរសង្គមកិច្ចខេត្ត(*PDoSVY*)** អនុវត្តដំណើរការសម្រាប់ការវិលត្រឡប់របស់កុមារទៅកាន់សហគមន៍ដោយប្រើប្រព័ន្ធគ្រប់គ្រងករណីបច្ចុប្បន្ន គ្រប់គ្រងដោយ *Primero CPIMS+* សម្រាប់កុមារដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ដោយមិនស្ម័គ្រចិត្ត។<br>**ការិយាល័យសុខុមាលភាពសង្គមស្រុក** ផ្តល់ការគ្រប់គ្រងករណីកិច្ចការពារកុមារ សម្រាប់កុមារដែលបានត្រឡប់មកវិញ (និងសម្រាប់កុមារដែលទុកនៅស្រុកកំណើតផងដែរ) |

[81] Ibid

| | |
|---|---|
| | **អង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា** ផ្តល់ការគាំទ្រផ្នែកកិច្ចការពារកុមារជាច្រើន រួមទាំងកិច្ចការពារកុមារ និងការទប់ស្កាត់។ ធ្វើការជិតស្និទ្ធជាមួយអ្នកផ្តល់សេវារដ្ឋាភិបាល។ |

អង្គការក្រៅរដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់សេវាដល់គ្រួសារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនកំពុងធ្វើការនៅតំបន់ព្រំដែន ឬខេត្តដែលក្រុមគ្រួសារត្រឡប់មកវិញ។ សេវាកម្មទាំងនេះមានប្រយោជន៍សម្រាប់គ្រួសារ និងជាផ្នែកសំខាន់នៃដំណើរការ។ បញ្ហាប្រឈម គឺថាសេវាទាំងនេះមិនអាចផ្តល់ទៅគ្រប់គ្នាបានទេ ហើយជាញឹកញាប់ វាជាគម្រោងខ្លីប៉ុណ្ណោះ។ សូមមើលឧបសម្ព័ន្ធទី ១ សម្រាប់ការគូសផែនទីរបស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជា។ គេចាំបាច់ត្រូវមានដំណើរការច្បាស់លាស់ ដើម្បីការពារសិទ្ធិកុមារ និងផ្តល់ឧត្តមប្រយោជន៍ដល់ពួកគេ ដោយកំណត់តួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់តួអង្គនីមួយៗ រួមជាមួយការកំណត់ក្របខ័ណ្ឌពេលវេលា។ គ្មានដំហានណាផ្សេងទៀតដែលកំណត់ឧត្តមប្រយោជន៍ដល់កុមារ ទោះបីមានក្របខ័ណ្ឌច្បាប់ភាគច្រើនផ្តល់អាទិភាពដល់ចំណុចទាំងនេះក៏ដោយ។

## ការអនុវត្ត និងគំរូល្អៗក្នុងកិច្ចការពារ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញចំពោះកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍

ខាងក្រោមនេះ ជាសេចក្តីសង្ខេបអំពីទិដ្ឋភាពទូទៅគំរូនៃការអនុវត្តល្អៗ។ បញ្ហាប្រឈមដែលប្រទេសថៃ និងប្រទេសកម្ពុជាប្រឈម គឺមានលក្ខណៈជាសកល ទោះបីជាគំរូល្អមួយចំនួនបានលេចឡើង ដើម្បីធានាថា គ្រួសារដែលមានកូនត្រូវបានរៀបចំក៏ដោយ យើងយល់កាន់តែច្បាស់អំពីបទពិសោធន៍របស់ពួកគេ ហើយយើងក៏អាចឆ្លើយតបបានសមស្របផងដែរ។ ឧទាហរណ៍មួយចំនួនមានដូចខាងក្រោម៖

**កិច្ចសហការជាយុទ្ធសាស្ត្ររវាងអង្គការយូនីសេហ្វ និងអង្គការ IOM៖** នៅខែកញ្ញា ឆ្នាំ ២០២២ អង្គការ IOM និងយូនីសេហ្វ បានចាប់ផ្តើមសំណុំឧបករណ៍ថ្មីដើម្បីជួយអ្នកអនុវត្តក្នុងការអនុវត្តតាមនីតិវិធីនៃឧត្តមប្រយោជន៍សម្រាប់កុមារទេសន្តរប្រវេសន៍ និងសម្របសម្រួលជួយធ្វើសមាហរណកម្មឡើងវិញសម្រាប់កុមារ និងគ្រួសាររបស់ពួកគេ។ ឧបករណ៍ទាំងនេះ បំពេញបន្ថែមដល់មេរៀនក្នុងសៀវភៅការធ្វើសមាហរណកម្មឡើងវិញរបស់អង្គការ មានចំណងជើងថា *"វិធីសាស្ត្រសិទ្ធិកុមារចំពោះសមាហរណកម្មប្រកបដោយនិរន្តរភាពនៃកុមារ និងគ្រួសារទេសន្តរប្រវេសន៍"*[82] ។ អនុលោមតាមក្របខ័ណ្ឌអន្តរជាតិ មូលដ្ឋាននៃមេរៀននេះគឺថា វិធីសាស្ត្រសិទ្ធិកុមារក្នុងការធ្វើសមាហរណកម្មឡើងវិញ ចាប់ផ្តើមជាមួយនឹងការសម្រេចចិត្តត្រឡប់មកវិញដែលត្រូវបានកំណត់ថាជាឧត្តមប្រយោជន៍កុមារ។

**ភាពជាដៃគូស្រាវជ្រាវសកម្មភាព**[83]: គម្រោង *MPF* ដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុប "កុមារទុកនៅស្រុកកំណើតដោយពលកម្មទេសន្តរប្រវេសន៍" មានគោលបំណងស្វែងយល់ពីផលប៉ះពាល់នៃការធ្វើទេសន្តរប្រវេសន៍

[82] https://publications.iom.int/books/reintegration-handbook-module-6-child-rights-approach-sustainable-reintegration-migrant
[83] EU-funded MPF project Children Left Behind by Labour Migration (CASTLE) was implemented by Babeș-Bolyai University of Romania, Terre des hommes – Aide à l’enfance dans les monde, Terre des hommes Moldova, Terre des hommes Ukraine, the Ukrainian Institute for

ចំពោះកុមារទុកនៅស្រុកកំណើត និងកុមារដែលចាកចេញជាមួយឪពុកម្តាយ។ តាមរយៈការស្រាវជ្រាវជាក់ស្តែង ដោយប្រើវិធីសាស្ត្រចូលរួមដែលកុមារ និងមនុស្សពេញវ័យ បានចូលរួមយ៉ាងសកម្មក្នុងនាមជាសហអ្នកស្រាវជ្រាវ គម្រោងនេះបានផ្តល់ការយល់ដឹងអំពីបទពិសោធន៍របស់កុមារ ឪពុកម្តាយ និងអ្នកពាក់ព័ន្ធដទៃទៀត។ ការស្រាវជ្រាវសកម្មភាពបានគូសបង្ហាញពីបញ្ហាប្រឈមរបស់កុមារ "ទុកនៅស្រុកកំណើត" រួមទាំងផែនការមើលថែមិនគ្រប់គ្រាន់ និងការងារគ្រោះថ្នាក់។ តម្រូវការសម្រាប់ការបង្កើតសេចក្តីណែនាំបណ្តុះបណ្តាល/សៀវភៅណែនាំតម្រង់ទិសអ្នកជំនាញ ឪពុកម្តាយ និងអ្នកថែទាំត្រូវបានកំណត់ ក្នុងដំណាក់កាលស្រាវជ្រាវ។ សេចក្តីណែនាំនេះពង្រឹងចំណេះដឹងរបស់ពួកគេ ដូចជា ការរៀបចំមុនពេលចេញដំណើរ ការផ្ទេរការថែទាំកុមារ ឧបករណ៍ទំនាក់ទំនងឆ្លងព្រំដែន ជំនួយផ្លូវចិត្ត និងកិច្ចការពារផ្លូវច្បាប់របស់កុមារដែលទុកនៅស្រុក។

**គោលការណ៍ណែនាំរបស់ប្រទេសចិនស្តីពីកិច្ចការពារកុមារដែលទុកនៅស្រុក៖** នៅខែកុម្ភៈ ឆ្នាំ ២០១៨ ប្រទេសចិនបានបង្កើតគោលការណ៍ណែនាំរបស់ក្រុមប្រឹក្សារដ្ឋស្តីពីកិច្ចការពារកុមារដែលទុកនៅស្រុកកំណើត ដោយមានការជួយជ្រោមជ្រែងពីអង្គការយូនីសេហ្វ។ គោលការណ៍ណែនាំមានគោលបំណងកាត់បន្ថយចំនួនកុមារដែលទុកនៅតាមជនបទ ដែលកើតឡើងដោយសារឪពុកម្តាយធ្វើទេសន្តរប្រវេសន៍ស្វែងរកឱកាសការងារ និងធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាព និងកិច្ចការពារកុមាររាប់លាននាក់ដែលកំពុងស្ថិតក្នុងស្ថានភាពនេះ។ គោលការណ៍ណែនាំបង្ហាញអំពីទំនួលខុសត្រូវច្បាស់លាស់សម្រាប់គ្រួសារ ក៏ដូចជាអាជ្ញាធរមូលដ្ឋាន ដើម្បីជួយធានាថាកុមារត្រូវបានមើលថែ និងការពារនៅពេលដែលឪពុកម្តាយធ្វើទេសន្តរប្រវេសន៍ឆ្ងាយពីផ្ទះ។

**គំរូស្តីពីការសម្របសម្រួលអន្តរវិស័យសម្រាប់ការផ្តល់សេវាការពារកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍៖** នៅឆ្នាំ ២០២១ ស្នងការសិទ្ធិមនុស្សនៅសាធារណរដ្ឋកាហ្សាក់ស្ថានបានបង្កើត "គំរូ" ដើម្បីផ្តល់សេវាកិច្ចការពារដល់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ សៀវភៅណែនាំពន្យល់អំពីបរិបទសម្រាប់ការបង្កើតគំរូ សេវាការពារ និងមានពិធីការការងារអន្តរវិស័យ ដើម្បីគាំទ្រដល់ស្ថាប័នរដ្ឋ ស្ថាប័នសាធារណៈ អ្នកជំនាញ និងអ្នកអនុវត្តនៅក្នុងទីតាំងសាកល្បងលើការអនុវត្តមុខងាររបស់ពួកគេ។ សៀវភៅណែនាំនេះ មានគោលបំណងប្រើប្រាស់ដោយស្ថាប័នរដ្ឋ ស្ថាប័នសាធារណៈ អ្នកជំនាញ និងអ្នកអនុវត្ត។

**ការលើកកម្ពស់ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមាន៖** នៅឆ្នាំ ២០១៩ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (*UNHCR*) ប្រចាំប្រទេស អ៊ូហ្គង់ដា បានផ្តួចផ្តើមកម្មវិធីពង្រឹងគ្រួសារ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារកាន់តែមានលក្ខណៈស្ថាបនាដោយផ្តោតលើកុមារដែលរងផលប៉ះពាល់ដោ**ទេសន្តរប្រវេសន៍**យ[84]។ សហការជាមួយដៃគូ *UNHCR* បានភ្ជាប់នីតិវិធីឧត្តមប្រយោជន៍ (*BIPs*) ការថែទាំជំនួសសម្រាប់អនីតិជនដែលគ្មានអ្នករួមដំណើរជាមួយ និងសកម្មភាពចិញ្ចឹមបីបាច់ដោយវិជ្ជមាន ដើម្បីលើកកម្ពស់បរិយាកាសគាំទ្រដល់យុវជនជនភៀសខ្លួន។ គោលដៅសំខាន់គឺដើម្បីពង្រឹងទំនាក់ទំនងរវាងឪពុកម្តាយ

Social Research Oleksandr Yaremenko, and the Academy of Economic Studies of Moldova between June 2021 and December 2023. https://www.migrationpartnershipfacility.eu/news/castleprojectwrapsup

[84] https://www.unhcr.org/sites/default/files/2023-05/child-protection-practices-unhcr-2014-2022.pdf

និងកូនរបស់ពួកគេ ខណៈកុមាររងគ្រោះថ្នាក់ ឬមិនយកចិត្តទុកដាក់ទទួលបានជំនួយទាន់ពេលវេលា និងប្រកបដោយគុណភាព។

**ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនង៖** ការប្រាស្រ័យទាក់ទងដែលអាចទុកចិត្តបាន និងតម្លៃសមរម្យរវាងជនទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ មានសារៈសំខាន់ណាស់ ក្នុងការរក្សាទំនាក់ទំនងសំខាន់ៗ និងធានាបាននូវសុខុមាលភាពទូទៅរបស់ភាគីពាក់ព័ន្ធទាំងអស់។ គំនិតផ្តួចផ្តើមមួយចំនួនលើកទឹកចិត្តនិយោជកឱ្យផ្តល់ឱ្យជនទេសន្តរប្រវេសន៍ដែលរស់នៅក្នុងស្ថានភាពបង្ខាំង ដូចជាអន្តេវាសិកដ្ឋាន ការចូលប្រើ ឧបករណ៍ និងបច្ចេកវិទ្យាចាំបាច់ដែលមិនមានការរឹតបន្តឹង។ ឧទាហរណ៍ជាវិជ្ជមាន មានដូចជា ការវិនិយោគ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ជាពិសេសនៅតំបន់ដាច់ស្រយាល ឬនៅឆ្ងាយជាមុន ដើម្បីជួយឱ្យមានសេវាជាប់[85]។

**គាំទ្រក្រុមគ្រួសារដែលទុកនៅស្រុកកំណើត៖** កុមារ អ្នកមើលថែ និងមនុស្សចាស់ដែលទុកនៅស្រុកកំណើត នៅពេលពលករទេសន្តរប្រវេសន៍ចាកចេញ ពួកគេប្រឈមបញ្ហាចម្បងជាច្រើន។ ដើម្បីជួយដោះស្រាយបញ្ហាទាំងនេះ រដ្ឋាភិបាល អង្គការមិនរកប្រាក់ចំណេញ និងអង្គការសាសនាបានបង្កើតអន្តរាគមន៍ផ្សេងៗគ្នា។ ឧទាហរណ៍ បង្កើតសេវាពេទ្យ និងសេវាប្រឹក្សាសម្រាប់ក្រុមងាយរងគ្រោះទាំងនេះទទួលបាន ផ្តល់ការតម្រង់ទិសមុនពេលចេញដំណើរដល់ទាំងជនទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ ក្នុងគោលបំណងជួយបុគ្គល និងកូនៗជាទីស្រលាញ់ រៀបចំខ្លួនឱ្យកាន់តែប្រសើរសម្រាប់ការបែកគ្នា រក្សាទំនាក់ទំនងពីចម្ងាយក្នុងរយៈពេលនៅបរទេស និងយល់ពីស្ថានភាពគ្នាទៅវិញទៅមក។

### ចន្លោះប្រហោងក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ និងការអនុវត្ត

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយរវាងប្រទេសថៃ និងប្រទេសកម្ពុជាសម្រាប់ការបង្ការ និងឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ត្រូវបានដឹកនាំដោយការប្តេជ្ញាចិត្ត នីតិច្បាប់ និងគោលនយោបាយអន្តរជាតិក្នុងតំបន់ ក្នុងប្រទេសថៃ និងក្នុងប្រទេសកម្ពុជា។ ទោះបីជាមានគោលនយោបាយសំខាន់ៗកំពុងត្រូវអនុវត្តក្តី ក៏នៅមានចន្លោះប្រហោងទាំងនៅក្នុងគោលនយោបាយ និងការអនុវត្តផងដែរ។

**ឧត្តមប្រយោជន៍កុមារ៖** មាត្រា ៣(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ តម្រូវឱ្យមានឧត្តមប្រយោជន៍កុមារ ដើម្បីពិចារណាជាចម្បងក្នុងគ្រប់សកម្មភាពដែលទាក់ទងនឹងកុមារ។ គោលការណ៍នេះតម្រូថាសិទ្ធិរបស់កុមារទាំងអស់ត្រូវបានគោរព ការពារ និងបំពេញដោយគ្មានការរើសអើងដោយផ្អែកលើស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ ឬឪពុកម្តាយរបស់ពួកគេ។ ការពិនិត្យផ្នែកច្បាប់ដែលធ្វើឡើងដោយអង្គការយូនីសេហ្វក្នុងឆ្នាំ ២០២៣ បានរកឃើញថា ឧត្តមប្រយោជន៍កុមារត្រូវបានពិពណ៌នាយ៉ាងច្បាស់លាស់នៅក្នុងគោលនយោបាយសកលតំបន់ និងថ្នាក់ជាតិ[86]។ ទោះបីការប្តេជ្ញាចិត្តទាំងនេះស្របតាមគោលការណ៍ឧត្តមប្រយោជន៍កុមារក្តី ក៏មិនមានដំណើរការអនុវត្តឧត្តមប្រយោជន៍នេះទេ។ ការកំណត់ឧត្តមប្រយោជន៍កុមារមានសារសំខាន់ណាស់ក្នុងការធានាថាសិទ្ធិរបស់កុមារត្រូវបានការពារនៅក្នុងសកម្មភាពណាមួយ។

[85] https://www.caritas.org/2014/07/supporting-children-migrant-parents-south-east-asia/
[86] UNICEF East Asia and Pacific (2023). *Situation Analysis of Children Affected by Migration in ASEAN Member States: Legal Review*: Bangkok.

**សិទ្ធិទទួលបានការអប់រំ ការថែទាំសុខភាព៖** ទោះបីក្របខ័ណ្ឌច្បាប់ និងគោលនយោបាយនៅក្នុងប្រទេសថៃអនុញ្ញាតឱ្យកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ទទួលបានការអប់រំ និងការថែទាំសុខភាពក្តី ក៏ឧបសគ្គជាក់ស្តែងនៅតែកើតឡើង។ ឪពុកម្តាយទេសន្តរប្រវេសន៍ប្រហែលជាមិនដឹងអំពីសិទ្ធិរបស់ពួកគេ នីតិវិធី និងដំណើរការចុះឈ្មោះ ឬក៏ពួកគេអាចខ្លាចត្រូវបណ្តេញចេញ ប្រសិនបើពួកគេមានស្ថានភាពមិនប្រក្រតី ហើយពួកគេព្យាយាមចូលប្រើប្រព័ន្ធ។ ឧបសគ្គផ្សេងៗ មានដូចជាបញ្ហាភាសា កុមារធ្វើការ ឬការមើលថែប្អូនៗបង្កើតរបស់ពួកគេ។ អ្នកខ្លះបានកត់សម្គាល់ថា មន្ត្រីនៅប្រទេសថៃក៏មិនយល់ច្បាស់លាស់អំពីនីតិវិធី និងសិទ្ធិរបស់ឪពុកម្តាយទេសន្តរប្រវេសន៍ដែរ។ វាមានសារៈសំខាន់ក្នុងការលើកទឹកចិត្តឱ្យមានការចូលរួមក្នុងការអប់រំ និងការទទួលបានការថែទាំសុខភាព ដើម្បីធានាថាឪពុកម្តាយយល់ដឹងអំពីសិទ្ធិរបស់ពួកគេ ដំណើរការ និងនីតិវិធីក្នុងការចូលប្រើប្រាស់សេវានីមួយៗ។

**ការចុះបញ្ជី (កំណើត) នៅក្នុងប្រទេសថៃ៖** ជាថ្មីម្តងទៀត ទោះបីមានការអនុញ្ញាតដល់ជនទេសន្តរប្រវេសន៍ប្រក្រតីក្តី និងមិនប្រក្រតីក្តី ឱ្យទៅចុះបញ្ជីកំណើតសម្រាប់កូនៗរបស់ពួកគេក៏ដោយ ក៏នៅមានបញ្ហាប្រឈម។ ឧបសគ្គនេះដូចគ្នាចំពោះការថែទាំសុខភាព គឺកង្វះចំណេះដឹងភាសា ការភ័យខ្លាចគេនិរទេស - ដែលជាកត្តារារាំងឪពុកម្តាយមិនឱ្យទៅចុះឈ្មោះកូនៗរបស់ពួកគេ។ មានករណីខ្លះ ការកំណត់អត្តសញ្ញាណរបស់កុមារមានភាពលំបាក ដោយកុមារជាច្រើនខកខានទៅចុះបញ្ជី។ កុមារកើតនៅប្រទេសថៃពីឪពុកម្តាយខ្មែរ ដោយគ្មាន
ឯកសារភ្ជាប់សញ្ជាតិកម្ពុជា កុមារដែលកើតពីឪពុកម្តាយជាជនជាតិថៃ និងខ្មែរ ដោយគ្មានឯកសារសញ្ជាតិ។ ករណីទាំងនេះអាចមានភាពស្មុគស្មាញក្នុងការដោះស្រាយ និងទាមទារនីតិវិធីច្បាស់លាស់មួយដើម្បីតាមដាន និងសម្រេចចិត្តកំណត់អត្តសញ្ញាណ និងសញ្ជាតិរបស់កុមារ ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការពារសិទ្ធិ និងការទទួលបានសេវាដល់ពួកគេ។

**ប្រព័ន្ធការពារកុមារ:** ទាំងប្រទេសថៃ និងប្រទេសកម្ពុជា មានគោលបំណងអនុវត្តប្រព័ន្ធការពារកុមារ ឆ្លើយតបទៅនឹងកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ នៅក្នុងប្រទេសថៃ មានក្របខ័ណ្ឌគោលនយោបាយបង្កើតបានជាប្រព័ន្ធការពារកុមារ រួមទាំងកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ ដូចគ្នាចំពោះកម្ពុជាផងដែរ។ ប៉ុន្តែ ការអនុវត្តជាក់ស្តែងនៅតែជាបញ្ហាប្រឈម និងមានចន្លោះប្រហោង។

នៅក្នុងប្រទេសកម្ពុជា ប្រព័ន្ធការពារកុមារឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍មុនពេលចេញដំណើរ និងពេលត្រឡប់មកវិញ។ ប៉ុន្តែ នៅមានចន្លោះដែរ។ បច្ចុប្បន្ននេះ ដូចដែលបានកត់សម្គាល់ ប្រព័ន្ធគ្រប់គ្រងករណី Primero មិនបង្កើតឯកសារគ្រប់គ្រាន់សម្រាប់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នោះទេ និងតម្រូវឱ្យពង្រីកប្រភេទទិន្នន័យដែលប្រមូលបាន។

ក្រៅពីនេះ មិនមានដំណើរការច្បាស់លាស់សម្រាប់ការចងក្រងឯកសារអំពីការធ្វើទេសន្តរប្រវេសន៍ និងការវិលត្រឡប់មកវិញរបស់កុមារ ហើយគ្មានប្រព័ន្ធគ្រប់គ្រាន់សម្រាប់ការគាំទ្រទាំងការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត និងដោយមិនស្ម័គ្រចិត្ត។ ក្នុងករណីគ្មានប្រព័ន្ធគ្រប់គ្រាន់សម្រាប់ឆ្លើយតបចំពោះកុមារដែលរងផល

ប៉ះពាល់ដោយទេសន្តរប្រវេសន៍ មានកាលៈទេសៈមួយចំនួន ដូចជាការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការ នៅពេលដែលឪពុកម្តាយត្រូវបានចាប់ខ្លួន ពេលនោះនីតិវិធីមួយចំនួនសម្រាប់ធ្វើមាតុភូមិនិវត្តន៍កុមារដែលរងគ្រោះដោយការជួញដូរត្រូវយកទៅអនុវត្ត។ ដោយសារមិនមាននីតិវិធីច្បាស់លាស់ចំពោះកុមារដែលរងផលប៉ះពាល់ដោយ ទេសន្តរប្រវេសន៍នេះហើយ ទើបមន្ត្រី និងអ្នកផ្តល់សេវាយកនីតិវិធីនេះទៅប្រើពេលចាំបាច់ ក្នុងករណីមិនមាននីតិវិធីសម្រាប់កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។

ករណីគ្មានប្រព័ន្ធគ្រប់គ្រាន់សម្រាប់ឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ មានកាលៈទេសៈមួយចំនួន ដូចជាការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការ នៅពេលដែលឪពុកម្តាយត្រូវបានចាប់ខ្លួន ពេលនោះនីតិវិធីមួយចំនួនសម្រាប់ការធ្វើមាតុភូមិនិវត្តន៍កុមារត្រូវបានអនុវត្ត។ ដោយសារមិនមាននីតិវិធីច្បាស់លាស់អនុវត្តចំពោះកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ទើបមន្ត្រី និងអ្នកផ្តល់សេវាយកនីតិវិធីនេះទៅប្រើពេលចាំបាច់ ក្នុងករណីមិនមាននីតិវិធីសម្រាប់កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។

ដោយសារកុមារទទួលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ អាចមានបទពិសោធន៍ផ្សេងៗគ្នា (ឪពុកម្តាយត្រូវបានឃុំខ្លួន ឪពុកម្តាយស្លាប់។ល។) ចាំបាច់គេត្រូវមានដំណើរការ និងនីតិវិធីច្បាស់លាស់។ តួនាទី និងទំនួលខុសត្រូវរបស់ប្រទេសថៃ និងប្រទេសកម្ពុជា ត្រូវតែបញ្ជាក់ឱ្យច្បាស់ រួមទាំងនីតិវិធីការពារសិទ្ធិរបស់កុមារ។ ចំណុចនេះធានាឱ្យមានដំណើរការច្បាស់លាស់ ការគ្រប់គ្រងករណី រួមទាំងដំណើរការ និងជម្រើសថែទាំជាបណ្តោះអាសន្នដល់កុមារ (គ្មានការឃុំខ្លួន) ដំណើរការច្បាស់លាស់សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការកំណត់ដំណើរការសម្របសម្រួល និងសហការរវាងប្រទេសនិងប្រទេស។

ដូចគ្នានេះផងដែរ ដូចដែលបានចែកលើកឡើងរួចមកហើយ មានឱកាសសម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍ប្រព័ន្ធកិច្ចការពារកុមារបែបអាកាសធាតុឆ្លាតវៃ ដែលអាចជួយដល់កុមារងាយរងគ្រោះគ្រប់ប្រភេទ រួមទាំងជនចំណាកស្រុក ដើម្បីឱ្យពួកគាត់អាចទទួលបានសេវាសង្គម ទោះបីជាមានគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុកើតឡើងក៏ដោយ។

**យន្តការសម្របសម្រួល៖** យោងទៅតាមលក្ខណៈនៃស្ថានភាពឆ្លងច្រកព្រំដែន ការឆ្លើយតបប្រកបដោយគុណភាពចំពោះកុមារ ទាមទារឱ្យមានការសម្របសម្រួលនិងការចែករំលែកព័ត៌មានជាប្រព័ន្ធ រវាងប្រទេសនិងប្រទេស ដែលមានដំណើរការ និងនីតិវិធីច្បាស់លាស់។ បច្ចុប្បន្នមិនមានយន្តការផ្លូវការដើម្បីទាក់ទងរវាងប្រទេស និងប្រទេសនោះទេ។ ជាថ្មីម្តងទៀត យន្តការឆ្លើយតបទៅនឹងការជួញដូរកុមារត្រូវបានប្រើប្រាស់។ មជ្ឈមណ្ឌលសំចតក្រុងប៉ោយប៉ែតបម្រើជាតំណភ្ជាប់ដ៏សំខាន់រវាងប្រទេស និងប្រទេស។ ដើម្បីធានាថាមានដំណើរការច្បាស់លាស់ បន្ថែមលើតួនាទី និងការទទួលខុសត្រូវជុំវិញកិច្ចការពារកុមារ គេត្រូវតែមាននីតិវិធីច្បាស់លាស់ដើម្បីសម្របសម្រួលរវាងប្រទេសនិងប្រទេស។

**ការចូលរួមរបស់កុមារ៖** ជាទូទៅ កុមារមិនមានសំឡេងក្នុងបង្កើតកម្មវិធី និងគោលនយោបាយ ដូច្នេះ ពួកគេប្រហែលជាមិនដឹងអំពីសិទ្ធិរបស់ខ្លួន ហើយមានឱកាសតិចតួចក្នុងការផ្តល់ជាតុចូល។ តាមការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) គេត្រូវផ្តល់អាទិភាពដោយធានាថា កុមារមានឱកាសចូលរួម និងបញ្ចេញសំឡេង

ក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ ក្នុងដំណើរការបង្កើតគោលនយោបាយ និងតាមរយៈឱកាសសិក្សាអប់រំ។

**ឯកសារ និងទិន្នន័យ៖** បញ្ហាប្រឈមមួយដែលបានកំណត់នៅក្នុងការស្រាវជ្រាវនេះគឺការខ្វះទិន្នន័យ។ បញ្ហានេះធ្វើឱ្យមានការលំបាកក្នុងការយល់អំពីចំនួនកុមារទេសន្តរប្រវេសន៍ និងបញ្ហាប្រឈមដែលពួកគេជួបប្រទះ។ ទិន្នន័យត្រូវបានប្រមូលនៅតាមដំណាក់កាលផ្សេងៗ។ ឧទាហរណ៍ មជ្ឈមណ្ឌលសំចតក្រុងប៉ោយប៉ែត មានទិន្នន័យអំពីកុមារដែលត្រឡប់មកវិញតាមរយៈមជ្ឈមណ្ឌលរបស់ខ្លួន។ ប៉ុន្តែ កុមារ និងគ្រួសារភាគច្រើនមិនសូវឆ្លងកាត់មជ្ឈមណ្ឌលនេះទេ។ ប្រព័ន្ធគ្រប់គ្រងករណីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) *Primero* បានប្រមូលទិន្នន័យ "កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍" ប៉ុន្តែមិនផ្តល់ព័ត៌មានលម្អិតបន្ថែម។ មានការសិក្សាតិចតួចដែលបង្ហាញពីចំនួនកុមារ ដោយសារពិបាកទៅដល់ទីកន្លែងពួកគេ ហើយរកមិនឃើញពួកគេ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### សេចក្តីសន្និដ្ឋាន

កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ឬកុមារក្នុងបរិបទទេសន្តរប្រវេសន៍ រួមមាន**កុមារដែលទុកនៅស្រុកកំណើតឬទុកនៅក្នុងសហគមន៍ កុមារធ្វើដំណើរជាមួយឪពុកម្តាយដើម្បីធ្វើការ ឬធ្វើដំណើរដោយខ្លួនឯង (មិនមានអ្នកទៅជាមួយ) ឬបំបែកពីឪពុក ម្តាយរបស់ពួកគេ។** កុមារអាច ឬមិនអាចធ្វើការ។ គេមិនច្បាស់ថាចំនួនកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ឬក្រុមអាយុនោះទេ ដោយសារគ្រួសារជាច្រើនធ្វើទេសន្តរប្រវេសន៍តាមមធ្យោបាយមិនប្រក្រតី។ គ្រួសារ និងពេលខ្លះ មានកុមារផង ទំនងជាធ្វើការក្នុងវិស័យក្រៅប្រព័ន្ធដែលមិនសូវមានការគ្រប់គ្រង។

**កុមារប្រឈមហានិភ័យនៃកិច្ចការពារ**ជាច្រើន ដោយត្រូវបានទុកនៅស្រុកកំណើត ធ្វើដំណើរជាមួយឪពុកម្តាយ ឬតែម្នាក់ឯង។ ទាំងនេះរួមមានការថែទាំ និងជំនួយមិនគ្រប់គ្រាន់ អស្ថិរភាពសេដ្ឋកិច្ច តម្រូវការមូលដ្ឋានដែលមិនត្រូវបានបំពេញ កង្វះអាហារូបត្ថម្ភ ភាពតានតឹងផ្លូវចិត្ត ការអភិវឌ្ឍន៍សង្គម ការកើនឡើងហានិភ័យនៃការប្រើប្រាស់គ្រឿងញៀន ការកើនឡើងហានិភ័យនៃការមិនយកចិត្តទុកដាក់ ការរំលោភបំពានលើរាងកាយ ការរំលោភបំពានផ្លូវភេទ ការរើសអើង ពលកម្មកុមារ។ ហានិភ័យបន្ថែមចំពោះកុមារនៅក្នុងប្រទេសថៃរួមមានហានិភ័យអំឡុងពេលធ្វើដំណើរ ដូចជាការរំលោភបំពាន ការកេងប្រវ័ញ្ច ឬការជួញដូរ ឬត្រូវបានបំបែកចេញពីគ្រួសារ ពលកម្មកុមារ ការឃុំខ្លួន ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន ការរើសអើង និងការថែទាំមិនគ្រប់គ្រាន់។ ឧបសគ្គភាសា និងកង្វះឯកសារផ្លូវច្បាប់អាចធ្វើឱ្យមានភាពស្មុគស្មាញដល់បញ្ហាទាំងនេះ រួមជាមួយនឹងស្ថានភាពនៃការធ្វើទេសន្តរប្រវេសន៍តាមមធ្យោបាយមិនប្រក្រតី។ ហានិភ័យអាចកើតឡើងខុសគ្នាចំពោះក្មេងប្រុស និងក្មេងស្រី។ ខណៈពេលដែលកុមារទាំងអស់ប្រឈមនឹងហានិភ័យ ក្មេងប្រុសទំនងជាជួបប្រទះនឹងការធ្វើការងារដោយបង្ខំ ហើយក្មេងស្រីទំនងជាជួបប្រទះការកេងប្រវ័ញ្ចផ្លូវភេទ ការរៀបការដោយបង្ខំ។ កុមារដែលមានពិការអាចប្រឈមមុខនឹងការមាក់ងាយ ការរើសអើង និងការធ្វើការងារដោយបង្ខំ។

**កុមារប្រឈមបញ្ហាក្នុងការទទួលបានសេវា**នៅក្នុងប្រទេសកម្ពុជា និងក្នុងប្រទេសថៃ។ នៅក្នុងប្រទេសកម្ពុជា ការផ្តល់សេវា មាន ប៉ុន្តែចម្ងាយផ្លូវ ភាពក្រីក្រ កង្វះការកំណត់គោលដៅសេវាផ្សេងៗជាពិសេសសម្រាប់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ និងកត្តាផ្សេងៗទៀត គឺជាបញ្ហាប្រឈម។ សេវាបែបនេះត្រូវតែមានផងដែរ ទោះបីជាមានគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុកើតឡើងក៏ដោយ ដែលទាមទារឱ្យមានការគាំទ្រឱ្យដំណើរការប្រព័ន្ធកិច្ចការពារកុមារអាកាសធាតុឆ្លាតវៃ។ នៅប្រទេសថៃ ការអប់រំ និងសុខភាពមានកង្វះឯកសារ ព័ត៌មាន ភាសាជាឧបសគ្គ។ កុមារពិការអាចខ្វះលទ្ធភាពទទួលបានសេវា និងកិច្ចការពារ និងស្ថិតក្នុងចំណោមក្រុមដែលងាយទទួលរងគ្រោះបំផុត។កុមារទាំងឡាយដែលមានស្ថានភាព**មិនប្រក្រតី មានហានិភ័យកាន់តែច្រើន និងលទ្ធភាពទទួលបានសេវាមានកម្រិត។**

ក្របខ័ណ្ឌច្បាប់ មានភាពច្បាស់ ដែលថា**កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍មានសិទ្ធិដូចគ្នា** ហើយគួរតែមានសិទ្ធិទទួលបានកិច្ចការពារដូចគ្នា។ គោលការណ៍នៃឧត្តមប្រយោជន៍កុមារត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងការប្តេជ្ញាចិត្តជាច្រើន។ ទោះបីក្របខ័ណ្ឌច្បាប់ថ្នាក់តំបន់ និងថ្នាក់ជាតិ បានបញ្ចូល អាទិភាពនៃ "ឧត្តមប្រយោជន៍កុមារ" ក្តី ប៉ុន្តែមិនមាននីតិវិធីគ្រប់គ្រាន់សម្រាប់កំណត់ឧត្តមប្រយោជន៍នោះទេ។

មិនមាន**ក្របខ័ណ្ឌ ដំណើរការ និងនីតិវិធីច្បាស់លាស់សម្រាប់**ការឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃនោះទេ។ កុមារត្រូវបានបញ្ចូលក្នុងច្បាប់ការពារកុមារនៅក្នុងប្រទេសថៃ ហើយមានសិទ្ធិទទួលបានការអប់រំ ការថែទាំសុខភាព ឯកសារផ្លូវច្បាប់ ប៉ុន្តែឧបសគ្គនៅតែមាននៅក្នុងការអនុវត្ត។ ភាសា កង្វះចំណេះដឹង និងការភ័យខ្លាចការនិរទេស គឺស្ថិតក្នុងចំណោមឧបសគ្គនានា។

ខណៈដែលការឃុំខ្លួនកុមារមិនត្រូវបានហាមឃាត់ដោយច្បាប់ថៃ ប្រទេសថៃបានប្តេជ្ញាកាត់បន្ថយការឃុំខ្លួនកុមារ។ ក៏ប៉ុន្តែកុមារកម្ពុជាដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃជារឿយៗ**នៅតែត្រូវបានឃុំខ្លួន ឬជាប់នៅមណ្ឌលថែទាំជំនួសរយៈពេលយូរ។** ។ កង្វះនៃនីតិវិធីច្បាស់លាស់ និងជាប់លាប់សម្រាប់ការឆ្លើយតបចំពោះកុមារ ឬកិច្ចសហប្រតិបត្តិការចំពោះកុមារដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ រួមចំណែកដល់បញ្ហានេះ។ មានស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ទាក់ទងនឹងការគ្រប់គ្រងករណីជួញដូរមនុស្ស ប៉ុន្តែស្តង់ដារទាំងនេះមិនឆ្លើយតបបានគ្រប់គ្រាន់ចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។

**តួអង្គសំខាន់ៗក្នុងការវិលត្រឡប់មកវិញ និងមាតុភូមិនិវត្តន៍** រួមមានប៉ូលីស និងអន្តោប្រវេសន៍ សុខុមាលភាពសង្គម មជ្ឈមណ្ឌលសំចតក្រុងប៉ោយប៉ែត មណ្ឌលទទួលពលករ អ្នកផ្តល់សេវាការពារកុមាររបស់អង្គការក្រៅរដ្ឋាភិបាលទាំងក្នុងប្រទេសថៃ និងប្រទេសកម្ពុជា។

**ប្រព័ន្ធគ្រប់គ្រងករណីការពារកុមាររបស់កម្ពុជា** ផ្តោតលើកុមារដែលទុកនៅស្រុកកំណើត ឬកុមារត្រឡប់មកផ្ទះវិញ។ ប្រព័ន្ធបច្ចុប្បន្នមិនប្រមូលទិន្នន័យបានគ្រប់គ្រាន់ដែលអាចបែងចែកដើម្បីយល់ច្បាស់ពីស្ថានភាពរបស់

កុមារ។ កុមារដែលត្រឡប់មកដោយខ្លួនឯង ហើយអាចត្រូវការសេវាការពារ ច្រើនតែខកខានមិនបញ្ចូលក្នុងប្រព័ន្ធ លុះត្រាតែពួកគេត្រូវបានកំណត់អត្តសញ្ញាណតាមសហគមន៍។

# អនុសាសន៍

## ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

### សម្រាប់រដ្ឋាភិបាលប្រទេសថៃ និងប្រទេសកម្ពុជា

បង្កើត**អនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយប្រទេសថៃ ស្តីពីការឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍** ដែលបំពេញ ជំរុញនិងការពារសិទ្ធិ រួមមានការធានាក្នុងការទទួលបានសេវាសម្រាប់កុមារកម្ពុជានៅក្នុងប្រទេសថៃដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។

- អនុស្សរណៈនៃការយោគយល់គ្នា (MOU)ត្រូវដោះស្រាយផ្នែកសំខាន់ៗក្នុងការធានាឱ្យទទួលបានសេវាក្នុងប្រទេសថៃ ដោយបញ្ជាក់ឡើងវិញពីសិទ្ធិកុមារនៅប្រទេសថៃ ស្តីពីឯកសារស្របច្បាប់ សេវាអប់រំ សេវាថៃទាំសុខភាព សេវាផ្លូវច្បាប់ សេវាគាំទ្រផ្លូវចិត្ត-សង្គមនិងកិច្ចការពារ ចំពោះអំពើហិង្សា ការកេងប្រវ័ញ្ច និងការមិនអើពើ ដោយផ្តល់អាទិភាពការចែករំលែកពត៌មាន និងដកចេញ ឧបសគ្គនានាក្នុងប្រទេសថៃ។
- អនុស្សរណៈនៃការយោគយល់គ្នា (MOU)ត្រូវកំណត់ដំណើរការធ្វើមាតុភូមិនិវត្តន៍ ដូចជា ស្វែងរកអត្ត សញ្ញាណ តាមដានប្រវត្តិគ្រួសារ ការវាយតម្លៃ ការផ្ទៀងផ្ទាត់សញ្ជាតិ ការកំណត់ឧត្តមប្រយោជន៍ និងការផ្តល់សេវា រួមជាមួយនីតិវិធីធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញ។
- ត្រូវផ្តល់ឱកាសដល់កុមារ (ស្របតាមអាយុ) ដើម្បីទទួលបានទស្សនៈរបស់ពួកគេ សម្រាប់ការសម្រេចចិត្តណាមួយ។
- កិច្ចព្រមព្រៀងនេះក៏ត្រូវបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តចំពោះជម្រើសផ្សេងទៀតក្នុងការឃុំខ្លួនកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ។ គេគួរដាក់បញ្ចូលក្របខ័ណ្ឌថេរវេលាផង។

បង្កើតគំរូឆ្លងព្រំដែនទូលំទូលាយសម្រាប់ការវិលត្រឡប់មកវិញ និងការធ្វើសមាហរណកម្មកុមារ រួមជាមួយ**ស្តង់ដារនីតិវិធីប្រតិបត្តិការ រវាងប្រទេសកម្ពុជា និងប្រទេសថៃ សម្រាប់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍** អនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ CRC ជាពិសេស ស្របគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ។ ទោះបីអនុស្សរណៈនៃការយោគយល់គ្នា (MOU) និងស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) មានភាពពាក់ព័ន្ធ ទៅនឹងការប្រឆាំងការជួញដូរក្តី ក៏ឧបករណ៍ទាំងពីរនេះមិនឆ្លើយតបឱ្យបានគ្រប់គ្រាន់ចំពោះបញ្ហាកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍នោះទេ។ គេចាំបាច់ត្រូវពង្រីកដំណើរការ តែត្រូវភ្ជាប់នឹងដំណើរការថ្មី។ ផ្នែកសំខាន់ៗមួយចំនួនសម្រាប់ដាក់បញ្ចូលរួមមាន៖

- បញ្ជាក់តួនាទី និងកំណត់ទំនួលខុសត្រូវរបស់តួអង្គសំខាន់ៗ (ផ្នែកអន្តោប្រវេសន៍ កិច្ចការពារកុមារ សុខុមាលភាពសង្គម ស្ថានទូត អង្គការក្រៅរដ្ឋាភិបាល) ក្នុងប្រទេសថៃ និងប្រទេសកម្ពុជា ក្នុងវិស័យ

សំខាន់ៗដូចបានរៀបរាប់ខាងលើ។ គំរូនេះគួររួមបញ្ចូលយន្តការទំនាក់ទំនងឆ្លងព្រំដែន កិច្ចសហប្រតិបត្តិការ និងការបញ្ជូនបន្ត ដើម្បីសម្រួលដល់កិច្ចការពារ ការផ្តល់សេវា ការបញ្ជូនត្រឡប់មកវិញ និងករណីធ្វើសមាហរណកម្មឡើងវិញ។

- ស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ត្រូវដោះស្រាយបញ្ហា ដូចជាការវាយតម្លៃកែភាពងាយរងគ្រោះដោយកត្តាយេនឌ័រ ស្ថានភាពពិការ និងហានិភ័យ និងភាពងាយរងគ្រោះផ្សេងៗ។ កុមារដែលត្រូវបានបញ្ជូនមកវិញ ត្រូវទទួលបានការគាំទ្រ និងត្រូវផ្ទេរតាមរយៈបុគ្គលិកសុខុមាលភាពសង្គម ជំនួសឱ្យការ "ប្រគល់" ទៅកាន់មន្ត្រីប្រចាំការព្រំដែន។

**ផ្តល់ឱកាសដល់កុមារចូលរួមក្នុងដំណើរការបង្កើតគោលនយោបាយ** ដើម្បីធានាបាននូវទស្សនៈ និងផលប្រយោជន៍របស់កុមារ ដោយទស្សនៈនេះត្រូវបានស្តាប់ ហើយពិចារណា។

បង្កើត**គោលការណ៍ណែនាំជាក់ស្តែងមួយ ដើម្បីអនុវត្តវាយតម្លៃ និងកំណត់ឧត្តមប្រយោជន៍កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍** (សម្រាប់កុមារក្នុងអំឡុងពេលធ្វើដំណើរ និងត្រឡប់មកវិញ និងកុមារដែលទុកនៅសហគមន៍) សម្រាប់បុគ្គលិក និងអ្នកឯកទេសផ្តល់សេវាផ្សេងៗនៅក្នុងប្រទេសទាំងពីរ ដែលទទួលបន្ទុកដោះស្រាយបញ្ហាកុមារទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ។ ដំណើរការនេះត្រូវធានាជាតុចូលពីកុមារ និងគោរពចំពោះភ្នាក់ងារតំណាងកុមារដែលមានអាយុច្រើនជាង។

បង្កើត**កិច្ចព្រមព្រៀងលើដំណើរការបញ្ជាក់អត្តសញ្ញាណកុមារ** រួមមានការតាមស្វែងរកគ្រួសារ និងដំណើរការផ្សេងៗទៀត ដើម្បីធានាថា កុមារមានសិទ្ធិទទួលបានអត្តសញ្ញាណជាតិ និងសិទ្ធិនានាដែលភ្ជាប់មកជាមួយអត្តសញ្ញាណនេះ។

**ផ្តល់សេវាផ្នែកច្បាប់ដល់កុមារដែលរងភាពងាយរងគ្រោះ**។ កុមារដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ដោយ**មិនស្ម័គ្រចិត្ត ឬមានជម្លោះផ្នែកច្បាប់ ពួកគេមានសិទ្ធិទទួលបានសេវាច្បាប់ និងសិទ្ធិប្តឹងឧទ្ធរណ៍។** ការបំបែកកុមារពីឪពុកម្តាយ ឬសមាជិកគ្រួសារផ្សេងទៀត ត្រូវជៀសវាង លុះត្រាតែការរួមដំណើរជាមួយគ្នានេះ ធ្វើឱ្យកុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។

ផ្តល់សិទ្ធិទទួលបាន**ការបកប្រែភាសា**តាមតម្រូវការសម្រាប់កុមារ ស្ថិតក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍ និងត្រឡប់ទៅប្រទេសកម្ពុជាវិញ។

**ប្រទេសកម្ពុជា**

**ពិនិត្យឡើងវិញគោលនយោបាយដែលមានស្រាប់ទាក់ទងនឹងពលករទេសន្តរប្រវេសន៍ដូចជាគោលនយោបាយទេសន្តរប្រវេសន៍ការងារ** ដើម្បីធានាថា គោលនយោបាយទាំងនេះឆ្លើយតបចំពោះកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍។ បញ្ចូលសំឡេងរបស់កុមារ ក្នុងការបង្កើតគោលនយោបាយ ដើម្បីធានាថា តម្រូវការ

និងសិទ្ធិជាក់លាក់របស់ពួកគេ ត្រូវបានចាត់ទុក ជាអាទិភាព។ ចំណុចនេះអាចកើតឡើងតាមរយៈការពិគ្រោះយោបល់ ឬការស្រាវជ្រាវ។

ធានាថា **ផែនការអភិវឌ្ឍន៍ភូមិឃុំត្រូវបញ្ចូលសកម្មភាពចំណេះដឹងអំពីទេសន្តរប្រវេសន៍** នៅថ្នាក់មូលដ្ឋានដែលអាចនាំទៅដល់ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព។

## ការបន្តសេវាដល់កុមារ និងគ្រួសារ

**ផ្តល់ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងដល់ឪពុកម្តាយ អាណាព្យាបាល និងកុមារ** មកពីក្រុមគ្រួសារជនទេសន្តរប្រវេសន៍អំពីរបៀបគាំទ្រ និងកិច្ចការពារកុមារដែលទុកនៅស្រុកកំណើត និងដើម្បីធានាថាកុមារដែលធ្វើដំណើរជាមួយឪពុកម្តាយរបស់ពួកគេ ត្រូវទទួលបានកិច្ចការពារ។ ត្រូវធានាថា ព័ត៌មានសេវាទាំងឡាយដែល អាចរកបានត្រូវមានសម្រាប់កុមារដែលមានពិការ ដើម្បីដោះស្រាយភាពខុសគ្នានៃយេនឌ័រ និងហានិភ័យ។

**ត្រូវធានាថា កម្មវិធីចិញ្ចឹមបីបាច់កូនៗដោយវិជ្ជមាន** ត្រូវបង្កើតឡើង ផ្តល់ដល់អ្នកមើលថែកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ដើម្បីធានាលើកកម្ពស់ការចិញ្ចឹមបីបាច់ពួកគេដោយវិជ្ជមាន និងការអនុវត្តការថែទាំ ក្នុងគោលបំណងជួយកែលម្អសុខុមាលភាពរបស់កុមារ និងទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ។

**លើកកម្ពស់បណ្តាញមិត្ត និងយន្តការផ្សេងទៀតសម្រាប់គាំទ្រគ្នាទៅវិញទៅមក ដល់កុមារ**ដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ទាំងនៅក្នុងប្រទេសថៃ និងនៅក្នុងប្រទេសកម្ពុជា។

ត្រូវធានាថា **ព័ត៌មានសមស្របតាមអាយុកុមារ** ត្រូវបានផ្សព្វផ្សាយដល់កុមារក្នុងទម្រង់ងាយយល់ ព្រមទាំងសិទ្ធិស្របច្បាប់របស់ពួកគេផងដែរ។

បង្កើន**កិច្ចខិតខំប្រឹងប្រែង ឈងទៅរកកុមារនៅប្រទេសថៃ ដើម្បីដោះស្រាយហានិភ័យ ដូចជាកត្តាយេនឌ័រ ពលកម្មកុមារ និងការជួញដូរកុមារជាដើម។** ឧទាហរណ៍ ការកំណត់គោលដៅលើកិច្ចខិតខំប្រឹងប្រែងនៅក្នុងសហគមន៍ដែលមានពលករទេសន្តរប្រវេសន៍រស់នៅ ឬចំណោមមនុស្សជាច្រើនបានចេញពីស្រុក ឬត្រឡប់មកវិញ។ បញ្ចូលប្រធានបទដូចជាវិធីទទួលបានការអប់រំ ការថែទាំសុខភាព និងការទទួលបានឯកសារផ្លូវច្បាប់។

ប្រើប្រាស់**បច្ចេកវិទ្យាដើម្បីជួយឪពុកម្តាយទេសន្តរប្រវេសន៍ទាក់ទងជាមួយកូនៗ និងក្រុមគ្រួសាររបស់ពួកគេ។** ការបញ្ចុះតម្លៃទូរគមនាគមន៍ សម្រួលដល់ការចូលប្រើអ៊ីនធឺណិត និងកាត់បន្ថយឧបសគ្គបច្ចេកវិទ្យាដែលពាក់ព័ន្ធ អាចជួយឱ្យជនទេសន្តរប្រវេសន៍ភ្ជាប់ទំនាក់ទំនងកាន់តែញឹកញាប់ជាមួយកូនៗរបស់ពួកគេ (ផ្សារភ្ជាប់ជាមួយវិស័យឯកជន)។

ត្រូវធានាថា មាន**កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ** ដែលពលករទេសន្តរប្រវេសន៍ និងកូនរបស់ពួកគេអាចចូលទៅប្រើបានដោយងាយស្រួល។

### *ការគ្រប់គ្រងករណី*

ដោយទទួលស្គាល់ពីសារៈសំខាន់ប្រព័ន្ធការពារកុមារនៅតាមច្រកព្រំដែន ដើម្បីឆ្លើយតបដោះស្រាយបញ្ហាកុមារដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍ទៅប្រទេសថៃ ទើបគេចាំបាច់ត្រូវ**ធ្វើបច្ចុប្បន្នភាពស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ប្រព័ន្ធការពារកុមារ និងប្រព័ន្ធគ្រប់គ្រងករណី ដើម្បីធានាថា ប្រព័ន្ធទាំងនេះ រួមបញ្ចូលតួនាទីកិច្ចការពារកុមារកម្ពុជា។** បច្ចុប្បន្ន ស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ផ្តល់ដំណោះស្រាយតែកុមារដែលបានត្រឡប់មកវិញ ឬកុមារទុកនៅស្រុកកំណើតប៉ុណ្ណោះ។ គេត្រូវកំណត់ឱ្យបានច្បាស់នូវតួនាទី និងទំនួលខុសត្រូវរបស់ផ្នែកទទួលបន្ទុកកិច្ចការពារកុមារកម្ពុជា ដោយផ្សារភ្ជាប់ទៅនឹងគំរូថ្មីនៃការឆ្លើបតបញ្ហាឆ្លងកាត់ច្រកព្រំដែន ហើយថាតើរបៀបគ្រប់គ្រងប្រព័ន្ធទាំងនេះ ជាពិសេស របៀបវាយតម្លៃកុមាររកមើលភាពងាយរងគ្រោះ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍ ប្រព្រឹត្តទៅយ៉ាងដូចម្តេច។

**ពង្រីកប្រភេទក្រុមកុមារដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍ក្នុងប្រព័ន្ធ** *Primero CPIMS+* ៖ គ្មានព័ត៌មានលម្អិតគ្រប់គ្រាន់ពីប្រភេទ (categories) កុមារមួយក្រុមដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍។ បញ្ហានេះអាចត្រូវបានពង្រីក ដើម្បីបញ្ចូលប្រភេទកុមារ ដូចជា ១)កុមារទុកនៅស្រុកកំណើត (ឪពុកម្តាយម្នាក់ ឬ ទាំងពីរធ្វើទេសន្តប្រវេសន៍នាពេលបច្ចុប្បន្ន) ២)កុមារដែលបានត្រឡប់មកពីទេសន្តប្រវេសន៍ដោយស្ម័គ្រចិត្ត ៣)កុមារដែលបានត្រឡប់មកវិញដោយមិនស្ម័គ្រចិត្ត កុមារបំបែកពីគ្រួសារ កុមារគ្មានអ្នកអបដំណើរជាមួយ និង ៤)កុមារជាកូនរបស់ជនចំណាកស្រុកក្នុងប្រទេស។ ចំណុចនេះត្រូវបញ្ជាក់ឱ្យបានច្បាស់ក្នុងស្តង់ដារនីតិវិធីប្រតិបត្តិ (SOPS)។

ការរួមផ្សំព័ត៌មានអំពីអ្នកមើលថែ ជាមួយនឹងស្ថានភាពរស់នៅបច្ចុប្បន្ន គេនឹងទទួលបានព័ត៌មានលម្អិតបន្ថែមអំពីស្ថានភាពរបស់កុមារ។ លើសពីនេះ ការបំបែកទិន្នន័យ (តាមរយៈការរាយការណ៍) ពីប្រព័ន្ធ *Primero* អាចត្រូវបានស្រាវជ្រាវដើម្បីធានាថា ទិន្នន័យដែលប្រមូលបាន ត្រូវបានយកទៅវិភាគ ដោយប្រើទិន្នន័យដែលបានមកពី ដូចជា អ្នកមើលថែកុមារ ស្ថានភាពពិការ និងពីអ្នកផ្សេងៗទៀត។

**កម្លាំងការងារសេវាសង្គម៖** ការមានកម្លាំងការងារសេវាសង្គម ដែលទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ ផ្តល់សារៈសំខាន់យ៉ាងខ្លាំងក្នុងការធានានូវគុណភាពដល់ការគ្រប់គ្រងករណី។ បន្ថែមលើការបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារ និងការគ្រប់គ្រងករណី បុគ្គលិកសង្គមកិច្ច តម្រូវឱ្យមានការបណ្តុះបណ្តាលស្តីពីស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) និងផលប៉ះពាល់ពីទេសន្តប្រវេសន៍មកលើកុមារ ហើយធានាថា ការចូលរួមរបស់កុមារគឺជាការចូលរួមចំណែកក្នុងការសម្រេចចិត្តណាមួយសម្រាប់ពួកគេ។

### ទិន្នន័យ និងការស្រាវជ្រាវ

ទោះបីទិន្នន័យនៅមានកម្រិតក្តី ក៏ក្រសួងផ្សេងៗ មានទិន្នន័យដែលជួយដល់ការយល់ដឹងបានខ្លះៗ។ គេគួរបង្កើតផែនទី និងកំណត់ទិន្នន័យរបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍ ហើយប្រើវាដើម្បី

ស្វែងយល់អំពីទិន្នន័យដែលមានស្រាប់ និងរកមើលចន្លោះប្រហោង។ គេអាចធ្វើវាបានឥឡូវ ដើម្បីផ្តល់ការយល់ដឹងឱ្យកាន់តែច្បាស់អំពីប្រព័ន្ធនេះ។

ផ្តល់ការគាំទ្របន្ថែមដល់ការសិក្សា ដើម្បីយល់កាន់តែច្បាស់អំពីស្ថានភាពរបស់កុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ – កុមារដែលទុកនៅស្រុកកំណើត ទីកន្លែងសំចត និងស្ថិតក្នុងប្រទេសថៃ។ ចំណុចនេះរួមបញ្ចូលទាំងការគាំទ្រការស្រាវជ្រាវ និងប្រព័ន្ធកែលម្អលើកិច្ចការប្រមូលទិន្នន័យនិងការចែករំលែកពត៌មាន។

## ឧបសម្ព័ន្ធទី ១៖ ការធ្វើផែនទីអង្គការអ្នកពាក់ព័ន្ធ និងអង្គការអន្តរជាតិ

### ប្រទេសកម្ពុជា

| អង្គការ | ផ្នែកសំខាន់/ការផ្តោតលើការងារ |
|---|---|
| **អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM)** | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (*IOM*) ធ្វើការដើម្បីធានាការគ្រប់គ្រងទេសន្តរប្រវេសន៍ប្រកបដោយសណ្តាប់ធ្នាប់ និងប្រកបដោយមនុស្សធម៌។ នៅកម្ពុជា អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ផ្តោតលើការប្រឆាំងការជួញដូរ ផ្តល់ជំនួយជនទេសន្តរប្រវេសន៍ គ្រប់គ្រងទេសន្តរប្រវេសន៍ និងសុខភាពទេសន្តរប្រវេសន៍។ |
| **អង្គការជំណាក់ទឹក** | អង្គការក្រៅរដ្ឋាភិបាលផ្តោតលើកិច្ចការពារកុមារ បរិយាប័ន្នពិការភាព និងទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព។ ផ្តល់សេវាការពារដល់កុមារ និងយុវជនដែលងាយរងគ្រោះ រួមទាំងជនពិការនៅក្នុងប្រទេសកម្ពុជា ដើម្បីកាត់បន្ថយហានិភ័យគ្រោះថ្នាក់ និងការរំលោភបំពានគ្រប់ទម្រង់។<br><br>ផ្តល់ជំនួយដល់កុមារងាយរងគ្រោះ និងជនពិការ និងគ្រួសាររបស់ពួកគេនៅក្នុងទីតាំងបីផ្សេងគ្នាគឺ ក្រុងប៉ោយប៉ែត ក្រុងអ្នកលឿង និងក្រុងកែប។ ជួយកុមារនៅតាមចញ្ចើមផ្លូវក្នុងការស្វែងរកការអប់រំ និងការងារ។ អង្គការជំណាក់ទឹក ក៏បានបង្កើតកម្មវិធីមួយដើម្បីជួយដល់កុមារ និងយុវជនពិការ ដោយផ្តល់ឱ្យពួកគេមានទីជម្រក ការថែទាំសុខភាព សេវាពេទ្យ និងការងារ និងការអប់រំ។ |
| **អង្គការចាប់ដៃ** | អង្គការសមាជិកចំនួន ៥០ ដែលធ្វើការជាពិសេសនៅក្នុងប្រទេសកម្ពុជាបានចូលរួមដោយផ្ទាល់ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និង/ឬការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងវិស័យជាក់លាក់មួយ រួមមាន៖ ការទប់ស្កាត់ អន្តរាគមន៍ ការថែទាំក្រោយ ការធ្វើសមាហរណកម្មឡើងវិញ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំ អាជីវកម្មដោយសេរីភាព ឬសហគមន៍ដែលមានហានិភ័យ និង/ឬធ្វើការលើបញ្ហាចម្រុះ ដែលជះឥទ្ធិពល ឬរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ច និងការរំលោភលើការជួញដូរមនុស្ស (ឧទាហរណ៍ យេនឌ័រ និងអាកាសធាតុ)។ |
| **អង្គការជំនួយផ្លូវច្បាប់ដល់កុមារី និងស្ត្រី** | ផ្តល់ការគាំទ្រផ្នែកច្បាប់ដល់កុមារ និងគ្រួសារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ (ក្នុងចំណោមបញ្ហាផ្សេងទៀត)។ ធ្វើការងារទាក់ទងនឹងការឆ្លងព្រំដែន។ |
| **មូលនិធិគ្រួសារថ្មី** | មូលនិធិជំនួយកម្ពុជាដំបូងសម្រាប់កុមារក្រីក្រដែលធ្វើការជាមួយមជ្ឈមណ្ឌលនិរទេសប៉ោយប៉ែត |
| **មណ្ឌលសុវត្ថិភាពកុមារ** | ផ្តល់ពត៌មាននៅមជ្ឈមណ្ឌលនិរទេសប៉ោយប៉ែត |
| **អង្គការសកម្មភាពដើម្បីកុមារ កម្ពុជា (*APLE*)** | អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដែលធ្វើការ ដើម្បីការពារកុមារងាយរងគ្រោះ ជាពិសេសជនរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ច។ អង្គការ *APLE* ប្រតិបត្តិការផ្តល់ជម្រក ផ្តល់សេវាស្តារនីតិសម្បទា ជួយសង្គ្រោះជនរងគ្រោះ និងបើកយុទ្ធនាការយល់ដឹង។ |
| **អង្គការ អន្តរជាតិ** | អង្គការអន្តរជាតិដែលជួយជនរងគ្រោះពីការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច និងជួយក |

| | |
|---|---|
| ហាហ្គា (Hagar) | សាងជីវិតរបស់ពួកគេឡើងវិញ។ នៅក្នុងប្រទេសកម្ពុជា អង្គការហាហ្គារប្រតិបត្តិការផ្តល់ជម្រកស្នាក់នៅផ្តល់ការប្រឹក្សា ជំនួយផ្នែកច្បាប់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនួយក្នុងការរកការងារធ្វើ។ |
| អង្គការទស្សនៈពិភពលោក | អង្គការមនុស្សធម៌អន្តរជាតិ ដែលធ្វើការជាមួយកុមារ គ្រួសារ និងសហគមន៍ ដើម្បីជម្នះភាពក្រីក្រ និងអយុត្តិធម៌។ នៅក្នុងប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកធ្វើការដើម្បីទប់ស្កាត់ការជួញដូរ និងការកេងប្រវ័ញ្ចលើកុមារ តាមរយៈយុទ្ធនាការការយល់ដឹង ការចល័តសហគមន៍ និងជម្រើសសេដ្ឋកិច្ច។ |
| អង្គការ ឃែរ អន្តរជាតិ (CARE International) | អង្គការមនុស្សធម៌អន្តរជាតិ ដែលផ្តោតលើការប្រយុទ្ធប្រឆាំងភាពក្រីក្រជាសកល។ នៅក្នុងប្រទេសកម្ពុជា អង្គការ ឃែរ ធ្វើការដើម្បីទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការចល័តសហគមន៍ ការពង្រឹងសេដ្ឋកិច្ចដល់ក្រុមដែលរងហានិភ័យ និងជួយដល់ជនរងគ្រោះ។ |
| បេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) | អង្គការអន្តរជាតិដែលធ្វើការដើម្បីការពារប្រជាពលរដ្ឋពីទាសភាព ការកេងប្រវ័ញ្ចផ្លូវភេទ និងទម្រង់ផ្សេងទៀតនៃការជិះជាន់ដោយហិង្សា។ នៅក្នុងប្រទេសកម្ពុជា អង្គកការ IJM ធ្វើការជាមួយអាជ្ញាធរដើម្បីស៊ើបអង្កេតករណីជួញដូរ និងជួយសង្គ្រោះជនរងគ្រោះ។ |
| អង្គការ ActionAid | ធ្វើការដើម្បីផ្តល់អំណាចដល់សហគមន៍ទន់ខ្សោយ ដើម្បីទាមទារសិទ្ធិរបស់ពួកគេ និងប្រយុទ្ធប្រឆាំងភាពក្រីក្រ និងអយុត្តិធម៌។ នៅក្នុងប្រទេសកម្ពុជា អង្គការ *ActionAid* គាំទ្រដល់ពលករទេសន្តរប្រវេសន៍ តាមរយៈកម្មវិធីដែលផ្តល់ការបណ្តុះបណ្តាលជំនាញ ជំនួយផ្នែកច្បាប់ និងសេវាសុខភាព។ |
| សមាគមសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា។ (ADHOC) | អាដហុក ជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ដែលធ្វើការលើកកម្ពស់ និងការពារសិទ្ធិមនុស្សក្នុងប្រទេស។ អាដហុក ផ្តល់ជំនួយផ្នែកច្បាប់ និងការតស៊ូមតិសម្រាប់ពលករទេសន្តរប្រវេសន៍ ជាពិសេសអ្នកដែលប្រឈមការកេងប្រវ័ញ្ច និងការរំលោភបំពាន។ នេះរួមបញ្ចូលទាំងការផ្តល់ជំនួយផ្នែកច្បាប់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាសុខភាព។ សមាគមអាដហុកតស៊ូមតិសម្រាប់ការកែលម្អគោលនយោបាយ និងច្បាប់ទេសន្តរប្រវេសន៍ ដើម្បីការពារទេសន្តរប្រវេសន៍ឱ្យកាន់តែប្រសើរ។ |
| មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) | គឺជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ដែលផ្តល់ជំនួយផ្នែកច្បាប់ និងការអប់រំដល់ក្រុមងាយរងគ្រោះ រួមទាំងពលករទេសន្តរប្រវេសន៍ផងដែរ។ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ *CLEC* មានគោលបំណងផ្តល់អំណាចដល់ជនទេសន្តរប្រវេសន៍ តាមរយៈចំណេះដឹងអំពីសិទ្ធិរបស់ពួកគេក្រោមច្បាប់កម្ពុជា។ |
| អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) | ផ្តោតលើការជួយដល់ស្ត្រីទេសន្តរប្រវេសន៍ ជាពិសេសអ្នកដែលប្រឈមការកេងប្រវ័ញ្ច និងការរំលោភបំពាន។ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ប្រតិបត្តិការផ្តល់កន្លែងស្នាក់នៅ ផ្តល់ជំនួយផ្នែកច្បាប់ និងធ្វើយុទ្ធនាការអប់រំស្តីពីការធ្វើទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាពសម្រាប់ស្ត្រី។<br>ផ្តោតលើកុមារដែលទុកនៅស្រុកកំណើត។ |
| មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ | រៀបចំ និងគាំទ្រដល់កម្មករកម្ពុជា តាមរយៈជំនួយផ្នែកច្បាប់ និងមធ្យោបាយសមស្របផ្សេងទៀត ដើម្បីទាមទារឱ្យមានអភិបាលកិច្ចប្រកបដោយតម្លាភាព និងគណនេយ្យភាពសម្រាប់ |

| | |
|---|---|
| និងសិទ្ធិមនុស្ស (CENTRAL) | ការងារ និងសិទ្ធិមនុស្ស ដែលជាអ្នកតស៊ូមតិសម្រាប់ការកែលម្អលក្ខខណ្ឌការងារ និងសិទ្ធិសម្រាប់ពលករទេសន្តរប្រវេសន៍។ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) ធ្វើការស្រាវជ្រាវ បណ្តុះបណ្តាលកម្មករស្តីពីសិទ្ធិរបស់ពួកគេ និងបញ្ចុះបញ្ចូលរដ្ឋាភិបាលឱ្យផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីពលករទេសន្តរប្រវេសន៍។ |
| អង្គការការីតាស កម្ពុជា | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដោយរដ្ឋាភិបាលកម្ពុជា ហើយការិយាល័យប្រចាំប្រទេសត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញ។ ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ការប្រឆាំងការជួញដូរមនុស្ស និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) គឺជាការផ្តោតសំខាន់ និងអនុវត្តជាមួយដៃគូក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ ព្រៃវែង ពោធិ៍សាត់ រាជធានីភ្នំពេញ ហើយឆ្លើយតបបន្ទាន់នៅតាមតំបន់គ្រោះថ្នាក់ ។ |
| អង្គការ Terre des Hommes | តស៊ូមតិជាមួយអ្នកបង្កើតគោលនយោបាយ ម្ចាស់ជំនួយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីផ្តល់ឱ្យកុមារនូវបរិយាកាសសុវត្ថិភាព កិច្ចការពារ និងផ្តល់លទ្ធភាពឱ្យកុមារ។ ដើរតួជាកាតាលីករសម្រាប់ការផ្លាស់ប្តូរជាប្រព័ន្ធ ដែលអនុញ្ញាតឱ្យប្រទេសនានាបម្រើដល់កុមារ និងយុវជនរបស់ពួកគេកាន់តែប្រសើរឡើង។ |
| អង្គការអាហ្សេីប កម្ពុជា | ធ្វើការធានាសិទ្ធិស្ត្រី និងក្មេងស្រីរងគ្រោះដោយការជួញដូរមនុស្ស និងទាសភាពផ្លូវភេទ។ អង្គការនេះត្រូវបានបង្កើតឡើងនៅកម្រិតមូលដ្ឋានក្នុងឆ្នាំ ១៩៩៦ ដោយសារតែស្ថានភាពធ្ងន់ធ្ងរនៃជនរងគ្រោះរាប់ពាន់នាក់ត្រូវបានបង្ខំឱ្យធ្វើអាជីវកម្មនៅតាមច្រកឆ្លងកាត់ព្រំដែនកម្ពុជា។ |
| អង្គការ ខារ៉ាម កម្ពុជា | ធ្វើការដើម្បីជួយដល់ពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេក្នុងការកសាងគុណភាពជីវិត សុខភាព និងសុខុមាលភាពរបស់ពួកគេ និងដើម្បីធានាថាសិទ្ធិមនុស្ស និងសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍ទាំងនោះ គ្រួសាររបស់ពួកគេ និងសហគមន៍ ត្រូវបានគោរពដោយមនុស្សគ្រប់គ្នា។ អង្គការ *CARAM Cambodia* បានធ្វើការលើបញ្ហាទេសន្តរប្រវេសន៍ និងបញ្ហាមេរោគអេដស៍តាំងពីឆ្នាំ ១៩៩៨ ហើយនាំមកនូវបទពិសោធន៍ជាច្រើនក្នុងការងារទេសន្តរប្រវេសន៍ និងសុខភាពដល់សហគមន៍អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ |
| មូលនិធិ Ursula Zindel-Hilti | ចាប់តាំងពីឆ្នាំ ២០១៨ មក មូលនិធិ *Ursula Zindel-Hilti* បានគាំទ្រដល់ការងារគម្រោងរបស់ *Caritas Switzerland* ក្នុងប្រទេសកម្ពុជា រួមទាំងជួយមជ្ឈមណ្ឌលបណ្តុះបណ្តាលសម្រាប់ស្ត្រីវ័យក្មេងដែលរងផលប៉ះពាល់ដោយការជួញដូរមនុស្ស និងអំពើហិង្សា។ ឥឡូវនេះគម្រោងមួយកំពុងត្រូវបានគាំទ្រ ដែលរួមបញ្ចូលគ្នានូវការទប់ស្កាត់ កិច្ចការពារ និងសមាហរណកម្ម និងរួមបញ្ចូលផងដែរនូវកម្មវិធីការពារកុមារនៅក្រុងប៉ោយប៉ែត។ |
| អង្គការមិត្តសម្លាញ់ ដៃគូ 3 PC | ដៃគូអនុវត្តចំនួន១១៖ អង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តសកម្មភាពកម្មវិធីសំខាន់ៗ។<br>ដៃគូបច្ចេកទេសចំនួន៦៖ អង្គការក្រៅរដ្ឋាភិបាលដែលមានចំណេះដឹងឯកទេស និងអាចផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដូចជា ជំនួយផ្នែកច្បាប់ ការកសាងសមត្ថភាព ជំនួនាញបច្ចេកទេស ការអភិវឌ្ឍន៍សម្ភារៈបណ្តុះបណ្តាល ការស្រាវជ្រាវ។ល។ |

| | |
|---|---|
| | "បណ្ដាញនៃបណ្ដាញ" ដៃគូ៤០៖ ការពង្រីកបណ្ដាញទៅអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ដែលទាក់ទងនឹងសមាជិកអង្គការក្រៅរដ្ឋាភិបាល និងរួមបញ្ចូលជាអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធ។ |
| **អង្គការតេនៈ** | ផ្ដល់ជំនួយដល់ជនរងគ្រោះដោយការជួញដូរនៅកម្ពុជា |
| **អង្គការកុមាររីករាយ** | អង្គការកុមាររីករាយ គឺជាអង្គការមិនរកប្រាក់ចំណេញដែលផ្ដល់សេវាកិច្ចការពារ ស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មដល់កុមារដែលងាយរងគ្រោះ ទៅក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេ។ |

ប្រទេសថៃ

| អង្គការ | ផ្នែកសំខាន់/ការផ្ដោតលើការងារ |
|---|---|
| **អង្គការ ភឿន ភឿន មិត្តសម្លាញ់អន្តរជាតិ** | អង្គការ ភឿន ភឿន អនុវត្តកម្មវិធីជំនួយសង្គមចល័ត និងសេវាសមាហរណកម្មសង្គមទូលំទូលាយ។ កម្មវិធីនេះដំណើរការនៅទីក្រុងបាងកក និងនៅសងខាងព្រំដែនកម្ពុជា-ថៃ (អារញ្ញប្រាថេត និងប៉ោយប៉ែត)។ |
| **អង្គការ Save the Children ប្រទេសថៃ** | អង្គការ *Save the Children* គឺជាអង្គការសប្បុរសធម៌ឈានមុខគេសម្រាប់កុមារនៅក្នុងប្រទេសថៃចាប់តាំងពីឆ្នាំ ១៩៨៤។ យើងធ្វើការដើម្បីឈានចាប់កុមារដែលងាយរងគ្រោះបំផុត រួមមានកុមារទេសន្តប្រវេសន៍ ជនភៀសខ្លួន និងជនជាតិភាគតិច ក៏ដូចជាកុមារដែលរងផលប៉ះពាល់ដោយជម្លោះ អ្នករស់រានមានជីវិតពីការជួញដូរ កុមារពិការ និងកុមារក្រីក្រតាមផ្លូវក្នុងទីក្រុង – តាមរយៈកម្មវិធីផ្នែកសុខភាព ការអប់រំ កិច្ចការពារ និងការឆ្លើយតបបន្ទាន់។ |
| **អង្គការមូលនិធិទស្សនៈពិភពលោកប្រទេសថៃ** | មូលនិធិទស្សនៈពិភពលោកក្នុងប្រទេសថៃមានកម្មវិធីស្ដីពីការចល័តធនធានមនុស្ស និងការធ្វើទេសន្តប្រវេសន៍ ត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការរបស់ជនទេសន្តប្រវេសន៍ដែលងាយរងគ្រោះបំផុតនៅក្នុងប្រទេសថៃ រួមទាំងស្ត្រី និងកុមារផងដែរ ដែលរួមមានសសរស្ដម្ភចំនួនបី៖ សុខភាពទេសន្តប្រវេសន៍ ការប្រឆាំងការជួញដូរមនុស្ស ការងារសមរម្យ និងស្ត្រី និងកុមារដែលរងផលប៉ះពាល់ដោយទេសន្តប្រវេសន៍ ។ |
| **អង្គការមិត្តថៃ** | អង្គការមិត្តថៃ គឺជាកិច្ចសហការអន្តរភ្នាក់ងារដែលធ្វើការលើការលើកកម្ពស់កិច្ចការពារ និងការអភិវឌ្ឍជំនាញរបស់ពលករទេសន្តប្រវេសន៍ពីប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសភូមាដែលធ្វើទេសន្តប្រវេសន៍ទៅធ្វើការក្នុងប្រទេសថៃ តាមរយៈការផ្សព្វផ្សាយព័ត៌មាន ចំណេះដឹង និងដំបូន្មានផ្នែកច្បាប់ ព្រមទាំងសេវាពាក់ព័ន្ធផ្សេងៗទៀត ដែលពលករទេសន្តប្រវេសន៍អាចទទួលបាន។ ឧទាហរណ៍ នេះរួមបញ្ចូលទាំងព័ត៌មានអំពីការរៀបចំមុនពេលចេញដំណើរ ការធ្វើការ និងការរស់នៅក្នុងប្រទេសថៃ ក៏ដូចជាការទទួលបានសេវាសុខភាព ការអប់រំ ការអភិវឌ្ឍន៍ជំនាញសម្រាប់ពលករទេសន្តប្រវេសន៍ និងសិទ្ធិ និងកិច្ចការពារ។ |
| **អង្គការទេសន្តប្រវេសន៍អន្តរជាតិ** | អង្គការ IOM ផ្ដល់សេវាកម្មទូលំទូលាយដល់ជនទេសន្តប្រវេសន៍ដែលងាយរងគ្រោះ ដោយពិចារណាលើកត្តាដែលរួមចំណែកដល់ភាពងាយរងគ្រោះរបស់ពួកគេ ដើម្បីបង្កើតការឆ្លើយ |

| | |
|---|---|
| (IOM) ប្រទេសថៃ | តបតាមតម្រូវការ ដែលបង្កើនសក្តានុពលនៃការស្តារឡើងវិញប្រកបដោយនិរន្តរភាព។ សេវាលើកកម្ពស់សុខុមាលភាពបុគ្គល និងសហគមន៍ ព្រមគ្នានឹងការលើកកម្ពស់និរន្តរភាពតាមរយៈការកសាងសមត្ថភាពរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល។ លើសពីនេះ អង្គការ IOM គាំទ្រដល់ការបង្កើត និងអនុវត្តរចនាសម្ព័ន្ធបញ្ជូន ជម្រើសជំនួសការឃុំខ្លួន និងភាពជាដៃគូក្នុងតំបន់/ទ្វេភាគី តាមរយៈការណែនាំគោលនយោបាយ ការកសាងសមត្ថភាព/ការបណ្តុះបណ្តាល និងការស្រាវជ្រាវ/ការតស៊ូមតិ។<br><br>ផ្តល់ជំនួយដល់ជនទេសន្តរប្រវេសន៍ដែលជាប់គាំង និងងាយរងគ្រោះ រួមទាំងជនរងគ្រោះនៃការជួញដូរ និងកុមារដែលគ្មានអ្នករួមដំណើរជាមួយ និងបំបែកពីក្រុមគ្រួសារ។ |
| **មូលនិធិមជ្ឈមណ្ឌលគាំពារសិទ្ធិកុមារ** (CPCR) | មូលនិធិ CPCR គឺជាអង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសថៃដែលមានគោលបំណងការពារកុមាររងគ្រោះដោយអំពើហិង្សា និងការថៃទាំដោយខុសច្បាប់ តាមរយៈសេវាភាពជន់ សម្រាប់កុមារ និងគ្រួសារ។<br><br>មូលនិធិ CPCR រួមបញ្ចូលច្បាប់ការពារកុមារ និងវិធីសាស្ត្រពហុវិន័យ។ ប្រតិបត្តិការរួមមានការស៊ើបអង្កេត ការស្វែងរកការពិត កិច្ចការពារ ការស្តារនីតិសម្បទា ការអភិវឌ្ឍន៍ ជំនួយផ្នែកច្បាប់ និងការធ្វើសមាហរណកម្មឡើងវិញ។ មូលនិធិ CPCR សម្របសម្រួលជាមួយក្រុមពហុជំនាញ តាមរយៈការធ្វើសន្និសីទករណី ដើម្បីគាំទ្រផែនការសង្គ្រោះសមរម្យដល់ជនរងគ្រោះ។ |

## ឧបសម្ព័ន្ធ២៖ ស្ថានភាពកុមារដែលទុកនៅស្រុកកំណើត

### ហេតុផលទេសន្តរប្រវេសន៍របស់ឪពុកម្តាយ និងការទុកកូនៗនៅស្រុកកំណើត

ពេលឪពុកម្តាយនៅក្នុងប្រទេសកម្ពុជាសម្រេចចិត្តចាកចេញពីប្រទេសស្វែងរកការងារ ពួកគេទុកកូនៗនៅផ្ទះ អាចនាំទៅដល់ការពិចារណាកត្តាសំខាន់ៗ។ ការសិក្សាក្នុងតំបន់អាស៊ានមួយចំនួន[87] ស្តីពីទេសន្តរប្រវេសន៍ឆ្លង

[87] https://thailand.iom.int/news/iom-report-urges-cohesion-asean-labour-mobility; https://www.ilo.org/resource/other/research-and-publications-labour-migration; https://www.ilo.org/resource/other/research-and-publications-labour-migration; https://www.louvaincooperation.org/sites/default/files/2020-08/Migration%20impacts%20on%20cambodian%20children-MHICCAF%20REPORT.pdf.

ព្រំដែន បង្ហាញពីភាពស្មុគស្មាញនៃទេសន្តរប្រវេសន៍ នៅតាមច្រកទ្វារ នៅក្នុងបណ្តាប្រទេសអាស៊ាន ហើយមានផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គម។ ការវិភាគតាមតំបន់ ត្រូវបានសិក្សាស្វែងយល់ពីគំរូទេសន្តរប្រវេសន៍ និងកត្តាជះឥទ្ធិពលលើការសម្រេចចិត្តរបស់ជនទេសន្តរប្រវេសន៍។ ឪពុកម្តាយទេសន្តរប្រវេសន៍ ត្រូវបានសួរសំណួរចម្បងមួយ ថាតើពួកគេសម្រេចចិត្តទុកកូនៗរបស់ពួកគេនៅក្នុងប្រទេសកំណើតដែរឬយ៉ាងណា។

កត្តាសេដ្ឋកិច្ច សង្គម នយោបាយ និងវប្បធម៌មានទំនាក់ទំនងគ្នាយ៉ាងខ្លាំង ពាក់ព័ន្ធថាតើឪពុកម្តាយទេសន្តរប្រវេសន៍ សម្រេចចិត្តទុកកូនៗរបស់ពួកគេនៅប្រទេសកំណើត បណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។ ការសិក្សាមួយនៅខេត្តសៀមរាប ឆ្នាំ២០១៨[88] រកឃើញថា អាយុគឺជាកត្តាសំខាន់ក្នុងការសម្រេចចិត្តរបស់ឪពុកម្តាយទាក់ទងនឹងការយកកុមារទៅជាមួយក្នុងអំឡុងទេសន្តរប្រវេសន៍។ គេមានទំនោទុកកុមារតូចៗនៅស្រុកកំណើត ចំណែកកូនអាយុលើសពី ១៥ ឆ្នាំទំនង ត្រូវទៅជាមួយឪពុកម្តាយ ឬសមាជិកគ្រួសារផ្សេងទៀត។ ភាពខុសគ្នានេះ ត្រូវបានសន្មតថាជាអាយុអប្បបរមាការងាររបស់ប្រទេសកម្ពុជា ដោយកំណត់អាយុ ១៥ ឆ្នាំ ពីព្រោះកុមារភាគច្រើនដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ទំនងចាកចេញទៅជាមួយឪពុកម្តាយ ឬសាច់ញាតិ ដើម្បីចូលរួមការងារពលកម្មទៅកាន់ប្រទេសគោលដៅរបស់ពួកគេ។

ការពិចារណាជាច្រើន ជះឥទ្ធិពលដល់ជម្រើសទេសន្តរប្រវេសន៍របស់ឪពុកម្តាយ និងការទុកកូនៗនៅស្រុកកំណើត។ ជាញឹកញាប់ កត្តាសេដ្ឋកិច្ច ជាកម្លាំងរុញឱ្យមានទេសន្តរប្រវេសន៍។ ដំបូង ឪពុកម្តាយសម្រេចចិត្តចេញពីប្រទេស ដើម្បីស្វែងរកថវិកាជួយខ្លួនឯងសិន ក្រោយមកទើបពួកគេធ្វើឱ្យកូនៗរបស់ពួកគេនៅស្រុកកំណើត។ ប៉ុន្តែ ពលករទេសន្តរប្រវេសន៍ជាច្រើនយល់ឃើញថា ពួកគេមិនអាចសន្សំថវិកាបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កូនៗរបស់ពួកគេទេ។ បណ្តាញសង្គមក៏ដើរតួនាទីមួយផងដែរ ដោយសារជនទេសន្តរប្រវេសន៍មាន
ទំនោរផ្លាស់ទីលំនៅទៅកាន់តំបន់ដែលមានសហគមន៍ បង្កើតឡើងដោយជនទេសន្តរប្រវេសន៍ដែលមកពីប្រទេសកំណើតជាមួយគ្នា។ ប៉ុន្តែ ចំណុចនេះកាន់តែធ្វើឪពុកម្តាយឃ្លាតឆ្ងាយពីកូនៗរបស់ពួកគេក្នុងរយៈពេលយូរអង្វែង។

គោលនយោបាយរបស់រដ្ឋាភិបាលក៏កំណត់លើការសម្រេចចិត្តទេសន្តរប្រវេសន៍ផងដែរ។ ប្រទេសមួយចំនួនបានដាក់កំហិតចំពោះពលករទេសន្តរប្រវេសន៍ ដែលនាំយកអ្នកក្នុងបន្ទុកទៅជាមួយ ខណៈប្រទេសខ្លះបង្កើតកម្មវិធីជួបជុំគ្រួសារឡើងវិញ ដើម្បីជួយសម្រួលដល់ជនទេសន្តរប្រវេសន៍ជួបជាមួយកូនៗពួកគេ។ លទ្ធភាព និងភាពរកបានសេវាការថែទាំកុមារនៅក្នុងប្រទេសគោលដៅ គួរយកមកពិចារណាបន្ថែម។ បទដ្ឋានវប្បធម៌ជុំវិញការចិញ្ចឹមបីបាច់កូនៗ និងការគ្រប់គ្រងគ្រួសារ មានភាពខុសគ្នារវាងប្រទេសនានា ដែលជះឥទ្ធិពលដល់ឪពុកម្តាយទេសន្តរប្រវេសន៍ទាំងនោះ ថាតើជម្រើសទាំងនោះ អាចធ្វើទៅបាន ឬចង់បានដែរ ឬយ៉ាងណា។

[88] Quantitative and Qualitative Study on the Impact of Cross-Border Parental Migration on Families Left Behind in Siem Reap Province, Cambodia, Jesuit Refugee Service Cambodia 2018. https://jrscambodia.org/publication/Left_Behind_Children_Report.pdf.

## កត្តាសេដ្ឋកិច្ច

ករណីសិក្សានៅកម្ពុជា (២០២៣) ជាផ្នែកក្នុងរបាយការណ៍របស់អង្គការ *យូនីសេហ្វ* ស្ដីពីស្ថានភាពបរិបទទេសន្តរប្រវេសន៍តាមរដ្ឋសមាជិកអាស៊ាន[89] មានចំណងជើង *កត្តាសេដ្ឋកិច្ចជំរុញឪពុកម្ដាយ ទេសន្តរប្រវេសន៍* បានរកឃើញថា សេដ្ឋកិច្ចគឺជាកត្តាជំរុញចម្បងនាំឱ្យមានឪពុកម្ដាយធ្វើទេសន្តរប្រវេសន៍។ ជាពិសេស ការសិក្សាបានសន្និដ្ឋានថា កត្តាចម្បងដែលឪពុកម្ដាយបានចាកចេញពីស្រុក គឺដើម្បីរកប្រាក់ចំណូល និងផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ មុនពេលចាកចេញ គ្រួសារភាគច្រើនបានរាយការណ៍ថា ពួកគេប្រឈមនឹងស្ថានភាពហិរញ្ញវត្ថុដ៏លំបាក បង្ខំឱ្យពួកគេធ្វើចំណាកស្រុកក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហា ដោយអនុញ្ញាតឱ្យឪពុកម្ដាយទទួលបានការងារធ្វើ និងផ្ញើប្រាក់ចំណូលត្រឡប់មកផ្ទះវិញ។

កត្តាសំខាន់មួយទៀតទាក់ទងនឹងហិរញ្ញវត្ថុគ្រួសារគឺការសងបំណុល។ គ្រួសារខ្លះបានលក់ដី ឬទ្រព្យសម្បត្តិព្យាយាមសងបំណុល ប៉ុន្តែនៅមិនគ្រប់គ្រាន់ ឪពុកម្ដាយបង្ខំចិត្តធ្វើចំណាកស្រុកជាមធ្យោបាយចុងក្រោយ។ ជួនកាលឪពុកម្ដាយទាំងពីរបានចេញពីស្រុកទៅក្រៅប្រទេស ឬក្នុងប្រទេស ដើម្បីរកប្រាក់សងបំណុល។ មានពេលខ្លះ ឪពុកត្រូវទៅធ្វើការនៅប្រទេសថៃ ខណៈម្ដាយបានចេញពីភូមិ រកការងារធ្វើក្នុងប្រទេស ដើម្បីបាននៅជិតកូនៗ។

បំណុលគ្រួសារមានផ្សេងៗគ្នា។ ពួកគេជាច្រើននាក់បានខ្ចីបុល ដើម្បីចាប់ផ្ដើម ឬផ្គត់ផ្គង់អាជីវកម្ម ឬទិញដីទុក។ ខ្លះជំពាក់បំណុលដោយខ្ចីគេយកទៅបង់ថ្លៃច្រូតកាត់ ឬថ្លៃប្រវាស់ដី ក្រោយមក លក់ស្រូវមិនបានដោយសារបញ្ហាមានទឹកជំនន់ ឬគ្រោះរាំងស្ងួតដែលប៉ះពាល់ដល់កសិផល។ របាយការណ៍មួយចំនួនបានបង្ហាញថា និយោជកបានបង់ថ្លៃទេសន្តរប្រវេសន៍ជួសឪពុកម្ដាយ ហើយពួកគេត្រូវទៅធ្វើការងារដើម្បីសងវិញតាមក្រោយ ឬយកប្រាក់កម្ចីទៅបង់ឱ្យមេខ្យល់ជួយពួកគេរត់ការធ្វើដំណើរចេញពីស្រុក។ មានស្ថានភាពខ្លះគ្រួសារជាប់បំណុលដោយសារមានសមាជិកឈឺ ដូចជាឪពុកម្ដាយមានជំងឺមិនអាចរកប្រាក់ចំណូល ឬត្រូវធ្វើកម្ចីយកប្រាក់ទៅព្យាបាលជំងឺ។

## ទេសន្តរប្រវេសន៍មិនប្រក្រតី និងក្ដីបារម្ភពីសុត្ថិភាព

ការសិក្សានៅក្នុងប្រទេសកម្ពុជា និងបណ្ដាប្រទេសអាស៊ាន បានលើកឡើងកត្តាជាច្រើនដែលជះឥទ្ធិពលលើភាពស្មុគស្មាញនៃទេសន្តរប្រវេសន៍តាមព្រំដែន ក៏ដូចជាការពិចារណាបន្ថែមលើបញ្ហាសន្តិសុខ ដោយរួមចំណែកដល់ការសម្រេចចិត្តរបស់ឪពុកម្ដាយក្នុងការចេញទៅធ្វើការនៅក្រៅប្រទេស ដោយមិនបានយកកូនទៅជាមួយ។ នៅពេលខ្លះ កិច្ចព្រមព្រៀងការងារទ្វេភាគីរវាងប្រទេសនឹងប្រទេស ក៏ដូចជាគោលនយោបាយការងារបរទេស ហាមប្រាមពលករទេសន្តរប្រវេសន៍មិនឱ្យយកអ្នកក្នុងបន្ទុកទៅជាមួយ។ លើសពីនេះ អ្នកគ្មានឯកសារត្រូវចេញទៅតាមព្រំដែន មិនយកកុមារទៅជាមួយទេ ដោយសារមានគ្រោះថ្នាក់នៅតាមច្រកមិនប្រក្រតីចំណែកមេខ្យល់វិញ ក៏មិនព្រមដឹកជញ្ជូនអនីតិជនទៅកាន់ប្រទេសថៃដែរ។ ក្ដីបារម្ភអំពីសុវត្ថិភាពដល់អនីតិជននៅតាមច្រកព្រំដែនមិនស្របច្បាប់ ដ៏មានគ្រោះថ្នាក់នេះ ហាក់ដូចជាឧបសគ្គគួរឱ្យកត់សម្គាល់។

[89] Cambodia Case Study Produced as Part of the UNICEF Report on the Situation in the Context of Migration in ASEAN Member States, UNICEF 2023. https://www.unicef.org/eap/media/13426/file/ASEAN%20CABM%20Cambodia.pdf

## ការសិក្សាអប់រំរបស់កុមារ

ការអប់រំ ជាកត្តាសំខាន់ក្នុងការសម្រេចចិត្តរបស់ឪពុកម្តាយជុំវិញទេសន្តរប្រវេសន៍ និងការរៀបចំឡើងវិញក្នុងការចិញ្ចឹមបីបាច់កូនៗ នៅក្នុងប្រទេសកម្ពុជា។ ការរក្សាបាននូវនិរន្តរភាព និងការទទួលបានការអប់រំដោយស្របនឹងស្ថានភាពអភិវឌ្ឍន៍ ជាពិសេសភាសាកំណើតខ្មែរ គឺជាកត្តាសំខាន់សម្រាប់ឪពុកម្តាយជាច្រើន ទុកកូនរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា នៅពេលពួកគេចេញទៅក្រៅប្រទេស។ គេជឿថា ប្រព័ន្ធអប់រំនៅកម្ពុជា មានភាពប្រសើរជាង ក្នុងការបំពេញតម្រូវការអប់រំដល់កូនៗរបស់ពួកគេ លើមុខវិជ្ជាសំខាន់នេះ។ មានករណីលើកលែងដែរ ដោយកុមារតូចៗ ជាចម្បង ចាំបាច់ត្រូវការការថែទាំពីឪពុកម្តាយដោយផ្ទាល់ ក៏ដូចជាកុមារធំ អាចទទួលបានអត្ថប្រយោជន៍ពីឱកាសទេសន្តរប្រវេសន៍។ ទោះយ៉ាងណាក្តី អាទិភាពនៃការផ្តល់បរិយាកាសអប់រំដែលមានស្ថេរភាព និងប្រកបដោយការគាំទ្រ ដោយផ្តោតលើការអភិវឌ្ឍជំនាញភាសាខ្មែរ គឺជាឥទ្ធិពលដ៏សំខាន់ ថាតើឪពុកម្តាយជ្រើសរើសទុកកូនរបស់ពួកគេនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ឬយ៉ាងណា។ សរុបមក ការអប់រំគឺជាកត្តាជំរុញមួយក្នុងការកំណត់ស្ថានភាពរស់នៅរបស់កុមារ នៅពេលដែលឪពុកម្តាយរបស់ពួកគេចាកចេញទៅរកការងារនៅក្រៅប្រទេស។

## ការរៀបចំកិច្ចការថែទាំកុមារ

ករណីសិក្សារបស់អង្គការយូនីសេហ្វឆ្នាំ ២០២៣ បានរកឃើញថា ការរៀបចំ និងជម្រើសនៃការថែទាំកុមារ គឺជាទិដ្ឋភាពសំខាន់ពីរដែលមានឥទ្ធិពល ថាតើកុមារត្រូវបានទុកឱ្យនៅប្រទេសកម្ពុជា ឬយ៉ាងណា។ ការធានាថាកុមារទទួលបានការថែទាំ និងការគ្រប់គ្រងបានត្រឹមត្រូវ នៅពេលឪពុកម្តាយមិននៅ ទៅធ្វើការនៅប្រទេសថៃ គឺជាអាទិភាពចម្បងមួយ។ ដោយសារកង្វះជម្រើសថែទាំកុមារដែលមានតម្លៃសមរម្យ និងគួរឱ្យទុកចិត្តបាន នៅក្នុងប្រទេសថៃ ការដែលមានសមាជិកគ្រួសារ ដូចជា ជីដូន ទុកជួយមើលថែទាំចៅៗនៅក្នុងប្រទេសកម្ពុជា ជាជម្រើសដែលគេចង់បានខ្លាំង។ នៅពេលមានអ្នកជួយមើលថែទាំងកូនៗក្នុងគ្រួសារ ឪពុកម្តាយមានភាពស្កប់ចិត្ត ដោយដឹងថាកូនៗរបស់ពួកគេ មានអ្នកមើលការខុសត្រូវក្នុងម៉ោងធ្វើការ ព្រោះការនាំកូនៗទៅប្រទេសថៃអាចខ្វះការគ្រប់គ្រង និងការយកចិត្តទុកដាក់ ខណៈដែលឪពុកម្តាយជាប់រវល់ការងារ។ ការសិក្សាស្រាវជ្រាវដទៃទៀត[90] ក៏បានបង្ហាញថា ភាពអាចរកបាននៃការថែទាំកុមារ និងរចនាសម្ព័ន្ធគាំទ្រគ្រួសារនៅប្រទេសកម្ពុជា មានទម្ងន់លើការសម្រេចចិត្តទុកកូនៗនៅប្រទេសកំណើត ធៀបទៅនឹងការនាំពួកគេទៅជាមួយ ក្នុងដំណើរទេសន្តរប្រវេសន៍របស់ឪពុកម្តាយ។

## ប្រេវ៉ាឡង់ លក្ខណៈ និងកាលៈទេសៈរបស់កុមារដែលទុកនៅស្រុកកំណើត

ប្រទេសកម្ពុជាមានប្រវត្តិនិន្នាការទេសន្តរប្រវេសន៍គួរកត់សម្គាល់។ ពលករទេសន្តរប្រវេសន៍ជាស្ត្រីមានចំនួនជាង៥០%មកពីប្រទេសកម្ពុជា។ ការស្រាវជ្រាវលើកុមារទុកនៅក្នុងប្រទេស ដូចជាប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី ដោយមានស្ត្រីចំនួនច្រើនចេញទៅធ្វើការក្រៅប្រទេស បានបង្ហាញថា ផលប៉ះពាល់មួយនៃទេសន្តរប្រវេសន៍ឪពុកម្តាយគឺការបញ្ចូលកុមារីតាំងពីតូចទៅក្នុងសង្គម ដើម្បីឱ្យពួកគេទទួលយកទេសន្តរប្រវេ

[90] Ministry of Planning (2015). *Migration and left-behind households in rural areas in Cambodia: Structure and socio- economic conditions, A CRUMP Series Report.* Accessed at [MigrationandLeftBehindHouseholds-Final.pdf](MigrationandLeftBehindHouseholds-Final.pdf).
Patricia Cortes (2013). *The Feminization of International Migration and its Effects on the Children Left Behind: Evidence from the Philippines,* World Development, Volume 65, 2015, Pages 62-78, ISSN 0305-750X. Accessed at https://doi.org/10.1016/j.worlddev.2013.10.021.

សន៍ឆ្លងប្រទេសជាបទដ្ឋាន[91]។ ការសិក្សាបានបង្ហាញថា នៅពេលកុមារទាំងនេះធំដឹងក្តី ច្រើនយល់អំពីតម្រូវការចាំបាច់ ដែលពួកគេត្រូវចាកចេញពីប្រទេសខ្លួន ស្វែងរកការងារនៅបរទេស ហើយរឿងនេះក្លាយជាវដ្តបន្តនៃការធ្វើដំណើរឆ្លងកាត់ព្រំដែនដែលកើតឡើងក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។

មានការស្រាវជ្រាវតិចតួចអំពីទំហំ និងលក្ខណៈទេសន្តរប្រវេសន៍របស់ឪពុកម្តាយ និងកុមារដែលទុកនៅប្រទេសកម្ពុជា។ តាមការសិក្សាឆ្នាំ ២០១៥ រកឃើញថា អត្រាចំណាកស្រុកពីជនបទ នៅក្នុងប្រទេសកម្ពុជា មាន ចំនួនច្រើន រហូតដល់ ៣០% នៃគ្រួសារ ហើយក្នុងចំនួននេះ យ៉ាងតិច ក៏មានម្នាក់ជាជនទេសន្តរប្រវេសន៍។ ជនទេសន្តរប្រវេសន៍ភាគច្រើន (២២,៩%) គឺជាឪពុកម្តាយដែលទុកកូន និងអ្នកក្នុងបន្ទុកនៅស្រុក[92]។ ការសិក្សាក៏បានបង្ហាញផងដែរថា ទេសន្តរប្រវេសន៍ឪពុកម្តាយដែលទុកកូននៅស្រុកកំណើត ជាទូទៅ មានទម្រង់ជាទេសន្តរប្រវេសន៍អន្តរជាតិ (ភាគច្រើនចេញទៅប្រទេសថៃ) និងករណីបន្ទាប់ ឪពុកម្តាយទាំងពីរធ្វើចំណាកស្រុកក្នុងប្រទេស (ភាគច្រើនទៅទីក្រុងភ្នំពេញ)[93]។

ការសិក្សាថ្មីរបស់អង្គការយូនីសេហ្វ[94] បានរកឃើញថា គ្រួសារ១/៣នៅជនបទខេត្តបាត់ដំបង មានមនុស្សធំពេញវ័យដែលបានធ្វើទេសន្តរប្រវេសន៍។ ឪពុកម្តាយភាគច្រើនបានចាកចេញពីប្រទេស ដោយទុកកូនៗនៅផ្ទះ ហើយកុមារទាំងនោះ ភាគច្រើន មានអាយុក្រោម ១៤ ឆ្នាំ។

## អ្នកមើលថែកុមារដែលទុកនៅស្រុកកំណើត

ការសិក្សាដែលអាចរកបាន បានបង្ហាញថា ជាទូទៅ យាយតាគឺជាអ្នកមើលថែទាំកុមារ រស់នៅប្រទេសកំណើតរបស់ពួកគាត់ នៅពេលដែលឪពុកម្តាយចាកចេញទៅរកការងារ។ មានករណីតិចតួច កុមារត្រូវបានមើលថែដោយម្តាយមីង ជួលកាល នៅជាមួយជីតា។ ការសិក្សានេះបានរកឃើញកម្រិតសមត្ថភាព និងឆន្ទៈផ្សេងៗគ្នាក្នុងចំណោមអ្នកមើលថែកុមារពេញម៉ោង ។ យាយតាជាអ្នកមើលថែខ្លះ មានជំងឺប្រចាំកាយ ដែលកម្រិតសមត្ថភាពរបស់ពួកគាត់។ អ្នកផ្សេងទៀត មើលថែទាំកុមារពីចម្ងាយ ដោយកុមាររស់នៅក្នុងផ្ទះដាច់ដោយឡែក ឬនៅឆ្ងាយពីអ្នកមើលថែ។

មុនពេលចាកចេញ ឪពុកម្តាយបានប្រឹក្សាយោបល់ជាមួយអ្នកមើលថែទាំ អំពីទំនួលខុសត្រូវក្នុងការថែទាំកុមារ តែកម្រិតឆន្ទៈក្នុងការងារនេះ ខុសៗគ្នា។ ការសិក្សានៅខេត្តសៀមរាប (២០១៨)[95] បានរកឃើញថា យាយតាភាគច្រើនមានសុខភាពមិនល្អ ហើយគិតថា ការមើលថែចៅៗរបស់ពួកគាត់ជាបន្ទុកខ្លាំង។ ស្ត្រីវ័យចំណាស់ជាច្រើននៅក្នុងការសិក្សាបានប្រាប់ថា ពួកគាត់គ្មានជម្រើសអ្វី ក្រៅពីនៅចាំគ្រប់គ្រងចៅៗនោះទេ។ ដោយសារពួកគាត់មិនអាចគ្រប់គ្រងកាលៈទេសៈ ទើបបង្ខំឱ្យពួកគាត់ទទួលយកការងារនេះ ទាំងវ័យកាន់តែចាស់ក៏ដោយ។ ក្នុងករណីសិក្សាឆ្នាំ ២០២៣ របស់អង្គការយូនីសេហ្វ បានបង្ហាញថា អ្នកមើលថែមួយចំនួនសប្បាយចិត្តក្នុងការទទួលយកការងារនេះ។ ខ្លះទៀតបាននិយាយថា ពួកគាត់មិនចង់ឱ្យឪពុកម្តាយទៅណាទេ ប៉ុន្តែបាន

[91] IOM (2020). *World migration report. International Organization for Migration.* Accessed at wmr_2020.pdf
[92] Ibid.
[93] Ibid.
[94] UNICEF East Asia and the Pacific Regional Office (2023). *Migration and Family Separation. Accessed at* ASEAN CABM Cambodia.pdf
[95] Jesuit Refugee Service Cambodia (2018). *Quantitative and Qualitative Study on the Impact of Cross-Border Parental Migration on Families Left Behind in Siem Reap Province*, Cambodia.

ទទួលស្គាល់ថា ឪពុកម្ដាយទាំងនោះគ្មានជម្រើស។ ចំពោះអ្នកមើលថែមួយចំនួន ពួកគាត់ចាំបាច់ត្រូវរក្សាការងារ ដើម្បីផ្គត់ផ្គង់តម្រូវការមូលដ្ឋានរបស់ចៅៗឱ្យគ្រប់គ្រាន់ ដូចជាអាហារកិច្ចជាដើម។ ប៉ុន្តែ អ្នកមើលថែផ្សេងទៀត មានមុខងារចម្បង គឺគ្រប់គ្រងមើលការខុសត្រូវដោយផ្ទាល់ដល់កុមារ ដែលឪពុកម្ដាយទុកនៅប្រទេសកំណើត។

## ការផ្ញើរប្រាក់របស់ឪពុកម្ដាយទេសន្តរប្រវេសន៍

អ្នកមើលថែភាគច្រើនដែលបានចូលរួមក្នុងករណីសិក្សា ២០២៣ របស់អង្គការយូនីសេហ្វ បានរាយការណ៍ថា ឪពុកម្ដាយផ្ញើប្រាក់ផ្ញើមកផ្ទះដើម្បីផ្គត់ផ្គង់គ្រួសារ។ ប៉ុន្តែ ចំនួនប្រាក់ដែលឪពុកម្ដាយផ្ញើ មានភាពប្រែប្រួល។ យោងតាមការសិក្សាស្រាវជ្រាវផ្សេងទៀត ខណៈឪពុកម្ដាយភាគច្រើនវេរប្រាក់មកផ្ទះ តែការផ្ញើប្រាក់នេះមិនទៀងទាត់ ឬមិនជាប់លាប់ បូករួមជាមួយបំណុលច្រើន សងថ្លៃសេវាចំណាកស្រុក ធ្វើឱ្យអ្នកនៅផ្ទះទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុតិចតួច។ អ្នកមើលថែខ្លះបានរាយការណ៍ថា ឪពុកម្ដាយចង់វេរប្រាក់មកផ្ទះដែរ ប៉ុន្តែដំបូងត្រូវសងបំណុលសេវាមេខ្យល់សិន និងបង់ថ្លៃឯកសារផ្សេងៗទាក់ទងនឹងទេសន្តរប្រវេសន៍។ ពលករទេសន្តរប្រវេសន៍ជាច្រើនយក "ប្រាក់កម្ចី" ដែលគេស្គាល់ថាជា "ប្រាក់កម្ចីចំណាកស្រុក" ដើម្បីយកទៅចំណាយលើការផ្លាស់ប្តូរទីលំនៅរបស់ពួកគេនៅបរទេស ហើយចំនួនជាង ៧០% បច្ចុប្បន្ន កំពុងស្ថិតក្នុងដំណើរការទូទាត់បំណុលទាំងនេះ។ អ្នកខ្លះទៀតបានបញ្ជាក់ថា ឪពុកម្ដាយវេរប្រាក់មកម្ដងម្កាល ឬមិនទៀងទាត់។

ខណៈការផ្ញើរប្រាក់នេះ ផ្តល់អត្ថប្រយោជន៍ជាអាហារូបត្ថម្ភ និងសុខភាពដល់កុមារ តែការសិក្សាបង្ហាញថា ថវិកាទាំងនេះ មិនផ្សារភ្ជាប់ទៅនឹងសេវាមើលថែជំងឺកុមារប្រកបដោយគុណភាព ឬការចូលទៅប្រើមូលដ្ឋានសុខាភិបាលសាធារណៈដែលមានតម្លៃទាប ក្នុងចំណោមអ្នកចូលប្រើសេវាពេទ្យជាផ្លូវការនោះទេ។ ដូច្នេះ បើគ្មានគោលនយោបាយ ឬកម្មវិធីអន្តរាគមន៍បន្ថែមទេនោះ ការផ្ញើរប្រាក់ទំនងជាមិនអាចផ្លាស់ប្តូរគំរូនៃការស្វែងរកការថែទាំជំងឺកុមារនៅក្នុងតំបន់ដែលមានជនទេសន្តរប្រវេសន៍ជាអ្នកវេរប្រាក់នោះឡើយ[96]។ ដោយសារជនទេសន្តរប្រវេសន៍កម្ពុជា និងកុមារទុកនៅស្រុកកំណើត មានចំនួនកាន់តែច្រើន កង្វះខាតទំនាក់ទំនងរវាងការផ្ញើរប្រាក់ និងការប្រើសេវាថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ និង/ឬតម្លៃទាប គឺជាកត្តាសំខាន់សម្រាប់អ្នកធ្វើគោលនយោបាយ និងភាគីពាក់ព័ន្ធ គិតគូរស្វែងរកវិធីជួយកុមារ ឱ្យទទួលបានសេវាសុខភាពល្អប្រសើរ និងមានសមធម៌ ជាពិសេស នៅតំបន់ដែលមានការធ្វើទេសន្តរប្រវេសន៍ខ្ពស់។

## ទំនាក់ទំនងជាមួយឪពុកម្ដាយទេសន្តរប្រវេសន៍

របកគំហើញតាមរយៈសម្ភាសន៍ជាមួយកុមារ និងអ្នកមើលថែក្នុងករណីសិក្សា ឆ្នាំ២០២៣ របស់អង្គការយូនីសេហ្វ បានបង្ហាញពីភាពប្រែប្រួលនៃការទាក់ទងរវាងកុមារជាមួយឪពុកម្ដាយរបស់ពួកគេ ។ កុមារភាគច្រើនបានរាយការណ៍ថា ពួកគេនិយាយជាមួយឪពុកម្ដាយរបស់ខ្លួន តាមទូរស័ព្ទ ទោះបីជាខ្លះនិយាយជាមួយឪពុកម្ដាយមិនបានញឹកញាប់ក៏ដោយ តែខ្លះទៀតនិយាយស្ទើរតែរាល់ថ្ងៃ។ នៅក្នុងការស្ទង់មតិរបស់ជនទេសន្តរប្រវេសន៍

[96] Treleaven E, Ngin C. When parents are not present: Decision-making dynamics for young children's health and illness in migrant-sending households in rural Cambodia. Soc Sci Med. 2021 Oct;287:114327. doi: 10.1016/j.socscimed.2021.114327. Epub 2021 Aug 25. PMID: 34509896; PMCID: PMC8518313. ; Treleaven E. Migration and investments in the health of children left behind: the role of remittances in children's healthcare utilization in Cambodia. Health Policy Plan. 2019 Nov 1;34(9):684-693. doi: 10.1093/heapol/czz076. PMID: 31539036; PMCID: PMC6880323.

ដែលបានត្រឡប់មកវិញ មានចំនួន ៧៥% នៃឪពុកម្តាយបានរាយការណ៍ថា បាននិយាយជាមួយកូនៗរបស់ពួកគេជារៀងរាល់ថ្ងៃ។ អ្នកសម្ភាសន៍ ប្រាប់ថា មានករណីលើសពីមួយ មិនបានទាក់ទងជាមួយឪពុកម្តាយជនទេសន្តរប្រវេសន៍នោះទេ។ កុមារភាគច្រើនបានលើកឡើងថា ការហៅទូរស័ព្ទជាមធ្យោបាយដ៏សំខាន់មួយក្នុងទំនាក់ទំនងជាមួយឪពុកម្តាយ។ ពួកគេបានសម្តែងការរីករាយពេលនិយាយជាមួយឪពុកម្តាយ ខណៈមានចំនួនតិចតួចបញ្ជាក់ថា ពួកគេមិនសូវមានអារម្មណ៍ល្អ ពេលនិយាយជាមួយឪពុកម្តាយនោះទេ។ កុមារខ្លះមិនបានឃើញឪពុកម្តាយរបស់ពួកគេ ចាប់តាំងពីពួកគាត់ចាកចេញពីស្រុក (ជាទូទៅអស់ជាច្រើនឆ្នាំ) មានកុមារខ្លះទៀតបានរាយការណ៍ថា ឪពុកម្តាយរបស់ពួកគេបានមកលេងផ្ទះ (មានខ្លះកម្រមក និងខ្លះទៀតមកលេងបានទៀងទាត់)។ ឪពុកម្តាយទេសន្តរប្រវេសន៍ទៅប្រទេសថៃមានទំនោរតិចតួចនឹងត្រឡប់មកផ្ទះវិញ (ប្រហែលម្តងក្នុងមួយឆ្នាំ ឬតិចជាង) ជាងឪពុកម្តាយធ្វើចំណាកស្រុកក្នុងប្រទេស។

## ស្ថានភាពឪពុកម្តាយទេសន្តរប្រវេសន៍ ជំពោះកូនៗទុកនៅស្រុកកំណើត

### ហានិភ័យនៃកិច្ចការពារ

កុមារដែលទុកនៅស្រុកកំណើត ងាយទទួលរងហានិភ័យនៃកិច្ចការពារផ្សេងៗ។ ខណៈឪពុកម្តាយជាច្រើនបានចេញពីស្រុកទៅរកប្រាក់ផ្គត់ផ្គង់គ្រួសារជាចម្បង កុមារភាគច្រើនក្នុងការស្រាវជ្រាវនេះ បន្តរស់នៅក្នុងភាពក្រីក្រដោយមានភស្តុតាងគាំទ្រស្រាប់ បង្ហាញថាភាពក្រីក្រតែងតែកើតមានចំពោះកុមារដែលត្រូវបានទុកនៅស្រុកកំណើត។

### ការទទួលបានតម្រូវការមូលដ្ឋាន និងការសិក្សា

ទោះបីឪពុកម្តាយសម្រេចចិត្តទុកកូនឱ្យនៅស្រុកកំណើត ជារឿយៗ ពួកគេយល់ឃើញថា ការទុកកូននៅស្រុកកំណើត ជួយឱ្យកូនៗពួកគេមានលទ្ធភាពទទួលបានការអប់រំ ប៉ុន្តែមានករណីជាច្រើន រកឃើញថា កុមារដែលទុកនៅសហគមន៍ ខ្វះធនធានរៀនបានពេញលេញ ហើយជារឿយៗ ទៅសាលាមិនជាប់លាប់ ខកខានចូលរៀនទៅធ្វើការដោយកម្លាំងបាយ ឬមិនចូលរៀនតែម្តង។ អ្នកខ្លះមិនមានមធ្យោបាយហិរញ្ញវត្ថុ និងភស្តុការ ដើម្បីបញ្ជូនកូនទៅសាលារៀន។ តាមកត្តាសេដ្ឋកិច្ច កុមារដែលទុកនៅស្រុកកំណើត ច្រើនតែប្រឈមនឹងការលំបាក។ ក្នុងចំណោមគ្រួសារជនទេសន្តរប្រវេសន៍ ស្ថានភាពសេដ្ឋកិច្ចសង្គមមានទំនោរកាន់តែលំបាក នៅពេលមេគ្រួសាររស់តែម្នាងដែលជាឪពុកម្នាង ឬម្តាយម្នាង របស់ជនទេសន្តរប្រវេសន៍ (ឧទាហរណ៍ ជីតារបស់កុមារដែលឪពុកម្តាយទុកឱ្យនៅជាមួយ) ហើយមេគ្រួសារទាំងនេះ ទំនងភាគច្រើនជាស្ត្រី[97]។ ការផ្ញើរប្រាក់ទៅផ្ទះដោយឪពុកម្តាយទេសន្តរប្រវេសន៍ អាចមិនគ្រប់គ្រាន់លើការចំណាយទាំងអស់នោះទេ ហើយកុមារអាចត្រូវបង្ខំឱ្យឈប់រៀនមុនអាយុ ដើម្បីរកប្រាក់ចំណូលបន្ថែមជួយគ្រួសារ។ ចំណុចនេះអាចកាត់បន្ថយឱកាស និងអនាគតការងារពួកគេ។

[97] Migration and left-behind households in rural areas in Cambodia: Structure and socio- economic conditions, A CRUMP Series Report, Ministry of Planning 2015.

*"កុមារដែលត្រូវបានទុកនៅស្រុកកំណើត ទទួលបានការមើលថែ និងជំនួយជួយ បានតិច មានហានិភ័យនៃការរំលោភបំពានកាន់តែច្រើន"* គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (PCCT)

## ការមិនយកចិត្តទុកដាក់ និងកុមារមានតួនាទីជាអ្នកមើលថែ

ការមិនយកចិត្តទុកដាក់ដល់កុមារនៅតែជាកង្វល់ដ៏ចម្បងមួយនៅក្នុងប្រទេសកម្ពុជា ជាពិសេស ប៉ះពាល់ដល់អនីតិជនដែលទុកនៅស្រុកកំណើត ពេលឪពុកម្តាយចាកចេញទៅក្រៅប្រទេសដើម្បីរកការងារធ្វើ [98] ។ នេះបើយោងតាមរបាយការណ៍ដែលចេញដោយអង្គការទស្សនៈពិភពលោក (២០២១)[99] យុវជនកម្ពុជាជាច្រើនបន្តខ្វះអាហារូបត្ថម្ភ ខ្វះការថែទាំសេវាពេទ្យ និងឱកាសសិក្សា ដោយសារភាពក្រីក្រ និងលទ្ធភាពទទួលបានធនធានពីសហគមន៍នៅមានកម្រិត។ ដោយខ្វះអាហារូបត្ថម្ភ ការថែទាំសុខភាព និងការចូលរៀនសមស្របកុមារទាំងនេះប្រឈមបញ្ហាដែលអាចកើតមានរយៈពេលវែងលើរាងកាយ ផ្លូវចិត្ត និងការអភិវឌ្ឍន៍។ អង្គការទស្សនៈពិភពលោក (ឆ្នាំ ២០២១) បានកត់សម្គាល់ថា កង្វះខាតរយៈពេលយូរលើចំណុចសំខាន់ៗទាំងនេះ ក្នុងអំឡុងពេលនៃការលូតលាស់ដ៏សំខាន់ អាចបង្កផលអវិជ្ជមាន ដែលបន្តកើតមានរហូតដល់ពេលពួកគេធំពេញវ័យ។

ការសិក្សាជាច្រើនបានរកឃើញថា អ្នកមើលថែកុមារដែលឪពុកម្តាយទុកនៅស្រុកកំណើត ភាគច្រើនគឺជាយាយតា។ ការសិក្សារបស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM ) ២០១៩ បានរាយការណ៍ថា កុមារ៧៥% ដែលឪពុកម្តាយទុកនៅស្រុក មានយាយតាជាអ្នកមើលថែ ហើយអ្នកមើលថែ៤០% មានអាយុលើសពី ៦០ ឆ្នាំ ហើយពួកគាត់ទាំងនោះគឺជាស្ត្រី មានចំនួន៩៥%[100]។ ជារឿយៗ កុមារដែលនៅស្រុកកំណើត ជួយមើលថែយាយតា អាណាព្យាបាល ឬប្អូនៗបង្កើតរបស់ពួកគេ។ កុមារទាំងនេះងាយរងការមិនយកចិត្តទុកដាក់។ ការមិនយកចិត្តទុកដាក់គឺជាការព្រួយបារម្ភខ្ពស់បំផុតដែលត្រូវបានរាយការណ៍ដោយឪពុកម្តាយនៅក្នុងការស្ទង់មតិជនទេសន្តរប្រវេសន៍ ដែលវិលត្រឡប់មកប្រទេសវិញ។ កុមារ និងអ្នកមើលថែជាច្រើនបានរាយការណ៍ថា អ្នកមើលថែមិនអាចបំពេញតម្រូវការថែទាំជាមូលដ្ឋានដល់កុមារបានទេ។ របាយការណ៍បង្ហាញថា កុមារដែលទុកនៅស្រុកកំណើត ងាយទទួលរងការមិនយកចិត្តទុកដាក់ ដោយសារភាពក្រីក្រ អាយុ និងសមត្ថភាពរាងកាយរបស់អ្នកមើលថែ និងកង្វះជំនាញចិញ្ចឹមបីបាច់កុមាររបស់អ្នកទាំងនោះ។

*"កុមារទុកនៅស្រុកកំណើត នៅជាមួយយាយតា ដោយពួកគាត់មើលថែទាំងចៅៗមិនបានជិតដល់។ តាមពិត ចៅៗ ត្រូវមើលថែយាយតាទៅវិញ ហើយមិនបានចូលសាលា"។* អ្នកផ្តល់សេវា NGO ។

---

[98] Child Exploitation Situational Analysis Cambodia, Terre des Hommes Netherlands 2023.
[99] https://www.wvi.org/newsroom/cambodia/concerns-over-child-malnutrition
[100] https://www.iom.int/project/migration-and-its-impact-cambodian-children-and-families-miccaf

## ការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ

ករណីសិក្សាខេត្តសៀមរាប (២០១៨)[101] បានរកឃើញថា កុមារបានរងផលប៉ះពាល់អារម្មណ៍ និងផ្លូវចិត្តមិនល្អដោយទេសន្តរប្រវេសន៍។ ជាពិសេស ការផ្លាស់ទីលំនៅ បានរំខានដល់ទំនាក់ទំនងរវាងឪពុកម្តាយ និងកូនៗ។ កុមារដែលទុកនៅស្រុកកំណើត ក៏ងាយរងការរំលោភបំពានផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវភេទផងដែរ។ កុមារ និងអ្នកមើលថែ ជាច្រើននាក់បានរាយការណ៍ថា អ្នកមើលថែកុមារស្រែកគំហុកដាក់ពួកគេ ហើយវាយពួកគេនៅពេលពួកគេធ្វើអ្វីមួយខុស ដោយអ្នកមើលថែប្រាប់ថា ករណីនេះច្រើនកើតឡើងដោយភាពតានតឹងពីការទទួលខុសត្រូវក្នុងការថែទាំ និងផលលំបាកផ្នែកហិរញ្ញវត្ថុ។

ការរកឃើញករណីសិក្សាឆ្នាំ ២០២៣ របស់អង្គការយូនីសេហ្វ ពីការសម្ភាសន៍ជាមួយកុមារ និងអ្នកមើលថែ បានកត់សម្គាល់ថា អ្នកមើលថែអាចមានការខកចិត្តចំពោះកង្វះថវិកាដែលឪពុកម្តាយផ្ញើមកកុមារបានតិច។ កុមារដែលគ្មានទំនាក់ទំនងជាមួយឪពុកម្តាយ និងខ្វះការជួយ ឬបណ្តាញកិច្ចការពារកុមារនៅក្នុងសហគមន៍ អាចរងហានិភ័យខ្ពស់នៃការរំលោភបំពានផ្សេងៗ។ សុខភាពផ្លូវចិត្តមិនល្អ និងសុខុមាលភាពថមថយ ការចូលប្រឡូករបស់កុមារក្នុងចរិកគ្រោះថ្នាក់ និងកម្សោយទំនាក់ទំនងក្នុងគ្រួសារ (ជាពិសេសជម្លោះក្នុងគ្រួសារ) បណ្តាលឱ្យកុមារដែលឪពុកម្តាយទុកនៅស្រុកកំណើតរងហានិភ័យកាន់តែខ្លាំងបន្ថែមទៀត។

ការសិក្សាឆ្នាំ ២០១៧ រៀបចំឡើងដោយវិទ្យាស្ថានសភាកម្ពុជា[102] បានរកឃើញថា នៅពេលឪពុកម្តាយទាំងពីរធ្វើការនៅក្រៅប្រទេស ឬក្នុងប្រទេសឆ្ងាយពីផ្ទះ កុមារដែលទុកនៅស្រុកកំណើត មានអត្រាខ្ពស់នៃការរងរបួស មានជំងឺ និងកង្វះអាហារូបត្ថម្ភ។ គម្រោងស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាលបានប៉ាន់ប្រមាណថា កុមារដែលមានតម្រូវការពិសេស ទំនងជាទទួលរងអំពើហិង្សាពី ៣ ទៅ ៥ ដង បើប្រៀបធៀបទៅនឹងកុមារដទៃទៀត។ ការរំលោភបំពានផ្លូវភេទ កើតឡើងស្ទើរតែ ៥ ដងច្រើនជាងមុន ក្នុងចំណោមកុមារដែលមានពិការភាពផ្លូវចិត្ត ឬសតិបញ្ញា[103]។ បច្ចុប្បន្ននេះ មិនមានទិន្នន័យដែលអាចរកបានអំពីបទពិសោធន៍ និងកាលៈទេសៈជាក់លាក់លើកុមារដែលមានពិការភាពរាងកាយ និងសតិបញ្ញា ដែលឪពុកម្តាយទុកនៅស្រុកកំណើត។ គេចាំបាច់ត្រូវស្រាវជ្រាវបន្ថែម ស្វែងយល់ និងដោះស្រាយបញ្ហាប្រឈមនានា ដែលក្រុមកុមារងាយរងគ្រោះជួបប្រទះក្នុងស្ថានភាពទាំងនេះ។

## ពលកម្មកុមារ ពលកម្មដោយបង្ខំ និងការជួញដូរ

ពលកម្មកុមារគឺជាកង្វល់ជាយូរមកហើយនៅក្នុងតំបន់។ ក្មេងស្រីភាគច្រើនធ្វើការជាកម្មករតាមផ្ទះ ឬរោងចក្រ ក្មេងប្រុសធ្វើការជាកម្មកររោងចក្រ ឬកម្មករសំណង់ នេសាទ ឬធ្វើការងារប្រចាំថ្ងៃផ្សេងទៀត[104]។ ករណីសិក្សាឆ្នាំ ២០២៣ របស់អង្គការយូនីសេហ្វ ការរកឃើញតាមរយៈការសម្ភាសន៍ជាមួយកុមារ និងអ្នកមើលថែ បានរកឃើញថា កុមារតែងតែចូលរួមក្នុងសកម្មភាពពលកម្មកុមារដើម្បីរកចំណូលផ្គត់ផ្គង់គ្រួសារ។ ហានិភ័យនៃពល

[101] Quantitative and Qualitative Study on the Impact of Cross-Border Parental Migration on Families Left Behind in Siem Reap Province, Cambodia, Jesuit Refugee Service Cambodia 2018.

[102] Sothorn, M. K., Vanthen, M. K., & Samnang, M. S. (2017). Migration, Human Trafficking Prevention and Sexual Exploitation. Study Commissioned by Parliamentary Institute of Cambodia

[103] https://childhood.org/project/support-for-children-with-disabilities/

[104] Huijsmans, R., & Baker, S. (2012). Child trafficking: 'Worst form' of child labour, or worst approach to young migrants? *Development and Change, 43*(4), 919–946. https://doi. org/10.1111/j.1467-7660.2012.01786.x

កម្មកុមារទាំងនេះ ត្រូវបានផ្សារភ្ជាប់ទៅនឹងភាពក្រីក្រ។ កុមារជាច្រើន (ក្មេងប្រុស និងក្មេងស្រី) បានរាយការណ៍ថា ពួកគេត្រូវធ្វើការ រកប្រាក់ចំណូលបន្ថែម ដើម្បីជួយគ្រួសាររបស់ពួកគេ។

ទម្រង់ពិសេសមួយនៃពលកម្មកុមារដែលត្រូវបានរាយការណ៍ដោយអ្នកមើលថៃ និងកុមារ គឺការចាប់សត្វជាអាហារ ឬជួយបសុសត្វ។ ការងារផ្សេងទៀតដែលកុមារធ្វើរួមមាន ការវេចខ្ចប់លាមកសត្វ ការនេសាទ បេះ និងលក់រុក្ខជាតិ ឬផ្កា និងការចាប់សត្វកណ្ដុរ។ ការនេសាទ និងការចាប់សត្វហាក់ជាការងារទូទៅសម្រាប់ក្មេងប្រុស។ ជារឿយៗ កុមារធ្វើការមុនឬក្រោយម៉ោងរៀន។ កុមារខ្លះធ្វើការប្រចាំថ្ងៃ ចំណែកខ្លះទៀតធ្វើការតែពីរឬបីថ្ងៃក្នុងមួយសប្ដាហ៍។ ក្នុងករណីខ្លះ កុមារធ្វើការនៅម៉ោងចូលរៀន ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ជាពិសេសបើការងារនោះជាការងារតាមរដូវកាល។ ក្នុងករណីខ្លះ អ្នកមើលថែទាំក៏លើកទឹកចិត្តកុមារមិនទៅរៀន ដើម្បីទៅធ្វើការរកប្រាក់ចិញ្ចឹមគ្រួសារ ក៏មាន។

ខណៈករណីសិក្សាឆ្នាំ ២០២៣ របស់អង្គការយូនីសេហ្វបានយោងពលកម្មកុមារថា ជាបញ្ហាទូទៅក្នុងចំណោមកុមារដែលឪពុកម្ដាយទុកនៅស្រុកកំណើត ប៉ុន្តែ ករណីនេះមិនទាំងអស់។ ក្នុងស្ថានភាពទូទៅ មានកាលៈទេសៈដែលកុមារមិនអាចជៀសបាន។ ផ្ទុយទៅវិញ ពលកម្មកុមារដោយផ្ទាល់ កើតចេញពីភាពក្រីក្រដែលពួកគេប្រឈម និងតម្រូវការហិរញ្ញវត្ថុរបស់គ្រួសារ បង្ខំឱ្យពួកគេបង្កើនប្រាក់ចំណូល។ កិច្ចសម្ភាសន៍ខ្លះជាមួយកូនៗ និងឪពុកម្ដាយរបស់ពួកគេដែលត្រឡប់មកស្រុកវិញ បានបង្ហាញថា ទោះបីមកដល់ស្រុកហើយក្តី កុមារនៅតែជួយធ្វើការងារឪពុកម្ដាយពួកគេ ទោះបីជាគ្រួសារបានជួបជុំគ្នាឡើងវិញហើយក៏ដោយ។

ខណៈការជួយការងារនៅតាមផ្ទះមិនមានគ្រោះថ្នាក់អ្វីក៏ដោយ តែមានករណីខ្លះ ក៏រំខានដល់ការសិក្សារ និងការលូតលាស់របស់កុមារដែរ។ ទំនួលខុសត្រូវច្រើនហួសប្រមាណនេះ អាចធ្វើឲ្យកុមារបាក់កម្លាំង និងមិនអាចផ្ចង់លើការសិក្សារបស់ពួកគេបានទេ។